**នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០៣/០៧-០៩-២០០៩-អវតក/កសចស |
| ដាក់ទៅ | : | សហចៅក្រមស៊ើបអង្កេត |
| ថ្ងៃដាក់ | : | ថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៣ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញាអន្តរជាតិ |
| ភាសាដើម | : | **អង់គ្លេស** |

**ឯកសារបកប្រែ**
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 23-Apr-2013, 09:33
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សម្ងាត់បំផុត**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយ កសចស: សម្ងាត់បំផុត/Strictly Confidential

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ: **ប្តូរទៅជាសាធារណៈ**

ការពិនិត្យចំណាត់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**សេចក្តីសន្និដ្ឋានបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីពីទំនាស់ផលប្រយោជន៍**
**របស់សហមេធាវីចាត់តាំង**

---

**អ្នកដាក់ឯកសារ:**
ការិ.សហព្រះរាជអាជ្ញា:
លោក Andrew CAYLEY

**ចម្លងជូន:**
លោកស្រី ជា លាង

**អ្នកទទួលឯកសារ:**
ការិ.សហចៅក្រមស៊ើបអង្កេត:
ចៅក្រម យូ ប៊ុនឡេង
ចៅក្រម Mark B. HARMON

**ចម្លងជូន:**
ផ្នែកគាំពារការការពារក្តី
លោក Isaac ENDELEY

**ជនសង្ស័យ**
មាស មុត

**សហមេធាវីចាត់តាំងសម្រាប់ជនសង្ស័យ**
លោក អាង ឧត្តម
លោក Michael KARNAVAS

# I. សេចក្តីផ្តើម និង ប្រវត្តិនីតិវិធី

១- នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៣ លោក អាង ឧត្តម និងលោក Michael KARNAVAS ("សហមេធាវីចាត់តាំង") បានដាក់ចម្លើយតបរបស់ខ្លួន ("ចម្លើយតប")[1] ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ("សំណើ")[2]សុំឲ្យបដិសេធការតែងតាំងពួកគាត់ជាអ្នកការពារឲ្យជនសង្ស័យ មាស មុត ក្នុងសំណុំរឿង ០០៣ ដោយឈរលើទឡ្ហីករណ៍នៃទំនាស់ផលប្រយោជន៍ដែលមិនអាចផ្សះផ្សារបាន និងបុរេនិច្ឆ័យដែលមិនអាចវិលត្រឡប់ចំពោះរដ្ឋបាលតុលាការ។ នៅក្នុងសេចក្តីសម្រេច និងដីកាកំណត់កាលបរិច្ឆេទចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៣ ("សេចក្តីសម្រេចលើកទីមួយ") សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានអញ្ជើញសហមេធាវីចាត់តាំងឲ្យបង្ហាញការលះបង់សិទ្ធិដែលទទួលបានពីជនសង្ស័យ និងជនជាប់ចោទ អៀង សារី នៅក្នុងរយៈពេលបីថ្ងៃនៃថ្ងៃធ្វើការ ឲ្យដាក់សេចក្តីសន្និដ្ឋាននៅក្នុងរយៈពេលដប់ថ្ងៃនៃថ្ងៃធ្វើការ និងបានអញ្ជើញសហព្រះរាជអាជ្ញាដាក់ការឆ្លើយតបនៅក្នុងរយៈពេលប្រាំថ្ងៃនៃថ្ងៃធ្វើការ[3]។ ក្នុងដីកាសម្រេចកំណត់កាលបរិច្ឆេទឡើងវិញ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៣ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានកត់សម្គាល់ពី "កង្វះនៃការអនុវត្ត"[4] របស់សហមេធាវីចាត់តាំងចំពោះលក្ខខណ្ឌផ្សេងៗនៃសេចក្តីសម្រេច និងដីកាកំណត់កាលបរិច្ឆេទ ហើយក៏បានពន្យារពេលកំណត់នៃការដាក់ឯកសាររបស់ខ្លួនរហូតដល់ថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៣។ ទោះបីជាចម្លើយតបត្រូវបានដាក់យ៉ាងត្រឹមត្រូវនៅថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៣ ក៏ដោយ ក៏សហព្រះរាជអាជ្ញាទើបបានទទួលការជូនដំណឹងនៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៣។

២- ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣ អៀង សារី បានទទួលមរណភាពក្នុងពេលឃាត់ និងឃុំខ្លួន នៅក្នុងបរិវេណនៃមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត[5] ហើយកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងគាត់ ក្នុងសំណុំរឿង០០២ ត្រូវបានបញ្ចប់យ៉ាងត្រឹមត្រូវដោយអង្គជំនុំជម្រះសាលាដំបូង[6]។ ថ្ងៃទី១៥ ខែមីនា ឆ្នាំ

[1] **D56/4/1** សំណើសុំបន្ថែមចំនួនទំព័រកំណត់ និងសារណារបស់សហមេធាវីស្តីពីទំនាស់ផលប្រយោជន៍ជាសក្តានុពល នៅក្នុងការធ្វើការការពារឲ្យលោក មាស មុត ក្នុងសំណុំរឿង ០០៣, ៤ មីនា ២០១៣។

[2] **D56/1** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឲ្យច្រានចោលការចាត់តាំងសហមេធាវីចាត់តាំង ដោយផ្អែកលើទំនាស់ផលប្រយោជន៍ដែលមិនអាចផ្សះផ្សាបាន, ២៤ ធ្នូ ២០១២។

[3] **D56/3** សេចក្តីសម្រេច និងដីកាកំណត់កាលបរិច្ឆេទទាក់ទងនឹងសំណើសុំការចាត់តាំងសហមេធាវីចាត់តាំង, ១១ កុម្ភៈ ២០១៣។

[4] **D56/4** ដីកាសម្រេចកំណត់កាលបរិច្ឆេទឡើងវិញពាក់ព័ន្ធនឹងសំណើសុំការចាត់តាំងសហមេធាវីចាត់តាំង, ២៨ កុម្ភៈ ២០១៣។

[5] **CF002-E270** លិខិតមរណភាព អៀង សារី, ១៤ មីនា ២០១៣។

[6] **CF002-E270/1 [D56/4/2.1.1]** ការបញ្ចប់កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទ អៀង សារី, ១៤ មីនា ២០១៣។

២០១៣ សហមេធាវីចាត់តាំងបានដាក់សេចក្តីជូនដំណឹងមួយទៅសហចៅក្រមស៊ើបអង្កេត ដោយអះអាងថា ការបញ្ចប់កិច្ចដំណើរការនីតិវិធីប្រឆាំងនឹង អៀង សារី ធ្វើឲ្យសំណើ "លែងមានភាពចាំបាច់យ៉ាងមានប្រសិទ្ធិភាព"[7]។ នៅថ្ងៃដដែល សហព្រះរាជអាជ្ញាអន្តរជាតិ បានស្នើសុំការកំណត់កាលបរិច្ឆេទនៃការដាក់សេចក្តីសន្និដ្ឋានដែលបានកែសម្រួល ដើម្បីអនុញ្ញាតឲ្យមានការពន្យល់ដោយសង្ខេបគ្រប់គ្រាន់ពីការផ្លាស់ប្តូរនៃកាលៈទេសៈផ្សេងៗ បណ្តាលមកពីមរណភាពរបស់ អៀង សារី[8]។ ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៣ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានច្រានចោលសំណើរបស់មេធាវីការពារក្តី និងបានផ្តល់ការអនុញ្ញាតតាមសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដោយបានអញ្ជើញឲ្យដាក់សេចក្តីសន្និដ្ឋានត្រឹមថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៣ ("សេចក្តីសម្រេចលើកទីពីរ")[9]។

៣- សហព្រះរាជអាជ្ញាអន្តរជាតិ ដាក់សេចក្តីសន្និដ្ឋានបន្ថែមនេះ អនុលោមតាមសេចក្តីសម្រេចលើកទីពីរ ដោយធ្វើការបង្រួមសេចក្តីយោងនៃខ្លឹមសារក្នុងសំណើដំបូងរបស់ខ្លួន។

៤- សហព្រះរាជអាជ្ញាអន្តរជាតិសន្និដ្ឋានដោយសង្ខេបថា កាតព្វកិច្ច និងដំណើរទាក់ទងគ្នារបស់សហមេធាវីចាត់តាំងចំពោះ អៀង សារី បង្កើតឲ្យមានទំនាស់ខាងផលប្រយោជន៍ដែលមិនអាចផ្សះផ្សាបានជាមួយនឹងសំណើសុំធ្វើអ្នកតំណាងឲ្យ មាស មុត ជាពិសេស ដោយសារកិច្ចដំណើរការនីតិវិធីមានលក្ខណៈប្រទាក់ក្រឡាគ្នានៅផ្នែកខាងក្នុងប្រឆាំងនឹងកូនក្តីនានា។ លើសពីនេះ ការអនុញ្ញាតឲ្យសហមេធាវីចាត់តាំងធ្វើតំណាងឲ្យ មាស មុត ចំពោះកាលៈទេសៈទាំងនេះ នឹងធ្វើឲ្យខូចដល់កាតព្វកិច្ចវិជ្ជាជីវៈទាំងចំពោះ អៀង សារី និង មាស មុត និងថែមទាំងធ្វើឲ្យខូចដល់ជំនឿរបស់សាធារណជនចំពោះ អ.វ.ត.ក និងការគ្រប់គ្រងយុត្តិធម៌ផង។ ទាំងនេះគឺជាផលប្រយោជន៍ដែលសហចៅក្រមស៊ើបអង្កេតមានអំណាច និងកាតព្វកិច្ចជាប់មកជាមួយស្រាប់ដើម្បីការពារឲ្យខានតែបាន ហើយដែលផ្តល់នូវមូលហេតុបន្ថែម និងឯករាជ្យចំពោះការមិនបញ្ចោក់អះអាងក្នុងការទទួលយកការតែងតាំងសហមេធាវីចាត់តាំង។ តាមរបៀបផ្សេងពីនេះ បើសិនជាសហចៅក្រមស៊ើបអង្កេតរកឃើញថា អៀង សារី និង មាស មុត បានយល់ព្រមយ៉ាងត្រឹមត្រូវចំពោះទំនាស់ខាងផលប្រយោជន៍ជាច្រើនដែលកំពុងកើតមាន នោះសហព្រះរាជអាជ្ញាសន្និដ្ឋានថា សហមេធាវីចាត់តាំង

[7] **D56/4/2** សេចក្តីជូនដំណឹងអំពីការបញ្ចប់កិច្ចដំណើរការនីតិវិធីប្រឆាំងនឹង អៀង សារី ក្នុងសំណុំរឿង ០០២, ១៥ មីនា ២០១៣។

[8] **D56/4/3** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំកំណត់កាលបរិច្ឆេទជាថ្មីសម្រាប់ការដាក់សេចក្តីសន្និដ្ឋាន, ១៥ មីនា ២០១៣។

[9] **D56/5** សេចក្តីសម្រេច និងដីកាកំណត់កាលបរិច្ឆេទឡើងវិញលើកទីពីរទាក់ទងនឹងសំណើសុំការចាត់តាំងសហមេធាវីចាត់តាំង, ១៩ មីនា ២០១៣។

មិនគួរទទួលបានការតែងតាំងឡើយដោយហេតុថា ការលះបង់សិទ្ធិដែលបានផ្តល់ជូន មិនសមទំនងទេទាំងផ្នែកនីតិវិធី និងសារធាតុ ហើយក៏មិនអាចដោះស្រាយបានទៀតផង នៅក្រោយមរណភាពរបស់ អៀង សារី ។

## II. សំណើសុំការអនុញ្ញាតដាក់តែមួយភាសាផ្លូវការជាមុនសិន និងសុំបន្ថែមចំនួនទំព័រកំណត់

៥- អនុលោមតាមមាត្រា ៧.២ នៃសេចក្តីណែនាំអនុវត្តជាធរមាន[10] សហព្រះរាជអាជ្ញាអន្តរជាតិសូមស្នើការអនុញ្ញាតពីសហចៅក្រមស៊ើបអង្កេតដាក់សេចក្តីសន្និដ្ឋានបន្ថែមនេះ តែជាភាសាអង់គ្លេសមួយសិន ចំណែកភាសាខ្មែរនឹងដាក់បន្ទាប់ភ្លាមៗតាមដែលអាចធ្វើបាន ទំនងជាក្នុងរយៈពេលបីថ្ងៃនៃថ្ងៃធ្វើការ។ មរណភាពរបស់ អៀង សារី កាលពីថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣ មានតម្លៃស្មើនឹងការផ្លាស់ប្តូរកាលៈទេសៈនានាដែលតម្រូវឲ្យមានការស្រាវជ្រាវផ្នែកច្បាប់ដ៏ទូលំទូលាយ និងដ៏ស្មុគស្មាញ និងការវិភាគដោយប្រៀបធៀបពីប្រភពច្បាប់នានា និងអំពីទម្លាប់ក្នុងការអនុវត្តនៃប្រព័ន្ធច្បាប់ជាច្រើនដើម្បីផ្តល់នូវសេចក្តីសង្ខេបឲ្យបានគ្រប់គ្រាន់ និងត្រឹមត្រូវ។ ជាការបន្ថែម ការទទួលខុសត្រូវជាពិសេសរបស់ការិយាល័យសហព្រះរាជអាជ្ញា នៅក្នុងការស្រាវជ្រាវអំពីមូលហេតុនៃមរណភាពរបស់ អៀង សារី[11] តម្រូវឲ្យមានការលៃលកបែងចែកធនធានទ្រទ្រង់ និងជាដុំកំភួននៅក្នុងការិយាល័យនេះ ដែលឡើងដល់ចំណុចកំពូលនៅក្នុងពេលដាក់របាយការណ៍លម្អិតកាលពីថ្ងៃទី២ ខែមេសា ឆ្នាំ២០១៣។ ក្នុងកាលៈទេសៈពិសេសទាំងនេះ ដែលរួមមានដំណើរការបកប្រែ ការពិគ្រោះយោបល់ និងការពិនិត្យឡើងវិញលើសេចក្តីសន្និដ្ឋានបន្ថែមនេះជាភាសាខ្មែរ អាចមិនបញ្ចប់ទាន់ពេលវេលា។

៦- ជាការបន្ថែម អនុលោមតាមមាត្រា ៥.៤ នៃសេចក្តីណែនាំអនុវត្តជាធរមាន សហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំសហចៅក្រមស៊ើបអង្កេត ដើម្បីបន្ថែមចំនួនទំព័រកំណត់សម្រាប់សេចក្តីសន្និដ្ឋានបន្ថែមនេះត្រឹម ១៦ទំព័រ។ ខ្លឹមសារនៃសំណើសុំមានការពាក់ព័ន្ធទៅនឹងផលប្រយោជន៍ផ្លូវច្បាប់ខុសៗគ្នាទាំងជនសង្ស័យ និងទាំងសហមេធាវីចាត់តាំង ទាំងសហព្រះរាជអាជ្ញា និងទាំងការទទួលខុសត្រូវផ្នែកស្ថាប័នដ៏ទូលាយនៅក្នុងការការពារចំពោះការគ្រប់គ្រងយុត្តិធម៌ឲ្យបានល្អ។ ការដាក់សេចក្តីសន្និដ្ឋានគ្រប់គ្រាន់ ស្តីពីទំនាស់ផលប្រយោជន៍លើសំណុំរឿងពាក់ព័ន្ធនឹងជនជាប់ចោទពីរនាក់ គឺកូនក្តីបច្ចុប្បន្នម្នាក់ និងកូនក្តីដែលបានទទួលមរណភាពម្នាក់ ហើយនឹងការជាប់ទាក់ទងទៅនឹងមេធាវី

[10] សេចក្តីណែនាំអនុវត្ត អវតក/២០០៧/១/វិសោធនកម្មលើកទី៨ “ការដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះ” (៧ មីនា ២០១២)។

[11] វិធាន៣២*ស្ទួន* នៃវិធានផ្ទៃក្នុង។

ដែលស្ថិតនៅក្រោមក្រមសីលធម៌នៃករណីកិច្ចទ្វេរដង ចាំបាច់តម្រូវឲ្យមានការវិភាគពីប្រភពច្បាប់នានាចេញពីយុត្តិសាស្ត្រជាតិ និងអន្តរជាតិជាច្រើន ព្រមទាំងការពិនិត្យឡើងវិញលើសំណុំអង្គហេតុ និងអង្គហេតុនៃការចោទប្រកាន់នានា។ រាល់កិច្ចប្រឹងប្រែងទាំងអស់ត្រូវបានធ្វើឡើងដើម្បីកម្រិតពីប្រវែងនៃការធ្វើអំណះអំណាងផ្លូវច្បាប់ - ដោយធ្វើយ៉ាងណាឲ្យសាមញ្ញ និងត្រង់ៗ - ដើម្បីកាត់បន្ថយឲ្យបានជាអប្បបរមានៅក្នុងកាលៈទេសពិសេសទាំងនេះ។ បើសិនជាសំណើសុំការអនុញ្ញាតដើម្បីបន្ថែមចំនួនទំព័រនេះពុំត្រូវបានផ្តល់ជូនទេ នោះសហព្រះរាជអាជ្ញាអន្តរជាតិសូមស្នើសុំពេលមួយ (០១)ថ្ងៃនៃថ្ងៃធ្វើការ ដើម្បីអនុវត្ត និងដាក់ជូនឡើងវិញ។

## III. **ច្បាប់ជាសារវន្ត**

### ១. កាតព្វកិច្ចរបស់មេធាវីការពារក្តីចំពោះកូនក្តីបច្ចុប្បន្ន កូនក្តីអតីតកាល និងកូនក្តីដែលបានស្លាប់

៧- ***មេធាវីការពារក្តីនៅចំពោះមុខ អ.វ.ត.ក មានកាតព្វកិច្ចក្នុងនាមជាអ្នកកាន់មុខតំណែងជាទីទុកចិត្តក្នុងកម្រិតខ្ពស់បំផុតចំពោះកូនក្តីរបស់ខ្លួន។*** សហមេធាវីទាំងជាតិ និងអន្តរជាតិ ត្រូវមានកាតព្វកិច្ចនៅក្រោមក្រមសីលធម៌នៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ("BAKC") ព្រមទាំងអាចត្រូវដាក់ឲ្យជាប់ក្រោមវិធានផ្សេងៗរបស់បណ្តាយុត្តាធិការដទៃទៀត[12]។ វិធាន២២(៤)នៃវិធានផ្ទៃក្នុង ដាក់មេធាវីការពារក្តីនៅក្រោម "បទដ្ឋាន និងក្រមសីលធម៌វិជ្ជាជីវៈដែលបានទទួលស្គាល់"។ ការណ៍នេះរួមបញ្ចូលទាំង "ភារកិច្ចរបស់ជនដែលកាន់តំណែងជាទីទុកចិត្ត"[13] ដែលមានលក្ខណៈពង្រីកចំពោះកូនក្តី ដែលជាភារកិច្ចដើម្បីបំពេញកិច្ចជាផលប្រយោជន៍ដ៏ល្អបំផុតជាទីទុកចិត្តនៃកូនក្តី នៅគ្រប់ពេលវេលាទាំងអស់[14]។ "ចំណុចខ្ពស់បំផុត"[15] នៃភារកិច្ចរបស់ជនដែលកាន់តំណែងជាទីទុកចិត្ត - *សុចរិតឥតខ្ចោះ* - រួមបញ្ចូលទាំង ភារកិច្ចចំពោះការសម្ងាត់[16] ភាពស្មោះត្រង់[17] ជំនាញត្រឹមត្រូវ[18] ភាពប្រុងប្រយ័ត្នហ្មត់ចត់[19] សច្ចភាព[20] និងការលាតត្រដាងបង្ហាញជូនចំពោះកូនក្តី[21]។

---

[12] វិធាន២២(៤) នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៨)។

[13] *Strother ទល់នឹង 3464920 Canada Inc.* [២០០៧] SCC 24 (តុលាការកំពូលប្រទេសកាណាដា)។

[14] ក្រមសីលធម៌ស្តីពីសិទ្ធិអំណាចតាមបទបញ្ជាផ្ទៃក្នុងរបស់មេធាវី (Code of Conduct of the Solicitors Regulation Authority) (អង់គ្លេស និងវេលស្ស), គោលការណ៍ទី៤ (រៀបរាប់គោលការណ៍ចាប់បង្ខំ១០ចំណុច ថាជា "មានការសោយភាយទាំងអស់... អនុវត្តចំពោះអ្វីទាំងអស់ដែលយើងបញ្ញត្តិ និងទិដ្ឋភាពទាំងអស់នៃទម្លាប់អនុវត្ត")។

[15] David Beck, ការផ្តោះផ្តួយផ្នែកច្បាប់ នៅតិចសាស (បោះពុម្ពលើកទី២), 50 Baylor L.Rev. 550,607 (១៩៩៨)។

[16] ក្រមសីលធម៌នៃព្រះរាជាណាចក្រកម្ពុជា, ក្រមសីលធម៌សម្រាប់មេធាវីដែលបានចុះបញ្ជី, ១៥ វិច្ឆិកា ១៩៩៥ ត្រង់មាត្រា៧។

[17] *ឯកសារដែលដូចខាងលើ,* មាត្រា៧។ ដដែលដូចខាងលើ។ គណៈមេធាវីអន្តរជាតិ ("គោលការណ៍នៃ IBA"), គោលការណ៍អន្តរជាតិស្តីពីក្រមសីលធម៌វិជ្ជាជីវៈច្បាប់ (២០១១)។ ក្រុមប្រឹក្សាសង្គមគណៈមេធាវី និងច្បាប់នៃក្រមសីលធម៌អឺរ៉ុប ("CCBE")។ Spincode Pty. Ltd. ទល់នឹង Look Software Pty. Ltd. [២០០១] VSCA 248។ Bolkiah ទល់នឹង K.P.M.G., សភាជាន់ខ្ពស់, ១៨ ធ្នូ ១៩៩៨។

៨- ***កាតព្វកិច្ចចំពោះការសម្ងាត់ពង្រីកហួសពីមរណភាពរបស់កូនក្តី។*** តាមក្រមសីលធម៌របស់ BAKC មេធាវីត្រូវ "ប្រកាន់ឲ្យបានខ្ជាប់ខ្ជួនដាច់ខាត"[22] នូវការសម្ងាត់វិជ្ជាជីវៈ។ ភារកិច្ចនេះពង្រីករហូតដល់កូនក្តីដែលបានស្លាប់ ស្របតាមក្រមសីលធម៌ដែលបានអនុម័តនៅទូទាំងទ្វីបអឺរ៉ុប[23] ប្រទេសអូស្ត្រាលី[24] អង់គ្លេស និងវ៉េលស្ស[25] រួមទាំងដែនសមត្ថកិច្ចជាច្រើនទៀតនៃតុលាការកំពូល (សហរដ្ឋអាមេរិក)[26]។

៩- ក្រមសីលធម៌ស្តីពីសិទ្ធិអំណាចតាមបទបញ្ជាផ្ទៃក្នុងរបស់មេធាវី ក្នុងដែនសមត្ថកិច្ចនៃប្រទេសអង់គ្លេស និងវ៉េល មានលក្ខណៈជាសេចក្តីណែនាំពិសេស ជាក្រមសីលធម៌វិជ្ជាជីវៈថ្មីមួយដែលត្រូវបានអនុម័ត និងអនុវត្តដោយស្ថាប័ននិយតកម្មឯករាជ្យមួយដែលបំពេញមុខងារដាច់ពីស្ថាប័នមេធាវីវិជ្ជាជីវៈ។ ក្រមនេះចែងថា៖ "ការការពារព័ត៌មានសម្ងាត់ គឺជាទម្រង់មូលដ្ឋាននៃការធ្វើទំនាក់ទំនងរបស់អ្នកជាមួយកូនក្តី។ វាជាអត្ថិភាពនៃគំនិតមួយដែលពាក់ព័ន្ធទាំងបញ្ហាច្បាប់ និងបញ្ហានៃអំពើប្រព្រឹត្តិ។ ករណីយកិច្ចនេះនៅមានជាបន្ត បើទោះបីជាអ្នកថែរក្សាត្រូវបានបញ្ចប់ និង<u>សូម្បីតែនៅក្រោយមរណភាពរបស់កូនក្តីក៏ដោយ</u>"[27]។

១០- ក្នុងលក្ខខណ្ឌស្រដៀងគ្នានេះដែរ ដែនសមត្ថកិច្ចរបស់តុលាការចុងក្រោយនៅឯស្រុកកំណើតរបស់លោក Karnavas បានបញ្ជាក់អះអាងថា កាតព្វកិច្ចរបស់មេធាវីចំពោះការសម្ងាត់នៅរស់រានមានជីវិតនៅក្រោយមរណភាពរបស់កូនក្តី ទោះបីជានៅក្នុងបរិបទជាក់លាក់នៃកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌណាមួយក៏ដោយ។ ក្នុងរឿងក្តី *Swindler ទល់នឹងសហរដ្ឋ (១៩៩៨)* តុលាការកំពូល

---

[18] សង្គមច្បាប់នៃរដ្ឋញូសោតវ៉ាល់នៃប្រទេសអូស្ត្រាលី (The Law Society of New South Wales of Australia), ក្រមសីលធម៌វិជ្ជាជីវៈ និងវិធានអនុវត្ត ១៩៩៥ ដែលបានកែសម្រួលឡើងវិញ ("ក្រមសីលធម៌វិជ្ជាជីវៈ និងវិធានអនុវត្តដែលបានកែសម្រួលឡើងវិញនៃរដ្ឋញូសោតវ៉ាល់"), មាត្រា១.១។

[19] *ឯកសារដដែលដូចខាងលើ។*

[20] *Employers Cas. Co. ទល់នឹង Tilley*, 496 S.W.2d 948,506, 1973។

[21] *Willis ទល់នឹង Maverick*, 760 S.W.2d 642,645, 1988។

[22] គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា, កំណត់សម្គាល់*ខាងដើម*លេខ១៦ ត្រង់កថាខណ្ឌទី៧។

[23] CCBE, កំណត់សម្គាល់*ខាងដើម*លេខ១៧។

[24] ក្រមសីលធម៌វិជ្ជាជីវៈ និងវិធានអនុវត្តដែលបានកែសម្រួលឡើងវិញនៃរដ្ឋញូសោតវ៉ាល់, កំណត់សម្គាល់*ខាងដើម*លេខ១៨។

[25] Solicitors Regulation Authority Code of England and Wales ("SRA"), 1 Jan 2013, Ch. 4។

[26] *Swindler ទល់នឹងសហរដ្ឋ* 524 U.S. 399; 118 S. Ct. 2081(1998)។

[27] SRA, កំណត់សម្គាល់*ខាងដើម*លេខ២៧ ត្រង់កថាខណ្ឌទី២។

(សហរដ្ឋ) បានអះអាងថា ករណីកិច្ចរបស់មេធាវីចំពោះការសម្ងាត់នៅមានជាបន្ត នៅក្រោយមរណភាពរបស់កូនក្តី។ ជាពិសេស តុលាការបានលើកយោងទៅរកការប្រាស្រ័យទំនាក់ទំនងដែលត្រូវរក្សាជាការសម្ងាត់ ដោយមានការយល់ដឹងថា ព័ត៌មានដែលនឹងរក្សាបាននូវការសម្ងាត់ នឹងជួយលើកកម្ពស់ដល់ការលាតត្រដាងរបស់កូនក្តីទៅឲ្យមេធាវី។ អាស្រ័យហេតុនេះ "ខណៈដែលមានការភ័យខ្លាចចំពោះការលាតត្រដាង និងការដកយកជាយថាហេតុនូវព័ត៌មានទាំងនោះពីមេធាវីវិញ អាចត្រូវបានកាត់បន្ថយ ប្រសិនបើការលាតត្រដាងត្រូវបានកម្រិតត្រឹមការលាតត្រដាងបច្ឆាមរណៈនៅក្នុងបរិបទព្រហ្មទណ្ឌ វាហាក់ដូចជាមិនសមហេតុផលដែលសន្មតថា វានឹងរលាយបាត់សូន្យជាមួយគ្នានោះឡើយ។ កូនក្តីអាចមានកង្វល់អំពីកេរ្តិ៍ឈ្មោះ ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ឬលទ្ធភាពគ្រោះថ្នាក់ចំពោះមិត្តភក្តិ ឬក្រុមគ្រួសារ។ ការលាតត្រដាងបច្ឆាមរណៈអំពីការប្រាស្រ័យទំនាក់ទំនងដូច្នេះ អាចត្រូវបានខ្លាចថា ជាការលាតត្រដាងនៅក្នុងអំឡុងនៃខ្សែជីវិតទាំងមូលរបស់កូនក្តី"[28]។

១១- ***ភាតព្វកិច្ចចំពោះការសម្ងាត់នេះ មានវិសាលភាពលើព័ត៌មានទាំងអស់ទាក់ទងនឹងការការពារ ហើយមិនអាចលះបង់សិទ្ធិដោយកូនក្តីបានឡើយតាមច្បាប់កម្ពុជា។*** តាមក្រមសីលធម៌ BAKC "ការសម្ងាត់នេះមិនត្រូវអាចឲ្យជនណាម្នាក់ស្រង់យកបានឡើយ ទោះបីជាអតិថិជនក៏ដោយ"[29]។ ការលើកលែងចំពោះករណីកិច្ចចំពោះការសម្ងាត់ ខុសគ្នានៅគ្រប់ដែនសមត្ថកិច្ច - ជាឧទាហរណ៍ ដើម្បីជាប្រយោជន៍នៃសុវត្ថិភាពសាធារណៈ ឬក្នុងដំណើរការនៃវិវាទដែលកូនក្តីប្រឆាំងនឹងមេធាវីជាដើម - ប៉ុន្តែកាលៈទេសៈដូច្នេះ នៅមានកម្រិតតិចតួចមិនជាប់ពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីបច្ចុប្បន្ននេះទេ។ គោលការណ៍អន្តរជាតិស្តីពីក្រមសីលធម៌សម្រាប់អ្នកប្រកបវិជ្ជាជីវៈច្បាប់របស់គណៈមេធាវីអន្តរជាតិ (២០១១) បង្កើតនូវក្របខណ្ឌដែលមានការទទួលស្គាល់ជាទូទៅមួយ ដើម្បីជូនដំណឹងទៅដល់ក្រមសីលធម៌ក្នុងស្រុក[30] ហើយមានលក្ខណៈជាការណែនាំទាក់ទងដល់ចំណុចនេះ ដូចមានចែងខាងក្រោម ៖

> *ភារកិច្ចដែលមានចែងក្រមសីលធម៌របស់មេធាវីចំពោះការសម្ងាត់ ហាមឃាត់មេធាវីពីការបង្ហាញ<u>ព័ត៌មានទាក់ទងនឹងការធ្វើតំណាងឲ្យ ឬការផ្តល់យោបល់ដល់កូនក្តីណាម្នាក់ពីប្រភពណាមួយក៏ដោយ</u> មិនមែនគ្រាន់តែការប្រាស្រ័យទំនាក់ទំនងគ្នារវាងមេធាវី និងកូន*

[28] *Swindler ទល់នឹង United States*, កំណត់សម្គាល់*ខាងដើម* លេខ២៦។

[29] គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា, កំណត់សម្គាល់*ខាងដើម* លេខ១៦ ត្រង់កថាខណ្ឌទី៧។

[30] គោលការណ៍របស់ IBA, កំណត់សម្គាល់*ខាងដើម* លេខ១៧ ត្រង់ទំព័រ៥។

*ក្ដីប៉ុណ្ណោះទេ ហើយក៏តម្រូវឱ្យមេធាវីការពារព័ត៌មាននោះកុំឱ្យលេចចេញទៀតផង។ គោលការណ៍នៃ ការសម្ងាត់មានវិសាលភាពធំជាងបុព្វសិទ្ធិវិជ្ជាជីវៈផ្លូវច្បាប់ទៅទៀត។ បញ្ហាដែលត្រូវបានការពារដោយបុព្វសិទ្ធិវិជ្ជាជីវៈច្បាប់ ក៏ត្រូវបានការពារដោយគោលការណ៍នៃការសម្ងាត់ផងដែរ ប៉ុន្តែបើនិយាយផ្ទុយពីនេះ មិនមែនជាការពិតទេ[31]។*

១២- ដូច្នេះ គ្រប់ព័ត៌មានទាំងអស់ដែលត្រូវបានការពារដោយបុព្វសិទ្ធិវិជ្ជាជីវៈច្បាប់ ក៏នឹងត្រូវបានការពារដោយគោលការណ៍នៃការសម្ងាត់ផងដែរ។ នៅក្នុងយុត្តាធិការដែលបានទទួលស្គាល់បុព្វសិទ្ធិវិជ្ជាជីវៈច្បាប់ជាវិធាននៃភ័ស្តុតាង បុព្វសិទ្ធិនេះក៏នៅមានជាបន្តនៅក្រោយមរណភាពរបស់កូនក្ដី។ ឧទាហរណ៍ ក្រមភ័ស្តុតាងនៅក្នុងយុត្តាធិការនៃរដ្ឋកាលីហ្វកញ៉ា (សហរដ្ឋអាមេរិក) ថា៖ ម្ចាស់នៃ "បុព្វសិទ្ធិរវាងមេធាវី និងកូនក្ដី" គឺ "តំណាងផ្ទាល់នៃកូនក្ដីនោះ ទោះបីជាកូនក្ដីនោះបានស្លាប់ហើយក៏ដោយ[32]។

១៣- ***កាតព្វកិច្ចនៃការរក្សាការសម្ងាត់ចំពោះកូនក្ដីដែលបានទទួលមរណភាព ចំពោះបញ្ហាដែលពាក់ព័ន្ធណាមួយ នឹងមានផលប៉ះពាល់ជាចាំបាច់ទៅលើករណីយកិច្ចនៃភាពស្មោះត្រង់ ហើយអាចប៉ះពាល់ទៅដល់កាតព្វកិច្ចផ្សេងទៀតដែលមានចំពោះកូនក្ដីបច្ចុប្បន្ន។*** ករណីយកិច្ចរបស់មេធាវីចំពោះការសម្ងាត់ចំពោះកូនក្ដីដែលបានស្លាប់ ក៏បានបង្កើតនូវ "តំបន់គ្រោះថ្នាក់" សម្រាប់ការអនុវត្តកាតព្វកិច្ចចំពោះភាពស្មោះត្រង់ដោយសេរីដែលខ្លួនមានចំពោះកូនក្ដីបច្ចុប្បន្ន ក្នុងបញ្ហាណាមួយដែលពាក់ព័ន្ធ។ ដូចបានថ្លែងដោយតុលាការឧទ្ធរណ៍នៃរដ្ឋកាលីហ្វកញ៉ា (សហរដ្ឋអាមេរិក) ថា៖ "កូនក្ដីមានសិទ្ធិទទួលបានស្នាក្ដីតំណាងដែលស្វាហាប់ និងដាច់ខាត។ គេពិបាកជឿថា មេធាវីម្នាក់ដែលមានការព្យាយាមយ៉ាងហ្មត់ចត់ ដើម្បីបញ្ចៀសនូវការលាតត្រដាងទំនុកចិត្តរបស់អតីតកូនក្ដីរបស់ខ្លួន - មានន័យថាអ្នកដែលខំប្រឹងប្រែងគ្រប់បែបយ៉ាងដើម្បីគេចចេញពីតំបន់គ្រោះថ្នាក់នេះ - អាចផ្ដល់នូវប្រភេទនៃភាពស្មោះត្រង់ដែលមិនអាចបែងចែកបាន ដែលកូនក្ដីមានសិទ្ធិគ្រប់យ៉ាងក្នុងការសង្ឃឹមទុក និងដែលប្រព័ន្ធច្បាប់របស់យើងមានតម្រូវការនោះឡើយ[...]"[33]។ ជាការបន្ថែម ភារកិច្ចចំពោះភាពស្មោះត្រង់ ដែលជាបុរេអត្ថិភាពមួយចំពោះអតីតកូនក្ដីណាម្នាក់ នឹងមានផលប៉ះពាល់ជាចាំបាច់ទៅលើកាតព្វកិច្ចដទៃទៀត ដែលហួរចេញពីភារកិច្ចរបស់ជនដែលកាន់តំណែងជាទីទំនុកចិត្ត ទៅលើកូនក្ដី

[31] IBA, សេចក្ដីអធិប្បាយអំពីគោលការណ៍អន្តរជាតិ IBA ស្ដីពីក្រមសីលធម៌វិជ្ជាជីវៈច្បាប់ (២០១១) ត្រង់ទំព័រទី៣៣ [សង្កត់ន័យដោយអក្សរទ្រេត]។

[32] ក្រមភ័ស្តុតាង (កាលីហ្វកញ៉ា), s. 953

[33] *Goldstein ទល់នឹង Lees* (១៩៧៥) 46 Cal.App.3d 614, 620,

បច្ចុប្បន្ន ដូចជាកាតព្វកិច្ចចំពោះជំនាញត្រឹមត្រូវ និងភាពហ្មត់ចត់។ ការណ៍នេះមានភស្តុតាងបញ្ជាក់ស្រាប់នៅក្នុងសេចក្តីសន្និដ្ឋានផ្សេងៗនៃសេចក្តីអត្ថាធិប្បាយរបស់អ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ និងទាំងនៅក្នុងករណីយុត្តិសាស្ត្រពាក់ព័ន្ធនៅក្នុងដែនសមត្ថកិច្ចនៃរដ្ឋកាលីហ្វកញ៉ា (សហរដ្ឋអាមេរិក) ដែលក្នុងកាលៈទេសៈដូច្នេះ លទ្ធភាពរបស់មេធាវីត្រូវបានកាត់បន្ថយក្នុងការផ្តល់ជូនកូនក្តីបច្ចុប្បន្ននូវ “ការវិនិច្ឆ័យវិជ្ជាជីវៈរបស់មេធាវី... ចាកផុតពីឥទ្ធិពលនៃការសម្រុះសម្រួល”[34]។

១៤- ***កាតព្វកិច្ចស្តីពីភាពស្មោះត្រង់ត្រូវនៅបន្តហួសពីមរណភាពរបស់កូនក្តីតទៅទៀត***។ ភារកិច្ចចំពោះភាពស្មោះត្រង់ ត្រូវបានរៀបរាប់យ៉ាងច្បាស់ដោយតុលាការនានានៅក្នុងរដ្ឋ Victoria (ប្រទេសអូស្ត្រាលី) ថាជា “ភារកិច្ចមួយដែលមិនត្រូវដាក់ខ្លួនក្នុងគោលជំហរណាមួយ ដែលនាំឲ្យជនដែលកាន់តំណែងជាទីទំនុកចិត្ត (the fiduciary) ត្រូវមានភារកិច្ចចំពោះកូនក្តីម្នាក់ ដែលខុសគ្នាពីភារកិច្ចចំពោះកូនក្តីម្នាក់ផ្សេងទៀត”[35]។ មូលវិចារណ៍ចំពោះវិធានគំរូនៃក្រមសីលធម៌វិជ្ជាជីវៈរបស់គណៈមេធាវីអាមេរិកកាំង, វិធាន១.៧ បានសង្កត់ន័យថា “ភាពស្មោះត្រង់គឺជាទិដ្ឋភាពមួយដ៏សំខាន់បំផុតក្នុងចំណោមទិដ្ឋភាពនានានៃទំនាក់ទំនងរបស់មេធាវីការពារក្តីជាមួយនឹងកូនក្តីរបស់ខ្លួន”។ ដូច្នេះ នៅក្នុងឧទាហរណ៍នៃរដ្ឋ California (សហរដ្ឋអាមេរិក) វាគឺជាការបំពានមួយលើភារកិច្ចនោះ ចំពោះមេធាវីការពារក្តីណាម្នាក់ដែលបានប្រកាន់យកគោលជំហរដែលផ្ទុយ ឬដែលប្រឆាំងនឹងកូនក្តីបច្ចុប្បន្ន[36] និងទាំងកូនក្តីពីមុន[37]។ តុលាការកំពូលនៃរដ្ឋ Illinois (សហរដ្ឋអាមេរិក) បានសម្រេចយ៉ាងជាក់ច្បាស់ថា ភារកិច្ចស្តីពីភាពស្មោះត្រង់របស់មេធាវីការពារក្តីធ្វើឲ្យមរណភាពរបស់កូនក្តីរស់រានមានជីវិតឡើងវិញ[38]។ ដូច្នេះ ភារកិច្ចស្តីពីភាពស្មោះត្រង់ចំពោះកូនក្តី ដែលបានទទួលមរណភាព រារាំងដល់មេធាវីការពារក្តីមិនឲ្យធ្វើជាអ្នកការពារឲ្យផលប្រយោជន៍ណា ដែលមានលក្ខណៈផ្ទុយ[39]។

---

[34] Steven J. Hyman, ការការពាររួមឲ្យកូនក្តីច្រើននាក់នៅក្នុងសវនាការព្រហ្មទណ្ឌមួយ: The Court's Headache (ការឈឺក្បាលរបស់តុលាការ) (1977) 5 Hofstra L.Rev. 315 ត្រង់ 334, លើកយោងដោយមានការយល់ព្រមក្នុងរឿងក្តី *People ទល់នឹង Mroczko* 35 Cal.3d. 86, 112។

[35] Spincode, កំណត់សម្គាល់ *ខាងលើ* លេខ១៧។

[36] Day ទល់នឹង Rosenthal (1985) 170 Cal.App.3d 1125, 1143, ដោយបានដកស្រង់ Betts ទល់នឹង Allstate, Ins. Co. (1984) 154 Cal.App.3d 688, 714។

[37] David Welch Co. ទល់នឹង Erskin & Tulley (1988) 203 Cal.App.3d 884, 891។ Kallen ទល់នឹង Delug (1984) 157 Cal.App.3d 940, 950-951។

[38] នៅក្នុង យោង Michal, 415 Ill. 150, 112 N.E.2d 603 (1953)។

[39] នៅក្នុង យោង Williams, 57 Ill.2d 63, 309 N.E.2d 579 (1974)។

១៥- ***ភារកិច្ចស្តីពីភាពស្មោះត្រង់ ធ្វើឱ្យភាពចប់នៃទំនាក់ទំនងមេធាវី-កូនក្តី មានឥស្សរភាពរស់ឡើងវិញ ដោយមិនគិតថាតើមេធាវីការពារក្តីរូបនោះបានទទួលនូវឯកសារព័ត៌មានសម្ងាត់ ចំពោះកូនក្តីបច្ចុប្បន្ន ឬយ៉ាងណានោះឡើយ***។ កូនក្តីម្នាក់ៗមានសិទ្ធិទទួលបាន និងមានសិទ្ធិសន្មតថា ជនដែលកាន់តំណែងជាទីទំនុកចិត្ត (the fiduciary) គាត់បានជាប់ទាក់ទិននឹងភាពស្មោះត្រង់ដែលមិនអាចបែងចែកបាន[40]។ "ភាពស្មោះត្រង់ដែលមិនអាចបែងចែកបាន" នេះ ដាក់ស្ម័យកាតព្វកិច្ចមិនផ្លាស់ប្តូរទៅលើមេធាវី ដោយមិនគិតថាតើមានព័ត៌មានសម្ងាត់ណាមួយ ដែលទាក់ទងនឹងការធ្វើតំណាងជាបន្តបន្ទាប់ក្រោយៗមកទៀត ដែលអាចឱ្យគេទទួលបានក្នុងដំណើរការនៃការធ្វើជាតំណាងកាលពីមុននោះឡើយ។ របកគំហើញនេះត្រូវបានគេគាំទ្រនៅពាសពេញទាំងយុត្តាធិការជាច្រើន ដោយរួមទាំងយុត្តាធិការក្នុងប្រទេសកំណើតរបស់លោក Karnavas ផង។ ក្នុងចំណោមឧទាហរណ៍ដទៃ ទៀត មានសាលាឧទ្ធរណ៍នៃរដ្ឋ Ontario[41] (ប្រទេសកាណាដា), សាលាឧទ្ធរណ៍របស់តុលាការជាន់ខ្ពស់នៃរដ្ឋ Victoria[42] (ប្រទេសអូស្ត្រាលី), សាលាឧទ្ធរណ៍ក្នុងប្រទេស Columbia[43] និងតុលាការនៅតាមរដ្ឋនៃសហរដ្ឋ[44] (សហរដ្ឋអាមេរិក) ជាដើម ដែលតុលាការ នីមួយៗនេះធ្លាប់បានសម្រេចថា ភារកិច្ចស្តីពីភាពស្មោះត្រង់នៃការកាន់តំណែងជាទីទំនុកចិត្តរបស់មេធាវីការពារក្តី ធ្វើឱ្យភាពចប់នៃទំនាក់ទំនងមេធាវី-កូនក្តី រស់រានមានជីវិតឡើងវិញ ដោយមិនគិត ថាតើព័ត៌មានសម្ងាត់ដែលទាក់ទងនឹងការធ្វើតំណាងឱ្យអតីតកូនក្តីណាម្នាក់ ពិតជាត្រូវបានលាតត្រដាងឱ្យកូនក្តីបន្ទាប់ ដែរឬអត់នោះឡើយ។

១៦- ***ប្រព័ន្ធច្បាប់ស៊ីវិលបានទទួលស្គាល់ថា សេចក្តីថ្លៃថ្នូរ កេរ្តិ៍ឈ្មោះ កិត្តិយស និងភាពឯកជន របស់មរណជន គឺជាសិទ្ធិដែលអាចដោះស្រាយតាមផ្លូវច្បាប់បាន ដែលបានផ្តល់ដាច់ណាត់ឱ្យទៅទាយាទ*** ។ ដូចគ្នានឹងមេធាវីត្រូវមានភារកិច្ចស្តីពីការរក្សាការសម្ងាត់ និងភាពស្មោះត្រង់ជាបន្តទៀត ចំពោះអតីតកូនក្តីដែលបានទទួលមរណភាព ដូចនេះដែរ គឺច្បាប់យុត្តិសាស្ត្រទាំងថ្នាក់ជាតិ និងទាំងថ្នាក់អន្តរជាតិបានគាំទ្រនូវគោលជំហរដែលថា ទាយាទនៃមរណជនមានមូលដ្ឋានតាមផ្លូវច្បាប់ ដើម្បីស្វែងរកកិច្ចការពារចំពោះសេចក្តីថ្លៃថ្នូរ កេរ្តិ៍ឈ្មោះ និងកិត្តិយសរបស់មរណជន ក៏ដូចជា សិទ្ធិបុគ្គលដែលមានកម្រិតមួយចំនួនទៀត ក្នុងពេលប្រឈមមុខនឹងការរំលោភជាសក្តានុពល ឬយ៉ាងជាក់ស្តែង។ នៅក្នុង

[40] Spincode, កំណត់សម្គាល់*ខាងលើ* លេខ១៧។

[41] *ដដែលដូចមុន*។

[42] *ដដែលដូចមុន*។

[43] *ដដែលដូចមុន*។

[44] *ដដែលដូចមុន*។

រឿងក្តី *Swindler* តុលាការកំពូល (សហរដ្ឋអាមេរិក) បានទទួលស្គាល់ពីកង្វល់ស្របតាមច្បាប់របស់កូនក្តី ដែលកំពុងប្រឈមមុខនឹងការស៊ើបអង្កេតរបស់សភាជាន់ខ្ពស់ ដោយមានការប៉ះពាល់ជាសក្តានុពលដល់កេរ្តិ៍ឈ្មោះរបស់គាត់ ឬរបស់មិត្តភក្តិ និងគ្រួសារ នៅក្រោយពេលមរណភាព[45]។ ប្រព័ន្ធច្បាប់ស៊ីវិល រួមទាំង ប្រទេសអាល្លឺម៉ង់ និងបារាំងផង បានទទួលស្គាល់ថា ផលប្រយោជន៍តាមផ្លូវច្បាប់ចំពោះសេចក្តីថ្លៃថ្នូរ ដែលមិនអាចរំលោភបានរបស់មរណជន (ប្រទេសអាល្លឺម៉ង់) និងកេរ្តិ៍ឈ្មោះ កិត្តិយស និងភាពឯកជន (ប្រទេសបារាំង) របស់មរណជន គឺជាសិទ្ធិដែលអាចដោះស្រាយតាមផ្លូវច្បាប់បាន និងដែលបានផ្តល់ឲ្យដាច់ណាត់ទៅទាយាទរបស់បុគ្គលនោះ[46]។

១៧- នៅក្នុងករណីដំបូងនៃរឿងក្តី *Mephisto* (ឆ្នាំ១៩៧៧) នៅចំពោះមុខតុលាការធម្មនុញ្ញសហព័ន្ធ (*Bundesverfassungsgericht,* ប្រទេសអាល្លឺម៉ង់) អ្នកដាក់ពាក្យប្តឹងសុំឲ្យពិនិត្យធម្មនុញ្ញភាពឡើងវិញចំពោះអធិបញ្ញាមួយដែលរារាំងដល់ការបោះពុម្ព ការចែកចាយ និងការបោះពុម្ពផ្សាយសៀវភៅប្រលោមលោកមួយក្បាលដែលអ្នកឆ្លើយនឹងសំណួរបានចោទថាមានផ្ទុកទៅដោយ "រូបភាពក្លែងក្លាយ និងមានលក្ខណៈមាក់ងាយយ៉ាងខ្លាំង" អំពីមរណជនដែលត្រូវជាឪពុករបស់អ្នកឆ្លើយនឹងសំណួរនោះ។ ខណៈដែលមានការរកឃើញថា សិទ្ធិចំពោះបុគ្គលភាព (តាមផ្លូវច្បាប់) ត្រូវផុតរលត់នៅពេលចូលមរណភាព នោះតុលាការបានពង្រីកកាតព្វកិច្ចរបស់រដ្ឋឲ្យការពារសិទ្ធិចំពោះសេចក្តីថ្លៃថ្នូររបស់មរណជន ដោយសម្រេចថា "ជាការមិនស្របគ្នាទៅនឹងអាណត្តិរដ្ឋធម្មនុញ្ញដែលចែងអំពីភាពមិនអាចរំលោភបានចំពោះសេចក្តីថ្លៃថ្នូររបស់មនុស្ស ដែលកំណត់អំពីសិទ្ធិជាមូលដ្ឋានទាំងអស់ បើសិនជាបុគ្គលម្នាក់អាចត្រូវបានគេមាក់ងាយ និងបន្តុះបង្អាប់នៅក្រោយពីមរណភាពនោះឡើយ"[47] សំអាងហេតុក្នុងរឿងក្តី *Mephisto* ត្រូវបានយកទៅអនុវត្តដោយតុលាការ ជាន់ខ្ពស់សហព័ន្ធ (*Bundesgerichtshof*) នៅ *Dietrich* (ឆ្នាំ១៩៩៩) ដែលនៅទីនោះ តុលាការបានសម្រេចថា "ស្រទាប់ពាណិជ្ជកម្ម" នៃសិទ្ធិបុគ្គលត្រូវបានផ្ទេរ ឬផ្តល់មរតកតាមច្បាប់រដ្ឋប្បវេណី ទោះបីមិនដូចអាជ្ញាបញ្ញាធម្មនុញ្ញក៏ដោយ ចំណែកឯសិទ្ធិសីលធម៌សុទ្ធសាធ គឺមិនមានឡើយ[48]។

---

[45] *Swindler ទល់នឹង សហរដ្ឋ*, កំណត់សម្គាល់*ខាងលើ* លេខ២៦។

[46] យ៉ាងណាក៏ដោយ ប្រព័ន្ធច្បាប់ common law រួមទាំងរដ្ឋចំនួន ២៨ របស់សហរដ្ឋអាមេរិក និងប្រទេស Jamaica ផង ក៏បានពន្លាតដែនកម្រិតនៃការការពារផ្នែកច្បាប់ទៅដល់សិទ្ធិខាងពាណិជ្ជកម្មរបស់បុគ្គល (ឬ "សិទ្ធិស្តីពីការផ្សាយជាសាធារណៈ") នៅក្រោយពេលមរណភាពរបស់បុគ្គលដែលពាក់ព័ន្ធ។

[47] Mephisto, BVerfGE 30, 173 (២៤ កុម្ភៈ ១៩៧៧) ត្រង់កថាខណ្ឌ៦។

[48] Mephisto, 1 ZR 49/97, Entscheidungen des BGH in Zivilsachen, ១ ធ្នូ ១៩៩៩, ១៤៣, ២១៤។

១៨- នៅក្នុងរឿងក្តី *Éditions Plon ទល់នឹង ប្រទេសបារាំង* (ឆ្នាំ២០០៤) តុលាការសិទ្ធិមនុស្សអឺរ៉ុប បានទទួលស្គាល់ថាជាការស្របច្បាប់នូវអធិបញ្ញាបណ្តោះអាសន្នមួយ ហាមឃាត់មិនឱ្យចែកចាយសៀវភៅមួយ ស្តីពីស្ថានភាពវេជ្ជសាស្ត្រ និងការព្យាបាលសពអតីតប្រធានាធិបតីបារាំង, លោក François Mitterand, ដែលនិពន្ធដោយវេជ្ជបណ្ឌិតព្យាបាលគាត់ ដែល*មួយក្រឡេកមើល (prima facie)* បានបំពានលើបទប្បញ្ញត្តិនានានៃក្រមនីតិវិធីព្រហ្មទណ្ឌ និងកាតព្វកិច្ចនៃក្រមសីលធម៌វិជ្ជាជីវៈស្តីពីការសម្ងាត់វេជ្ជសាស្ត្រ[49]។ ច្បាប់បារាំង[50] ច្បាប់កម្ពុជា[51] និងក្រមរបស់ BAKC[52] បានតម្កល់ការដាក់ទោសព្រហ្មទណ្ឌ និងកាតព្វកិច្ចតាមសីលធម៌វិជ្ជាជីវៈស្រដៀងគ្នា ដើម្បីទ្រទ្រង់ដល់ការសម្ងាត់តាមផ្លូវច្បាប់ ឱ្យបានដូចជាការសម្ងាត់វេជ្ជសាស្ត្រដែរ។ តុលាការពិចារណាថា អធិបញ្ញាបណ្តោះអាសន្ននោះបានបំពេញគោលបំណងតាមច្បាប់ បើមិនដូច្នោះទេវាជាការចាំបាច់នៅក្នុងសង្គមប្រជាធិបតេយ្យ "ដើម្បីការពារកិត្តិយស កេរ្តិ៍ឈ្មោះ និងភាពឯកជនរបស់លោកប្រធានាធិបតី" ហើយថា "ការវាយតម្លៃរបស់តុលាការថ្នាក់ជាតិ ដែលថា "សិទ្ធិរបស់អ្នកដទៃ" ត្រូវបានបន្តឱ្យទៅក្រុមគ្រួសាររបស់គាត់ នៅពេលដែលគាត់ទទួលមរណភាព" គឺមិនមែន "មិនសមហេតុសមផល ឬ តាមតែអំពើចិត្ត" នោះឡើយ[53]។

**២. កាតព្វកិច្ចរបស់ក្រុមមេធាវីការពារក្តីនៅក្នុងការចៀសវាងពីទំនាស់ផលប្រយោជន៍**

១៩- ***ក្រុមមេធាវីការពារក្តីនៅចំពោះមុខ អ.វ.ត.ក មានកាតព្វកិច្ចជាវិជ្ជមានមួយក្នុងការចៀសវាងពីទំនាស់ផលប្រយោជន៍ ដោយការដកខ្លួន ឬការយល់ព្រម***។ បទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការការពារក្តី (DSS) ដែលនៅក្រោមវិធាន ២២(៤) នៃវិធានផ្ទៃក្នុង បានដាក់បញ្ញត្តិលើការថែរក្សាករណីយកិច្ចវិជ្ជាជីវៈរបស់សហមេធាវី និងកាតព្វកិច្ចរបស់គាត់ឱ្យ "អនុវត្តដោយ ប្រុងប្រយ័ត្នជាប់ជានិច្ច ដើម្បីធានាថា មិនមានទំនាស់ផលប្រយោជន៍ណាមួយបានកើតឡើងនោះទេ"[54]។ ដោយត្រូវគ្នាទៅនឹងកាតព្វកិច្ចនេះ នៅក្នុងព្រឹត្តិការណ៍ដែលទំនាស់មួយពិតជាបានកើតឡើង គេតម្រូវឱ្យសហមេធាវីការពារក្តី "ជូនដំណឹងទៅកូនក្តីដែលរងការប៉ះពាល់ជាសក្តានុពលទាំងអស់"ភ្លាម[55] ឬត្រូវដកការ

[49] រឿងក្តី *Éditions Plon ទល់នឹង ប្រទេសបារាំង,* ពាក្យស្នើសុំលេខ 58148 (១៨ ឧសភា ២០០៤)។

[50] ក្រមព្រហ្មទណ្ឌប្រទេសបារាំង (ពិនិត្យឡើងវិញនៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៥), មាត្រា ២២៦-១៣។

[51] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលបានប្រកាសឱ្យប្រើកាលពីថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១០, ត្រង់មាត្រា ៣១៤។

[52] សមាគមគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា, កំណត់សម្គាល់*ខាងលើ* លេខ១៦ ត្រង់មាត្រា ៧។

[53] រឿងក្តី *Éditions Plon ទល់នឹង ប្រទេសបារាំង,* ត្រង់កថាខណ្ឌ ៣៥។

[54] បទបញ្ជារដ្ឋបាលរបស់ផ្នែកគាំពារ ការការពារក្តី ("DSS") នៃ អ.វ.ត.ក, ត្រង់មាត្រា ៩.២។

[55] *ដដែលដូចមុន,* មាត្រា ៩.៣។

ការពារ ឬមួយក៏ត្រូវ "ស្វែងរកនូវការយល់ព្រមទាំងស្រុង និងដោយមានព័ត៌មានគ្រប់គ្រាន់ពីកូនក្ដីដែលរងការប៉ះពាល់ជាសក្ដានុពលទាំងអស់ដើម្បីបន្តធ្វើជាអ្នកការពារ"[56]។

២០- ***ការប្រមើលមើលឃើញហេតុការណ៍ជាមុននៃសមហេតុសមផលនៃទំនាស់ រវាងការចាត់តាំងមេធាវីកាលពីអតីត និងបច្ចុប្បន្ន គឺមានលក្ខណៈគ្រប់គ្រាន់ក្នុងការដកការការពារ***។ បទដ្ឋាននៃសក្ដីកម្មសម្រាប់ដកគុណវុឌ្ឍិតាមផ្លូវតុលាការរបស់មេធាវីការពារក្ដី ដោយមូលហេតុទំនាស់ផលប្រយោជន៍ នៅក្នុង តំណាក់កាលសវនាការមុនអង្គសេចក្ដី គឺការឃើញហេតុការណ៍ជាមុនសមហេតុសមផលដែលថាទំនាស់មួយអាចនឹងកើតមានឡើង។ ខណៈដែលពាក្យពេជន៍នៅក្នុងបទបញ្ជារដ្ឋបាលរបស់ DSS ហាក់ដូចជាស្មើឡើង ចំពោះការវាយតម្លៃរបស់មេធាវីការពារក្ដី លើអត្ថិភាពនៃទំនាស់ផលប្រយោជន៍ ច្បាប់យុត្តិសាស្ត្រនៃតុលាការ ICTY បានផ្ដល់អាណត្តិថា ឲ្យធ្វើការពិនិត្យពិច័យតាមផ្លូវតុលាការឲ្យបានហ្មត់ចត់ទៅលើ៖ (i) អត្ថិភាព ឬហានិភ័យនៃទំនាស់ផលប្រយោជន៍, (ii) កាលៈទេសៈ និងភាពគ្រប់គ្រាន់នៃការយល់ព្រម ដែលបានមកពីកូនក្ដីដែលរងផលប៉ះពាល់ជាសក្ដានុពល, ឬ (iii) ភាពដែលអាចមានឡើងដែលថាការយល់ព្រមទៅនឹងទំនាស់ផលប្រយោជន៍ណាមួយនោះ នឹងធ្វើឲ្យមានភាពលម្អៀងដែលមិនអាចត្រឡប់ក្រោយបានខាងផ្នែកកិច្ចការរដ្ឋបាលតុលាការ[57]។

២១- នៅក្នុងសេចក្ដីសម្រេចជាឯកច្ឆន្ទមួយរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY នៅក្នុងរឿងក្ដី *Prlić និងគូកន* ដែលបានលើកឡើងនៅក្នុងសំណើ និងទាំងចម្លើយតប ចៅក្រមភាគច្រើនចំនួន ៣(បី)រូប (ចៅក្រម Shahabuddeen, ចៅក្រម Schomburg និង ចៅក្រម Weinberg de Roca) បានចេញសេចក្ដីប្រកាសរួមមួយជាពិសេសនៅលើបញ្ហាស្ដីពីបទដ្ឋាននៃសក្ខីកម្ម។ ការរកឃើញរបស់ពួកគាត់ គឺមានការទាក់ទងដោយផ្ទាល់ទៅនឹងកិច្ចដំណើរការនីតិវិធី លើទំនាស់ផលប្រយោជន៍ ក្នុងអំឡុងពេលនៃការចាត់តាំងដំបូងនៃមេធាវីការពារក្ដី ក្នុងដំណាក់កាលសវនាការមុនអង្គសេចក្ដី ដូចដែលសេចក្ដីសម្រេចដែលរងការជំទាស់បានការបារម្ភពីការចាត់តាំងដំបូងនៃមេធាវីការពារក្ដីដែរ គឺ២(ពីរ)ឆ្នាំ មុនការចាប់ផ្ដើមជំនុំជម្រះក្ដី។ ចៅក្រមទាំងនោះបានរកឃើញថា៖

[56] *ដដែលដូចមុន*។

[57] ក្រមសីលធម៌វិជ្ជាជីវៈរបស់តុលាការ ICTY សម្រាប់មេធាវីការពារក្ដីដែលបង្ហាញខ្លួននៅចំពោះមុខតុលាការអន្តរជាតិ, មាត្រា ១៤(ង)។ ("ក្រមសីលធម៌វិជ្ជាជីវៈរបស់តុលាការ ICTY")។

> *នៅក្នុងរឿងក្តីប្រភេទនេះ វាមានលេចឡើងថា ភាពខុសគ្នាមួយអាចនឹងត្រូវបានទាញចេញយ៉ាងមានប្រយោជន៍រវាង ការប្រមើលមើលដ៏សមហេតុសមផល និង ការគ្រាន់តែស្មង់មើល ហើយថា* <u>ការប្រមើលមើលដ៏សមហេតុសមផលគឺជាមូលដ្ឋាននៃសេចក្តីសម្រេចមួយដ៏គ្រប់គ្រាន់</u>។ *អង្គហេតុនានាបញ្ជាក់ថា នៅពេលសវនាការ ជនជាប់ចោទដែលជាដើមបណ្តឹងឧទ្ធរណ៍ អាចនឹងប្រកាន់ជំហរមួយដែលនឹងមានការប្រែប្រួលជាមួយនឹងជំហររបស់ជនជាប់ចោទម្នាក់ផ្សេងទៀត ដែលត្រូវបានមេធាវីការពារក្តីដដែលតែមួយធ្វើជាតំណាងឱ្យ[...] ផងដែរ។ អង្គហេតុពិតដែលថា សម្រាប់ហេតុផលណាមួយក៏ដោយដែលបានចាត់ទុកថាជាការគ្រប់គ្រាន់ចំពោះរូបគាត់នោះ យ៉ាងណាក៏ដោយក៏ជនជាប់ចោទដែលជាដើមបណ្តឹងឧទ្ធរណ៍ ដែលបានយល់ព្រមទៅនឹងការតំណាងឱ្យជាទូទៅ មិនធ្វើឱ្យអង្គជំនុំជម្រះសាលាឧទ្ធរណ៍បានធូរស្រាលពីការទទួលខុសត្រូវរបស់ខ្លួន ក្នុងការធានាថា* <u>ដើម្បីជាផលប្រយោជន៍នៃយុត្តិធម៌</u> *គេអាចជម្រុញរឿងក្តីរបស់គាត់ឱ្យទៅមុខទៀតបាន* <u>ចាប់ពីពេលចាប់ផ្តើមដំបូង ដោយពុំមានការហាមឃាត់ប្រភេទណាមួយដែលលេចចេញមកពីការឃាត់ឃាំងមេធាវីការពារក្តីដដែលតែមួយនោះឡើយ។</u>[58]។

សេចក្តីសម្រេចនេះនៅក្នុងរឿងក្តី *Prlić* បានយោងទៅដល់ "គោលការណ៍" នៅពីក្រោយវិធាន ៧ នៃក្រមសីលធម៌វិជ្ជាជីវៈរបស់មេធាវីការពារក្តី ប្រទេសហុល្លង់ដ៍ ឆ្នាំ១៩៩២ ("មេធាវីការពារក្តីអាចនឹងមិនការពារបានផលប្រយោជន៍ពីរ ឬច្រើនរបស់ភាគីទេ បើសិនជាផលប្រយោជន៍របស់ពួកគាត់មានទំនាស់ ឬបើសិនជាការវិវត្តន៍នានាទំនងជានឹងនាំពួកគាត់ឱ្យចូលទៅក្នុងទំនាស់") ដែលជាបញ្ញត្តិមួយដែលបានលើកឡើងនៅក្នុងសំណើដំបូង ថាជា "មូលដ្ឋានដ៏សមហេតុសមផលសម្រាប់ធ្វើការកំណត់ថា តើដើម្បីផលប្រយោជន៍នៃយុត្តិធម៌គេតម្រូវឱ្យមានអ្វី។ គឺគេបានទទួលយកនូវការប្រមើលមើលដ៏សមហេតុសមផល"[59]។

២២- ពីរឆ្នាំ នៅមុនចេញសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ នៅក្នុងរឿងក្តី *Prlić និងគូកន* អង្គជំនុំជម្រះសាលាដំបូងមួយ នៅក្នុងរឿងក្តី *Hadzihasanovic* បានតម្រូវឱ្យសក្ខីកម្មនៃ "លទ្ធភាពពិតប្រាកដ [នៃ] ទំនាស់ផលប្រយោជន៍រវាង ការចាត់តាំងពីពេលមុន និងពេលបច្ចុប្បន្ន

---

[58] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Prlić និងគូកន,* សំណុំរឿងលេខ IT-04-74-AR73.1, សាលដីកាលើបណ្តឹងឧទ្ធរណ៍ដាក់ដោយ Bruno Stojic ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឱ្យចាត់តាំងមេធាវីការពារក្តី (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃ តុលាការ ICTY), ២៤ វិច្ឆិកា ២០០៤, ត្រង់សេចក្តីប្រកាស ត្រង់កថាខណ្ឌ ២-៣។

[59] *រដ្ឋអាជ្ញា ទល់នឹង Jadranko Prlić និងគូកន, ,* កំណត់សម្គាល់*ខាងលើ* លេខ៦៤, ត្រង់សេចក្តីប្រកាស ត្រង់កថាខណ្ឌ ៤។

នៃមេធាវីការពារក្តី”[60] ប៉ុន្តែ យ៉ាងណាក៏ដោយ ការលើកស្ទួយគោលការណ៍ស្តីពីការពិនិត្យពិច័យដែលឯករាជ្យតាមផ្លូវតុលាការ ទៅលើហានិភ័យនៃទំនាស់ផលប្រយោជន៍ នៅក្នុងកាលៈទេសៈដែលមេធាវីការពារក្តី និងក្រុឡាបញ្ជីដែលក្នុងឋានៈជាអ្នកមានសមត្ថកិច្ចក្នុងការចាត់តាំង មានការពេញចិត្តតាមរបៀបវិជ្ជាជីវៈ ដែលថាមិនមានទំនាស់ណាមួយអាចនឹងមានអត្ថិភាពបានទេ ឬមួយក៏សូម្បីតែអាចនឹងកើតឡើងបាននោះទេ។ អង្គជំនុំជម្រះសាលាដំបូងនោះ បានសន្និដ្ឋានថា តេស្តស្តីពី “ភាពដែលអាចកើតឡើងដ៏ពិតប្រាកដ” គឺមានលក្ខណៈសមស្រប ខណៈដែលអង្គជំនុំជម្រះមួយ មិនអាចនឹង “នៅរង់ចាំរហូតទាល់តែការខូចខាតដែលអាចប្រមើលមើលបាននោះ បានកើតឡើង ចំពោះកិច្ចដំណើរការនីតិវិធី” ក៏ប៉ុន្តែគេត្រូវតែធ្វើការ “រារាំងដល់ការខូចខាតដែលអាចប្រមើល មើលបានបែបនោះ”[61]។ ច្បាប់ជាតិ(បារាំង)ក៏បានអនុវត្តបទដ្ឋាននៃភាពដែលអាចប្រមើលមើលបាននោះ ធ្វើជាមគ្គុទ្ទេសក៍ដើម្បីឲ្យមេធាវីការពារក្តីធ្វើការកំណត់ថាតើមានអត្ថិភាពនៃ “ហានិភ័យដ៏ធ្ងន់ធ្ងរ” នៃទំនាស់ផលប្រយោជន៍ ដែរ ឬទេ[62]។

២៣- ច្បាប់យុត្តិសាស្ត្ររបស់តុលាការ ICTY ក៏បានបង្កើតយ៉ាងច្បាស់លាស់ដូចគ្នាផងដែរ នូវជំនឿជាអត្តនោម័តទៅលើមេធាវីការពារក្តី សូម្បីតែមេធាវីការពារក្តីដែលមាន “បទពិសោធន៍ការពាររឿងក្តីព្រហ្មទណ្ឌក្នុងប្រទេស និងរឿងក្តីព្រហ្មទណ្ឌអន្តរជាតិ ចំនួនជាង៣០ឆ្នាំ” ក៏ដោយ[63] ក៏មិនអាចញែកដោយឡែកនូវស្ថានភាពនៃទំនាស់ផលប្រយោជន៍ និងប្រសិទ្ធិភាពនៃការព្រមព្រៀងគ្នាដ៏មានសក្តានុពលមួយ ចេញពីការពិនិត្យពិច័យតាមផ្លូវតុលាការ ហើយកាលណាសមស្របគឺ ការដកគុណវុឌ្ឍិរបស់មេធាវីការពារក្តីបានឡើយ។ គោលការណ៍ស្រដៀងគ្នាមួយធ្លាប់ត្រូវបានអនុវត្ត ទាំងនៅក្នុងតុលាការសហព័ន្ធ[64] និងទាំងតុលាការរដ្ឋ[65] នៅក្នុងយុត្តាធិការប្រទេសកំណើតរបស់លោក Michael Karnavas ដែលជាសហមេធាវីការពារក្តីដែលបានចាត់តាំង។ ដូចដែលត្រូវបានសម្រេចដោយអង្គជំនុំជម្រះសាលាឧទ្ធរណ៍សម្រាប់ Eighth Circuit នៃតុលាការរបស់សហរដ្ឋអាមេរិកដូច្នោះដែរ ទោះបីជានៅក្នុងបរិបទនៃការចូលរួមមិនមែននៅក្នុងការការពារជាបន្តបន្ទាប់ទៀតក៏

[60] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Enver Hadzihasanovic,* សំណុំរឿងលេខ IT-01-47-PT, សេចក្តីសម្រេចលើញត្តិរបស់អយ្យការស្នើសុំ ឲ្យពិនិត្យឡើងវិញនូវសេចក្តីសម្រេចរបស់ក្រុឡាបញ្ជីដែលចាត់តាំងលោក Rodney Dixon ជាសហមេធាវីការពារក្តីជនជាប់ចោទ Kubura, (អង្គជំនុំជម្រះសាលាដំបូងទី II នៃតុលាការ ICTY), ២៦ មីនា ២០០២, ត្រង់កថាខណ្ឌ ៥៦។

[61] *ដដែលដូចមុខ។*

[62] ក្រមសីលធម៌វិជ្ជាជីវៈសម្រាប់មេធាវីការពារក្តីថ្នាក់ជាតិ (ប្រទេសបារាំង), មាត្រា ៤.១។ (“ក្រមថ្នាក់ជាតិ”)

[63] DSS, កំណត់សម្គាល់*ខាងលើ* លេខ ៦០។

[64] រឿងក្តី *សហរដ្ឋអាមេរិក ទល់នឹង Lawriw* 568 F.2d, តុលាការសាលាឧទ្ធរណ៍ Eighth Circuit របស់សហរដ្ឋ, ៣០ធ្នូ ១៩៧៧។

[65] រឿងក្តី *រដ្ឋ ទល់នឹង Celikoski, 866 P.2d 139, តុលាការសាលាឧទ្ធរណ៍របស់រដ្ឋ Alaska, ០១ កក្កដា ១៩៩៤។*

ដោយ "វាមិនជាការគ្រប់គ្រាន់ទេ ដែលពឹងផ្អែកទៅលើមេធាវីការពារក្តី ដែលអាចនឹងមិន គិតទាំង ស្រុងទៅដល់ផលប្រយោជន៍ក្នុងការធានាថា កូនក្តីរបស់គាត់ដែលរួមគ្នាម្នាក់ៗនោះ បានធ្វើការលះបង់មួយដ៏មានប្រសិទ្ធិភាព"[66]។ នៅក្នុងរឿងក្តីតែមួយដូចគ្នានេះ តុលាការបានសម្រេចថា បទដ្ឋាននៃសក្ខីកម្មក្នុងការមិនអនុញ្ញាតឲ្យធ្វើជាអ្នកការពារ បានតម្រូវឲ្យមានតែ "ការបង្ហាញជាអប្បបរមា ក្នុងការបង្កើតឲ្យមានជាលទ្ធភាពដ៏សំខាន់មួយនៃទំនាស់ផលប្រយោជន៍" ប៉ុណ្ណោះ[67]។

### ៣. កាលៈទេសៈដែលទំនាស់ផលប្រយោជន៍បានកើតឡើង

២៤- ***ទំនាស់ផលប្រយោជន៍បានកើតឡើង កាលណាមានបញ្ហាពីរដែលមានការទាក់ទងគ្នាយ៉ាងជុំកំភួន និងដែលអាចប្រមើលមើលបានយ៉ាងសមហេតុផលថា ផលប្រយោជន៍របស់អតីតកូនក្តី និងកូនក្តីបច្ចុប្បន្ន គឺមានលក្ខណៈផ្ទុយគ្នាយ៉ាងខ្លាំង*** ។ នៅក្នុងកម្រិតអន្តរជាតិ ក្រមសីលធម៌វិជ្ជាជីវៈ និងបទវិន័យរបស់សមាគមមេធាវីព្រហ្មទណ្ឌអន្តរជាតិ ("ICB")[68] និងសមាគមមេធាវីអន្តរជាតិ ("IBA")[69] ទាំងពីរនេះបានចែងថា មេធាវីការពារក្តីដែលបានធ្វើជាតំណាងពីមុនឲ្យកូនក្តីនៅក្នុងបញ្ហាណាមួយ ដូច្នេះមិនត្រូវធ្វើជាតំណាងឲ្យកូនក្តីផ្សេងម្នាក់ទៀត នៅក្នុងបញ្ហាដែលមានការទាក់ទងគ្នាយ៉ាងជុំកំភួន ដែលផលប្រយោជន៍របស់គាត់មានលក្ខណៈផ្ទុយគ្នាយ៉ាងខ្លាំងទៅនឹងផលប្រយោជន៍របស់កូនក្តីមុននោះឡើយ។ ក្នុងចំណោមប្រព័ន្ធ [ក្រមសីលធម៌វិជ្ជាជីវៈ និងបទវិន័យ] តាមប្រទេសនីមួយៗ វិធានថ្នាក់ជាតិ (ប្រទេសបារាំង)[70], វិធានគំរូនៃគណៈមេធាវីអាមេរិកកាំង ("វិធានរបស់ ABA")[71], វិធានរបស់សមាគមមេធាវីសហព័ន្ធ (ប្រទេសជប៉ុន)[72] និងវិធានសម្រាប់

---

[66] រឿងក្តី *សហរដ្ឋអាមេរិក ទល់នឹង* Lawriw 568 F.2d ត្រង់ទំព័រទី ១០៤។

[67] *ដដែលដូចមុន*, ត្រង់កថាខណ្ឌ ៤៤។

[68] ក្រមសីលធម៌វិជ្ជាជីវៈ និងបទវិន័យរបស់សមាគមមេធាវីព្រហ្មទណ្ឌអន្តរជាតិ (ឆ្នាំ២០០៣)។("ICB")

[69] គោលការណ៍របស់ IBA, កំណត់សម្គាល់*ខាងលើ* លេខ ១៧, ត្រង់ទំព័រទី១៨។

[70] Règlement Intérieure National de la Profession D'avocat ("RIN"), ត្រង់មាត្រា ៤.១ បានចែងថា "មេធាវីការពារក្តីត្រូវតែបង្អង់លែងធ្វើកិច្ចការគ្រប់បែបយ៉ាងទាំងអស់ដែលទាក់ទងទៅនឹងការតំណាងឲ្យកូនក្តី កាលណាមានទំនាស់ផលប្រយោជន៍ នៅពេលដែលភាពសម្ងាត់នៃវិជ្ជាជីវៈដែលឋិតនៅក្នុងហានិភ័យកំពុងត្រូវបានរំលោភ"។

[71] វិធានគំរូស្តីពីសីលធម៌វិជ្ជាជីវៈសម្រាប់សមាគមមេធាវីអាមេរិកកាំង ("វិធានគំរូ"), វិធាន ១.៩(ក)។

[72] សមាគមមេធាវីសហព័ន្ធរបស់ប្រទេសជប៉ុន, វិធានមូលដ្ឋានស្តីពីភារកិច្ចរបស់មេធាវីការពារក្តីដែលកំពុងអនុវត្តការងារ (ឆ្នាំ២០០៤), ត្រង់មាត្រា២៨ បានចែងថា លើកលែងតែមានការយល់ព្រមពីកូនក្តី មេធាវីមិនត្រូវធ្វើការងារនោះទេ កាលណាផលប្រយោជន៍របស់កូនក្តីម្នាក់មានទំនាស់ទៅនឹងផលប្រយោជន៍របស់កូនក្តីម្នាក់ផ្សេងទៀត។

អ្នកមានវិជ្ជាជីវៈច្បាប់ (ប្រទេសសឹង្ហបូរី)[73] ទាំងអស់នេះបានចែងថា មេធាវីការពារក្តីត្រូវតែបង្អង់លែងធ្វើជាអ្នកការពារឲ្យកូនក្តីថ្មី នៅក្នុងករណីដែលមានការទាក់ទងគ្នាយ៉ាងជុំកំភួន ដែលផលប្រយោជន៍របស់គាត់ មានលក្ខណៈផ្ទុយគ្នាយ៉ាងខ្លាំងទៅនឹងផលប្រយោជន៍របស់កូនក្តីមុន។ វិសាលភាពនៃវិធាន ១.៩(ក) នៃវិធានរបស់ ABA ត្រូវបានបញ្ជាក់អះអាងក្នុងពេលថ្មីៗនេះ ដោយតុលាការក្នុងស្រុកនៃសហរដ្ឋ (សហរដ្ឋអាមេរិក) នៅក្នុងរឿងក្តីរបស់ *Fredericks ទល់នឹង Atlantic City Board of Education*[74]។ នៅក្នុងរឿងក្តីនេះ តុលាការបានសម្រេចថា លក្ខខណ្ឌតម្រូវនានា ដើម្បីបង្កើតឲ្យបានជាទំនាស់ផលប្រយោជន៍ សម្រាប់គោលបំណងនៃការដកគុណវុឌ្ឍិរបស់មេធាវីការពារក្តីលែងឲ្យធ្វើជាតំណាងឲ្យកូនក្តីបច្ចុប្បន្ន នឹងត្រូវអាស្រ័យលើអត្ថិភាពនៃទំនាក់ទំនងមេធាវី-កូនក្តីក្នុងពេលកន្លមក កាលណាផលប្រយោជន៍របស់កូនក្តីមុន មានលក្ខណៈផ្ទុយគ្នាយ៉ាងខ្លាំងទៅនឹងផលប្រយោជន៍របស់កូនក្តីបច្ចុប្បន្ន[75]។

២៥- លក្ខខណ្ឌនៃការចាប់ផ្តើមក្នុងកម្រិតខ្ពស់នៃការបង្កើតឡើងករណីរឿងដែលជាប់ពាក់ព័ន្ធគ្នាយ៉ាងច្រើន ត្រូវបានគូសបញ្ជាក់ដោយវិធានគំរូរបស់គណៈមេធាវីអាមេរិកាំង (ABA) ។ ពាក្យថា "យ៉ាងច្រើន" ត្រូវបានកំណត់និយមន័យថា គឺជាសញ្ញាដែលបង្ហាញឲ្យឃើញអំពីកម្រិត ឬវិសាលភាពនៃសារៈសំខាន់របស់បញ្ហាដែលជាប់ទាក់ទងទៅនឹងឯកសារណាមួយនោះ[76]។ ក៏ប៉ុន្តែ "ការដឹងអំពីអង្គហេតុដ៏ជាក់លាក់ ដែលទទួលបានក្នុងអំឡុងពេលនៃការបង្ហាញជូនកាលពីលើកមុនណាមួយ ដែលជាប់ទាក់ទងទៅនឹងបញ្ហាដែលកំពុងតែចោទចំពោះមុខ ជាធម្មតា គឺវានឹងបណ្តាលឲ្យមានការច្រានចោលជាមុននូវការការពារនោះ"[77]គឺជាការគ្រប់គ្រាន់សម្រាប់បង្កើតជា"សារៈសំខាន់ខ្លាំង" នៃទំនាស់ផល

---

[73] វិធាន(ស្តីពីក្រមសីលធម៌វិជ្ជាជីវៈ)សម្រាប់អ្នកមានវិជ្ជាជីវៈច្បាប់នៅប្រទេសសឹង្ហបូរី, ត្រង់វិធាន ៣១(១)៖ "បុគ្គលដែលបានធ្វើសកម្មភាពឲ្យកូនក្តីនៅក្នុងកិច្ចការណាមួយ នៅពេលក្រោយមកបុគ្គលនោះមិនត្រូវធ្វើសកម្មភាពប្រឆាំងនឹងកូនក្តីរូបនោះទេ (ឬ ប្រឆាំងនឹងបុគ្គលនានាដែលធ្លាប់មានជាប់ទាក់ទិននៅក្នុងកិច្ចការនោះ ឬបានសមគំនិតជាមួយនឹងកូនក្តីរូបនោះ) នៅក្នុងកិច្ចការតែមួយដូចគ្នា ឬនៅក្នុងកិច្ចការពាក់ព័ន្ធណាមួយទៀតក៏ដោយ"។ វិធាន ២៤ នៃវិធានស្តីពីក្រមសីលធម៌វិជ្ជាជីវៈ ចែងថា "(១) តាមមធ្យោបាយណាក៏ដោយ មេធាវីការពារក្តី និងអ្នកច្បាប់ឯកជន (solicitor) មិនត្រូវ ទោះដោយត្រង់ៗក្តី ឬដោយប្រយោលក្តី (ក) បង្ហាញព័ត៌មានសម្ងាត់ណាមួយដែល មេធាវីការពារក្តី និងអ្នកច្បាប់ឯកជន (solicitor) នោះ ទទួលបានមកដែលជាលទ្ធផលនៃការកក់ប្រាក់មេធាវីទុក (retainer), ឬមួយក៏ (ខ) បង្ហាញអំពីខ្លឹមសារនៃក្រដាសឯកសារដែលបានកត់ត្រានូវសេចក្តីណែនាំបែបដូច្នោះ, លើកលែងតែមានការយល់ព្រមពីកូនក្តី ឬច្បាប់បានតម្រូវឲ្យធ្វើដូច្នោះ ឬមានដីកាបង្គាប់របស់តុលាការ"។

[74] រឿងក្តី *Fredericks ទល់នឹង Atlantic City Board of Education* (នៅក្នុងតុលាការ Camden Vicinage របស់រដ្ឋ New Jersey នៃសហរដ្ឋ)។

[75] *ដដែលដូចមុន,* ត្រង់ទំព័រទី៥-៦។

[76] វិធានគំរូនៃវិធានផ្ទៃក្នុង, លេខ៧៨ *ខាងដើម,* ត្រង់វិធាន១.០, "ប្រជុំពាក្យបច្ចេកទេសTerminology".

[77] *ដូចគ្នានឹងខាងលើ* វិធាន១.៩, នៅក្នុងសេចក្តីអធិប្បាយផ្តល់មតិ [៣]។

ប្រយោជន៍។ សូម្បីតែលក្ខខណ្ឌនៃការចាប់ផ្តើមក្នុងកម្រិតទាបណាមួយ ត្រូវបានបង្កើតឡើងដោយតុលាការជាន់ខ្ពស់(នៃប្រទេសសិង្ហបុរី)ក៏ដោយក៏ នៅក្នុងករណីរឿងក្តីរបស់ *Vorobiev Nikolay ទល់នឹង Lush John Frederick Peters:* "ប្រសិនបើបញ្ហានានាមានការជាប់ពាក់ព័ន្ធគ្នាយ៉ាងជាក់ស្តែង ដែលមេធាវីការពារក្តីមិនអាចការពារបានទេ ទោះបីជាមិនមានព័ត៌មានសម្ងាត់ ដែលមានហានិភ័យក៏ដោយ"[78]។

២៦- ***ទំនាស់ផលប្រយោជន៍ណាមួយកើតឡើង ប្រសិនបើគេអាចធ្វើការព្យាករណ៍ទុកជាមុនបានដោយសមហេតុសមផលថាព័ត៌មានសម្ងាត់ដែលពាក់ព័ន្ធនឹងការធ្វើតំណាងឱ្យអតីតកូនក្តីអាចមានផលប្រយោជន៍ដល់មេធាវីរបស់កូនក្តីបច្ចុប្បន្ន និងធ្វើឱ្យខូចខាតដល់ផលប្រយោជន៍ដល់អតីតកូនក្តី។*** បើសិនជាការប្រើប្រាស់នូវព័ត៌មានសម្ងាត់ជាប់ទាក់ទងទៅនឹងការការពារឱ្យអតីតកូនក្តី អាចត្រូវបានព្យាករណ៍ទុកជាមុនដោយសមហេតុសមផលថា មានប្រយោជន៍ដល់មេធាវីការពារក្តីរបស់កូនក្តីបច្ចុប្បន្ន ក៏ប៉ុន្តែធ្វើឱ្យខូចខាតផលប្រយោជន៍ដល់អតីតកូនក្តីនោះ ទំនាស់ផលប្រយោជន៍នឹងកើតឡើង។ គណៈមេធាវីអន្តរជាតិ (International Bar Association)[79], គណៈមេធាវីការពារក្តីករណីរឿងព្រហ្មទណ្ឌអន្តរជាតិ ( Internatonal Criminal Bar )[80] ហើយស្រដៀងគ្នានេះដែរ វិធានគំរូស្តីពីក្រមសីលធម៌វិជ្ជាជីវៈ[81]របស់គណៈមេធាវីអាមេរិកាំង (American Bar Association) បានបង្កើតជាកាតព្វកិច្ចសម្រាប់មេធាវីដោយមិនឱ្យប្រើប្រាស់ ឬបញ្ចេញនូវព័ត៌មានដែលទាក់ទងនឹងការការពារឱ្យកូនក្តី

---

[78] ករណីរឿងក្តីរបស់ *Vorobiev Nikolay ទល់នឹង Lush John Frederick Peters* [ឆ្នាំ២០១០] SGHC 290។

[79] គោលការណ៍ របស់ IBA , កំណត់សម្គាល់លេខ១៧ *ខាងដើម*, ត្រង់ជំពូកទី៣ ត្រង់កថាខណ្ឌទី៣.២ 2 "កំណត់ពន្យល់"៖ "មេធាវីដែលកាលពីមុនធ្លាប់បានធ្វើការការពារឱ្យកូនក្តីណាម្នាក់ នៅក្នុងករណីរឿងក្តីណាមួយ ឬ ដែលវត្តមានរបស់គាត់ ឬអតីតការិយាល័យមេធាវីរបស់គាត់ កាលពីមុនធ្លាប់បានធ្វើការការពារឱ្យកូនក្តីក្នុងករណីរឿងណាមួយ ក្រោយពីនោះ មិនត្រូវ៖ "ប្រើប្រាស់នូវព័ត៌មានដែលទាក់ទងនឹងការធ្វើការការពារនោះ ដើម្បីធ្វើឱ្យខូចខាតដល់ផលប្រយោជន៍របស់អតីកូនក្តីនោះឡើយ។ លើកលែងតែក្នុងករណីដែលច្បាប់ឬវិធានស្តីពីសីលធម៌បានអនុញ្ញាតឱ្យ តែប៉ុណ្ណោះ"។

[80] ICB, កំណត់សម្គាល់លេខ៧៥ *ខាងដើម*, ត្រង់កថាខណ្ឌទី៧៖បានចែងថា មេធាវីដែលកាលពីមុនធ្លាប់បានធ្វើការការពារឱ្យកូនក្តីណាម្នាក់ នៅក្នុងករណីរឿងក្តីណាមួយឬវត្តមានរបស់គាត់ ឬអតីតការយាល័យមេធាវីរបស់គាត់ កាលពីមុនធ្លាប់បានធ្វូជាតំណាងឱ្យកូនក្តីណាម្នាក់ក្នុងករណីរឿងក្តីណាមួយ ក្រោយពីនោះមិនត្រូវ ៖ ១) ប្រើប្រាស់នូវព័ត៌មានដែលទាក់ទងនឹងការធ្វើការការពារនោះ ដើម្បីធ្វើឱ្យខូចខាតដល់ផលប្រយោជន៍របស់អតីកូនក្តីនោះទេ។ លើកលែងតែដូចដែលមាត្រា៦បានអនុញ្ញាតឱ្យ ឬតម្រូវឱ្យធ្វើទាក់ទងនឹងកូនក្តីនោះតែប៉ុណ្ណោះ ឬនៅពេលព័ត៌មាននោះត្រូវបានគេដឹងឮជាទូទៅ។ ដែលនៅក្នុងមាត្រា៦(២)នៃក្រមសីលធម៌បានចែងថា៖ "មេធាវីអាចបញ្ចេញព័ត៌មាននោះបាន ប៉ុន្តែនៅក្នុងកម្រិតដែលមេធាវីមានហេតុផលដែលធ្វើឱ្យជឿថាចាំបាច់៖ ក) ដើម្បីបង្ការកុំឱ្យកូនក្តីប្រព្រឹត្តនូវអំពើឧក្រិដ្ឋណាមួយ ដែលមេធាវីជឿថា ទំនងជានឹងបណ្តាលឱ្យជិតស្លាប់ ឬរងរបួសធ្ងន់ធ្ងរដល់រូបរាងកាយ។ ឬ (ខ) ដើម្បីបង្កើតនូវការការពារក្តី ចំពោះការចោទប្រកាន់ពីបទព្រហ្មទណ្ឌ ឬការទាមទារសំណងខាងរដ្ឋប្បវេណី ប្រឆាំងនឹងមេធាវី ដោយផ្អែកលើមូលដ្ឋានការប្រព្រឹត្តដែលកូនក្តីបានចូលរួម ឬដើម្បីឆ្លើយតបទៅនឹងការចោទប្រកាន់នានា នៅក្នុងកិច្ចដំណើរការនីតិវិធីណាមួយដែលពាក់ពណ្ធទៅនឹងការធ្វើជាតំណាងឱ្យកូនក្តីរបស់មេធាវី"។

[81] វិធានផ្ទែក្នុងគំរូ, លេខ ៧៨ *ខាងដើម* , ត្រង់វិធាន១.៩។

ដែលធ្វើឲ្យការខូចខាតដល់ផលប្រយោជន៍របស់អតីតកូនក្តី[82]។ ក្រមសីលធម៌របស់គណៈមេធាវីនៃប្រទេសអង់គ្លេស (Bar of England) បានកំហិតនូវភារកិច្ចស្រដៀងគ្នានេះដែរចំពោះមេធាវី៖ ដោយគ្មានការយល់ព្រមពីអតីតកូនក្តី (ឬម្យ៉ាងទៀត តាមដែលច្បាប់បានអនុញ្ញាត) មេធាវីទាំងឡាយត្រូវហាមឃាត់មិនឲ្យបញ្ចេញព័ត៌មានសម្ងាត់ ឬប្រើប្រាស់ព័ត៌មាននេះ ដែលនាំឲ្យអន្តរាយដល់កូនក្តីឡើយ[83]។

២៧- ***ទំនាស់ផលប្រយោជន៍ណាមួយកើតឡើង ប្រសិនបើគេអាចព្យាករណ៍ទុកជាមុនបាន ដោយសមហេតុសមផលថា ចំណេះដឹងដែលទទួលបានមកពីអតីតកូនក្តី អាចមានផលប្រយោជន៍ដល់កូនក្តីបច្ចុប្បន្ន។*** អនុលោមតាមក្រមថ្នាក់ជាតិ(ប្រទេសបារាំង) មេធាវីមិនអាចទទួលយល់ព្រមធ្វើជាអ្នកការពារឲ្យកូនក្តីណាម្នាក់បានឡើយ បើសិនជាការដឹងរបស់ខ្លួនអំពីកិច្ចការផ្សេងៗរបស់អតីតកូនក្តីជួយជម្រុញធ្វើឲ្យមានផលប្រយោជន៍ផ្សេងៗដល់កូនក្តីថ្មី[84]។ ស្រដៀងគ្នានេះដែរ អនុលោមតាមក្រម CCBE Code (របស់ទ្វីបអឺរ៉ុប)ចែងថា៖ “មេធាវីមិនត្រូវទទួលយល់ព្រមជាមួយកូនក្តីថ្មីណាម្នាក់ឡើយ ប្រសិនជាមានហានិភ័យអំពីការរំលោភបំពានលើភាពសម្ងាត់ទាក់ទងទៅនឹងព័ត៌មាន ដែលបានផ្តល់កាលពីមុនដោយអតីតកូនក្តីណាម្នាក់ ឬនៅពេលដែលការដឹងដែលមេធាវីបានទទួលមកពីអតីតកូនក្តីនឹងផ្តល់អត្ថប្រយោជន៍ទៅឲ្យកូនក្តីថ្មី”[85]។ នៅក្នុងតុលាការសម្រាប់ករណីរឿងទាក់ទងនឹងគ្រួសារ Family court (ប្រទេសអូស្ត្រាលី) សាលាឧទ្ធរណ៍បានរកឃើញថាបញ្ហាគឺវាស្ថិតនៅត្រង់ថា តើមេធាវីពីមុនរបស់ដើមបណ្តឹងឧទ្ធរណ៍ ដែលជាតំណាងឲ្យភាគីចុងបណ្តឹងឧទ្ធរណ៍ដែរនោះ មានបានរក្សានូវព័ត៌មានសម្ងាត់ ដែលអាចផ្តល់អត្ថប្រយោជន៍ដល់ករណីរឿងក្តីរបស់ភាគីចុងបណ្តឹងឧទ្ធរណ៍ដែរ ឬទេ។ សាលាឧទ្ធរណ៍បានសម្រេចថា មេធាវីរបស់ភាគីចុងបណ្តឹងឧទ្ធរណ៍បានធ្វើដូចខាងលើនេះ ហើយបានចេញដីកាសម្រេចឲ្យបញ្ឈប់លែងឲ្យមានការទាក់ទងគ្នារវាងមេធាវី និងកូនក្តី[86]។

---

[82] *ដូចគ្នានឹងខាងលើ* ត្រង់វិធាន ១.៩(គ)(១)៖ “មេធាវីដែលកាលពីមុនធ្លាប់បានធ្វើការការពារឲ្យកូនក្តីណាម្នាក់ នៅក្នុងករណីរឿងក្តីណាមួយ ឬ ដែលវត្តមានរបស់គាត់ ឬអតីតការិយាល័យមេធាវីរបស់គាត់ កាលពីមុនធ្លាប់បានធ្វើការការពារឲ្យកូនក្តីក្នុងករណីរឿងណាមួយ ក្រោយពីនោះ មិនត្រូវ៖ “ប្រើប្រាស់នូវព័ត៌មានដែលទាក់ទងនឹងការធ្វើការការពារនោះ ដើម្បីធ្វើឲ្យខូចខាតដល់ផលប្រយោជន៍របស់អតីកូនក្តីនោះទេ។ លើកលែងតែក្នុងករណីដែលវិធានទាំងនេះចែងអនុញ្ញាតឲ្យ ឬតម្រូវឲ្យធ្វើទាក់ទងនឹងកូនក្តីនោះតែប៉ុណ្ណោះ”។

[83] ក្រមសីធម៌របស់គណៈមេធាវីនៃប្រទេសអង់គ្លេស, § 702. (“គណៈមេធាវីនៃប្រទេសអង់គ្លេស”)

[84] *ដូចគ្នានឹងខាងលើ។*

[85] CCBE, កំណត់សម្គាល់លេខ១៧ *ខាងដើម,* ត្រង់មាត្រា៣.២។

[86] ករណីរឿងក្តីរបស់ *Manner ទល់នឹង Manner* [ឆ្នាំ២០១២] FamCAFA 6.

ក្រមសីលធម៌របស់គណៈមេធាវីនៃប្រទេសអង់គ្លេស ក៏បានហាមឃាត់មិនឱ្យប្រើប្រាស់នូវព័ត៌មានសម្ងាត់ដែលទាក់ទងជាមួយនឹងអតីតកូនក្តី ដើម្បីជាអត្ថប្រយោជន៍ដល់កូនក្តីបច្ចុប្បន្នផងដែរ[87]។

២៨- ***ទំនាស់ផលប្រយោជន៍ណាមួយកើតឡើង ប្រសិនបើគេអាចព្យាករណ៍ទុកជាមុនបានដោយសមហេតុសមផលថាព័ត៌មានសម្ងាត់ដែលទាក់ទងនឹងការការពារឱ្យអតីតកូនក្តី អាចផ្តល់អត្ថប្រយោជន៍ដល់មេធាវីរបស់កូនក្តីបច្ចុប្បន្នណាម្នាក់ ហើយដែលធ្វើឱ្យផលប្រយោជន៍របស់កូនក្តីទាំងពីរមានភាពផ្ទុយគ្នា។*** ក្រមសីលធម៌របស់អាជ្ញាធរសម្រាប់គ្រប់គ្រងមេធាវី Solicitors Regulation Authority (នៃប្រទេសអង់គ្លេស និងប្រទេសវ៉េលហ្ស៍) បានចែងនូវសេចក្តីដោយខ្លីៗហើយច្បាស់អំពីរឿងនេះថា៖ “បើសិនជាលោកកាន់កាប់ ឬមួយក៏ការិយាល័យមេធាវីរបស់លោកកាន់កាប់នូវព័ត៌មានសម្ងាត់ដែលទាក់ទងទៅនឹងកូនក្តីណាម្នាក់ ឬទៅនឹងអតីតកូនក្តី លោកមិនត្រូវប្រថុយប្រថានគ្រោះថ្នាក់ក្នុងការរំលោភលើការសម្ងាត់ដោយការធ្វើតំណាងឱ្យ ឬក៏បន្តធ្វើតំណាងជួសមុខឱ្យកូនក្តីណាម្នាក់ផ្សេងទៀតក្នុងបញ្ហាណាមួយនោះឡើយ បើសិនជា៖ (ក) “ព័ត៌មាននោះអាចនឹងត្រូវបានគេរំពឹងទុកថាមានអត្ថប្រយោជន៍ និង(ខ) ថាកូនក្តីនោះបានទទួលនូវអត្ថប្រយោជន៍ផ្ទុយគ្នាពីកូនក្តីដែលបានលើកឡើងពីដំបូង ឬអតីតកូនក្តី”[88]។

២៩- ***ទំនាស់ផលប្រយោជន៍ណាមួយក៏អាចកើតឡើងបានដែរ ប្រសិនបើមានហានិភ័យដ៏ធំថា ការការពារឱ្យកូនក្តីបច្ចុប្បន្ន នឹងត្រូវបានកម្រិតយ៉ាងជាក់ស្តែងដោយសារកាតព្វកិច្ចរបស់មេធាវី ចំពោះអតីតកូនក្តី។*** អនុលោមតាមក្រមសីលធម៌របស់ គណៈមេធាវីអន្តរជាតិ(IBA) ទំនាស់ផលប្រយោជន៍ក៏អាចកើតឡើងបានដែរ “ក្នុងករណីបើសិនជាមានហានិភ័យដ៏ធំមួយថា ការធ្វើតំណាងឱ្យកូនក្តីម្នាក់ឬច្រើននាក់នឹងត្រូវបានកម្រិតយ៉ាងជាក់ស្តែង ដោយសារការទទួលខុសត្រូវរបស់មេធាវីចំពោះកូនក្តីម្នាក់ទៀត, អតីតកូនក្តី ឬតតីយជនណាម្នាក់ ឬដោយសារផលប្រយោជន៍ជាបុគ្គលផ្ទាល់ខ្លួនរបស់មេធាវី”[89]។

---

[87] គណៈមេធាវីនៃប្រទេសអង់គ្លេស, កំណត់សម្គាល់លេខ៩០ *ខាងដើម*។

[88] ក្រមសីលធម៌របស់អាជ្ញាធរសម្រាប់គ្រង់គ្រងមេធាវី ឆ្នាំ២០១១, វិធាន៤.០៣, “ការសម្ងាត់ និង ការបញ្ចេញការសម្ងាត់, អាជ្ញាធរសម្រាប់គ្រង់គ្រងមេធាវី”។ គេហទំព័រ http://sra.org.uk/solicitors/handbook/code/part2/rule4/content.page (ដែលបានចូលមើលជាចុងក្រោយកាលពីថ្ងៃទី២១ ខែមេសា ឆ្នាំ២០១២)។

[89] “គោលការណ៍របស់គណៈមេធាវីអន្តរជាតិ IBA, គ្រង់ជំពូក៣ , គ្រង់កថាខណ្ឌទី៣.១ “គោលការណ៍ទូទៅ,” “មេធាវីមិនត្រូវប្រកាន់ជំហរដែលធ្វើឱ្យផលប្រយោជន៍របស់កូនក្តីណាម្នាក់មានទំនាស់ជាមួយនឹងផលប្រយោជន៍របស់មេធាវីឡើយ លុះត្រាតែត្រូវបានអនុញ្ញាតដោយច្បាប់ដែលចែងផ្សេងពីនេះ ដោយវិធានស្តីពីក្រមសីលធម៌ជាធរមាន, ឬ បើសិនជាត្រូវបានអនុញ្ញាតដោយកូនក្តី”។ គ្រង់កថាខណ្ឌទី៣.២ “កំណត់ពន្យល់:” □ ទំនាស់អំពីផលប្រយោជន៍មានអត្ថិភាព ប្រសិនជាការធ្វើការការពារឱ្យកូនក្តីណាមួយ ធ្វើឱ្យមានផលប្រយោជន៍ផ្ទុយគ្នាដោយផ្ទាល់ទៅនឹងផលប្រយោជន៍របស់កូនក្តីម្នាក់ផ្សេងទៀត ឬធ្វើឱ្យមានហានិភ័យដ៏ធំ ដែលការធ្វើការការពារឱ្យកូនក្តីម្នាក់ ឬច្រើននាក់

៣០- ***ច្បាប់របស់កម្ពុជា ដែលយោងទៅលើ(ប្រព័ន្ធ)ច្បាប់របស់បារាំង មិនអនុញ្ញាតឱ្យយកការយល់ព្រមជាលាយលក្ខណ៍អក្សរមកធ្វើជាមូលដ្ឋានដើម្បីបោះបង់ចោលនូវការសម្ងាត់ ឬទម្រង់មួយចំនួននៃទំនាស់ផលប្រយោជន៍ដែលអាចព្យាករណ៍ទុកជាមុនបានឡើយ។*** ដូចដែលបានលើកខាងលើ ភារកិច្ចក្នុងការរក្សាការសម្ងាត់គឺត្រូវធ្វើជាដាច់ខាត ហើយមិនអាចលះបង់សិទ្ធិនេះចោលបានទេតាមច្បាប់របស់កម្ពុជា សូម្បីតែកូនក្តីក៏មិនអាចធ្វើបានដែរ[90]។ ទោះជាយ៉ាងនេះក្តីក៏ច្បាប់របស់កម្ពុជាមិនបាននិយាយទាល់តែសោះ ស្តីពីសុពលភាពនៃការយល់ព្រមជាលាយលក្ខណ៍អក្សររបស់អតីតកូនក្តី នឹងកូនក្តីថ្មីសម្រាប់ធ្វើជាមូលដ្ឋានដើម្បីជៀសវាងកុំឱ្យមានទំនាស់ផលប្រយោជន៍ដែលមានសក្តានុពល ដែលក្នុងនោះ រួមមាន ផលប្រយោជន៍ផ្សេងៗទៀតរបស់ភាគីណាមួយក្នុងចំណោមភាគីទាំងពីរនោះផង។ នៅក្នុងប្រព័ន្ធច្បាប់របស់ប្រទេសបារាំង ដែលប្រទេសកម្ពុជាបានយកគំរូតាមដើម្បីធ្វើជាក្របខណ្ឌសម្រាប់ក្រមសីលធម៌ច្បាប់នោះ បទបញ្ញត្តិដែលពាក់ព័ន្ធនៃក្រមសីលធម៌វិជ្ជាជីវៈរបស់ថ្នាក់ជាតិសម្រាប់មេធាវី (“ក្រមសីលធម៌ថ្នាក់ជាតិ”) ដែលបានឆ្លុះបញ្ចាំងតាមរយៈក្រិត្យមួយនាឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបទដ្ឋានសីលធម៌នៃវិជ្ជាជីវៈមេធាវី ហើយបានចែងថា មេធាវីត្រូវតែបញ្ឈប់លែងឱ្យចូលរួមនៅក្នុងគ្រប់កិច្ចការរបស់រាល់កូនក្តីទាំងអស់ដែលបានទទួលរងនូវផលប៉ះពាល់ លុះត្រាតែមានការព្រមព្រៀងជាលាយលក្ខណ៍ពីភាគីនានា ក្នុងករណីបើ៖ (១) មានទំនាស់ផលប្រយោជន៍។ (២) នៅក្នុងពេលដែលការរក្សាការសម្ងាត់ ត្រូវបានរំលោភបំពាន។ (៣) នៅពេលដែលឯករាជ្យភាពរបស់មេធាវីអាចត្រូវបានធ្វើឱ្យខូចខាត[91]។ ជាងនេះទៅទៀត មេធាវីមិនអាចធ្វើជាតំណាងឱ្យកូនក្តីថ្មីណាម្នាក់បានទេ បើសិនជាព័ត៌មានសម្ងាត់ដែលបានផ្តល់ឱ្យដោយអតីតកូនក្តីណាម្នាក់អាចត្រូវបានរំលោភបំពាន ឬនៅពេលដែលការដឹងរបស់មេធាវីអំពីកិច្ចការរបស់អតីតកូនក្តី ជួយជម្រុញឱ្យបានផលប្រយោជន៍ទៅកូនក្តីថ្មី[92]។

---

បណ្តាលឱ្យមានការកម្រិតយ៉ាងជាក់ស្តែងដោយការទទួលខុសត្រូវរបស់ខ្លួន ចំពោះកូនក្តីណាម្នាក់ផ្សេងទៀត, អតីតកូនក្តី, តតីយជន ឬដោយសារផលប្រយោជន៍បុគ្គលផ្ទាល់ខ្លួនរបស់មេធាវី។

[90] គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា, កំណត់សម្គាល់លេខ១៦ *ខាងដើម* ត្រង់មាត្រា៧។

[91] ក្រិត្យលេខ 2005-790 ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៥ ស្តីពីវិធាន វិធានស្តីពីករណីយកិច្ចសាស្ត្រខាងវិជ្ជាជីវៈរបស់មេធាវី relatif aux règles de déontologie de la profession d'avocat, អត្ថបទដែលបានធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១១, មាត្រា៧។ ក្រមសីលធម៌ជាតិ, កំណត់សម្គាល់លេខ ៦៩ *ខាងដើម*, ត្រង់មាត្រា ៤.១, ដែលបានដាក់បញ្ចូលជាមួយនូវខ្លឹមសារដូចគ្នាយ៉ាងត្រឹមត្រូវ។

[91] ក្រិត្យលេខ 2005-790 ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៥ ស្តីពីវិធាន វិធានស្តីពីករណីយកិច្ចសាស្ត្រខាងវិជ្ជាជីវៈរបស់មេធាវី relatif aux règles de déontologie de la profession d'avocat, អត្ថបទដែលបានធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១១, មាត្រា៧។ ក្រមសីលធម៌ជាតិ, កំណត់សម្គាល់លេខ ៦៩ *ខាងដើម*, ត្រង់មាត្រា ៤.១, ដែលបានដាក់បញ្ចូលជាមួយនូវខ្លឹមសារដូចគ្នាយ៉ាងត្រឹមត្រូវ។

[92] *ដូចគ្នានឹងខាងលើ។*

៣១- ក្រុមសីលធម៌ថ្នាក់ជាតិ បានកំណត់និយមន័យនៃពាក្យ "ទំនាស់ផលប្រយោជន៍" ថាកើតឡើង៖ (១) នៅពេលដែលមេធាវីណាម្នាក់ដែលមានកាតព្វកិច្ចត្រូវផ្តល់នូវព័ត៌មានឲ្យបានពេញលេញ និងយ៉ាងត្រឹមត្រូវ មិនមានលទ្ធភាពអាចបំពេញបេសកកម្មនេះ ដោយគ្មានការសម្របសម្រួលផលប្រយោជន៍រវាងភាគីមួយ ឬច្រើនបាន។ ឬ (២) បើសិនជា*ការការពារក្តី* របស់ភាគីជាច្រើនដោយមេធាវីតែមួយជាមួយគ្នា*នាំឲ្យមេធាវីនោះសម្រេចប្រកាន់យកនូវយុទ្ធសាស្ត្រផ្សេងពីយុទ្ធសាស្ត្រ ដែលគាត់គួរតែប្រកាន់យក បើសិនជាគាត់ការពារឲ្យជនជាប់ចោទតែម្នាក់ប៉ុណ្ណោះ*[93]។

## ៤. សិទ្ធិរបស់កូនក្តីក្នុងការលះបង់នូវទំនាស់ផលប្រយោជន៍ នៅក្នុងកាលៈទេសៈដែលមានការកម្រិត

៣២- តុលាការអន្តរជាតិនានា អនុញ្ញាតឲ្យកូនក្តីនានាអាចលះបង់នូវទំនាស់ផលប្រយោជន៍ ដែលមិនសូវប្រកាស តាមរយៈការយល់ព្រមទាំងស្រុង និងដោយមានការជូនដំណឹង។ គោលបំណងនៃវិធានផ្ទៃក្នុងគឺដើម្បី "រួមបញ្ចូលគ្នានូវនីតិវិធីនានាជាធរមានរបស់កម្ពុជា បំពេញបន្ថែមដោយបទដ្ឋានអន្តរជាតិនានា បើសិនជាមានភាពចាំបាច់និងសមស្រប"[94]។ វិធានផ្ទៃក្នុងមិនមាននិយាយដល់អំពីបញ្ហាទំនាស់ផលយោជន៍ដែលកើតចេញមកពីការធ្វើការការពារឲ្យជនសង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទនោះទេ។ ហេតុនេះ សហព្រះរាជអាជ្ញាជូនជាយោបល់សម្រាប់ពិចារណាថា មគ្គុទេសក៍ណែនាំ គួរបានស្វែងរកនៅក្នុងវិធានស្តីពីនីតិវិធីដែលបានបង្កើតឡើង នៅក្នុងកម្រិតអន្តរជាតិ ជាពិសេសនៅក្នុងវិធានស្តីពីនីតិវិធីភ័ស្តុតាង និងនៅក្នុងយុត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិនានា ដោយអនុលោមតាមសិទ្ធិអំណាចរបស់សហចៅក្រមស៊ើបអង្កេត តាមមាត្រា២៣ថ្មី នៃច្បាប់ អវតក។

---

[93] ក្រុមសីលធម៌ថ្នាក់ជាតិ, កំណត់សម្គាល់លេខ៦៩ *ខាងដើម* បន្ថែមនិយមន័យនៃទំនាស់អំពីផលប្រយោជន៍។ [ សង្កត់ន័យបន្ថែមដោយអក្សរទ្រេត]

[94] ឯកសារលេខ **E51/14** សេចក្តីសម្រេចលើអញ្ញត្រកម្មបឋមរបស់ នួន ជា ពាក់ព័ន្ធនឹងការចោទប្រកាន់អំពីចរិតលក្ខណៈផ្ទុយគ្នានៃវិធានផ្ទៃក្នុង របស់ អវតក ទៅនឹងច្បាប់រដ្ឋធម្មនុញ្ញ, ចុះថ្ងៃទី៨ សីហា ២០១១ត្រង់កថាខណ្ឌទី៧។

៣៣- នៅចំពោះមុខគ្រប់បណ្តាតុលាការឧក្រិដ្ឋកម្មអន្តរជាតិទាំងអស់ ជនជាប់ចោទមានសិទ្ធិជាមូលដ្ឋានក្នុងការការពារក្តីរបស់ខ្លួនតាមរយៈជំនួយរបស់មេធាវីតាមការជ្រើសរើសរបស់ខ្លួនផ្ទាល់[95]។ ក៏ប៉ុន្តែសិទ្ធិនេះគឺមិនមាន "លក្ខណៈដាច់ណាត់"នោះឡើយ[96]។ ទំនាស់ផលប្រយោជន៍ដែលជាក់ស្តែងឬដែលមានសក្តានុពល គឺជាការទទួលស្គាល់ដែលមានការកម្រិតមួយ ទៅលើការជ្រើសរើសរបស់ជនជាប់ចោទ[97]។ តាមការពិត មេធាវីមានភារកិច្ចត្រូវមានភក្តីភាពចំពោះកូនក្តីនានាដែលមានស្រាប់ និងត្រូវមានភារកិច្ចចំពោះតុលាការ ក្នុងការធ្វើសកម្មភាពប្រកបដោយឯករាជ្យភាព ដើម្បីជាផលប្រយោជន៍ដល់ភាពយុត្តិធម៌[98]។ អាស្រ័យហេតុនេះ មេធាវីត្រូវតែឈប់ធ្វើការការពារឲ្យកូនក្តីណាម្នាក់ នៅពេលដែលការធ្វើតំណាងនោះមានផលប៉ះពាល់ ឬអាចមានផលប៉ះពាល់ដល់ការធ្វើការការពារឲ្យកូនក្តីមួយផ្សេងទៀត[99]។

៣៤- នៅក្នុងសំណើបឋមរបស់គាត់ សហព្រះរាជអាជ្ញាអន្តរជាតិបានជូនជាមតិថា តុលាការអន្តរជាតិនានាបានកម្រិតអំពីកាលៈទេសៈមួយចំនួនដែលក្នុងនោះកូនក្តីទាំងឡាយអាចបដិសេធ ឬទទួលយល់ព្រមចំពោះទំនាស់ផលប្រយោជន៍។ តាមការពិតតុលាការ ICC, ICTY, និងតុលាការ ICTR បានអនុញ្ញាតឲ្យមេធាវីអាចព្យាយាមធ្វើការដោះស្រាយទំនាស់បានដោយការស្វែងរកនូវ "ការយល់ព្រមដ៏ពេញលេញ និងដោយមានការជូនដំណឹងជាលាយលក្ខណ៍អក្សរពីគ្រប់កូនក្តីទាំងអស់ដែលបានទទួលរងផលប៉ះពាល់ដ៏មានសក្តានុពលដើម្បីឲ្យបន្តការធ្វើការការពារ"[100]។ នៅចំពោះមុខតុលាការ

---

[95] *សូមអាន* ឧទាហរណ៍ដូចជា ច្បាប់លក្ខន្តិកៈរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី(ដែលបានអនុម័តកាលពីថ្ងៃទី២៥ ឧសភា ១៩៩៣ ដោយសេចក្តីសម្រេចចិត្តលេខ ៨២៧) ត្រង់មាត្រា២១(៤)(ខ)។
ច្បាប់លក្ខន្តិកៈរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសំរាប់ប្រទេសរ្វាំន់ដា ត្រង់មាត្រា ២០(៤)(ខ)។ លក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ, ចុះថ្ងៃទី១៧ កក្កដា ១៩៩៨, ត្រង់មាត្រា ៦៧(១)(ខ) ; និង១។
ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីលើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ, ចុះថ្ងៃទី១៧ តុលា ២០០៤ , ត្រង់មាត្រា ៣៥(២)(ខ)។

[96] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង* Prlic, សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ( យោបល់ដាច់ដោយឡែកពីគ្នារបស់លោកចៅក្រម Mumba.), ចុះថ្ងៃទី២៤ ធ្នូ ២០០៤។

[97] ក្រមសីលធម៌វិជ្ជាជីវៈ របស់តុលាការ ICTY, កំណត់សម្គាល់លេខ៦៣ *ខាងដើម*, មាត្រា១៤(ខ)។

[98] *ដូចគ្នានឹងខាងលើ* , មាត្រា ១៤ (ក)។

[99] *ដូចគ្នានឹងខាងលើ* , មាត្រា ១៤ ។

[100] ក្រមសីលធម៌វិជ្ជាជីវៈសម្រាប់មេធាវី នៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិ, ត្រង់មាត្រា ១៦(៣) ("ក្រមសីលធម៌តុលាការ ICC ") ។ ក្រមសីលធម៌វិជ្ជាជីវៈ របស់តុលាការ ICTY, កំណត់សម្គាល់លេខ៦៣ *ខាងដើម*, មាត្រា១៤(ង)។ ក្រមសីលធម៌វិជ្ជាជីវៈសម្រាប់មេធាវីសម្រាប់មេធាវី របស់តុលាការ ICTR, ត្រង់មាត្រា (៩)(៥)(ខ)(ii) ("ក្រមសីលធម៌តុលាការ ICTR ") ។

ICTR ការយល់ព្រមត្រូវបានទទួលស្គាល់ "ដរាបណាមេធាវីនៅតែអាចមានលទ្ធភាពដើម្បីបំពេញនូវរាល់កាតព្វកិច្ចផ្សេងៗទៀតទាំងអស់បាននៅឡើយ"[101]។

៣៥- សហមេធាវីការពារក្ដីដែលបានចាត់តាំងរួច នៅក្នុងចម្លើយតបរបស់ខ្លួន បានលើកយកមកសម្អាងដោយត្រឹមត្រូវនូវមាត្រា១៦(៣)នៃក្រមសីលធម៌វិជ្ជាជីវៈ("ក្រមវិជ្ជាជីវៈរបស់ ICC") នៅក្នុងរឿងនេះ៖ មេធាវីដែលមានទំនាស់ត្រូវបានអនុញ្ញាតឲ្យ "អាចស្វែងរកការយល់ព្រមដ៏ពេញលេញនិងដោយមានការជូនដំណឹងជាលាយលក្សណ៍អក្សរពីគ្រប់រាល់កូនក្តីទាំងអស់ដែលត្រូវបានរងផលប៉ះពាល់ដ៏មានប្រសិទ្ធិភាព ដើម្បីឲ្យបន្តធ្វើការការពារ"[102]។ ក៏ប៉ុន្តែ ការធ្វើវិភាគនេះខកខានមិនបានលើកឡើងបង្ហាញដោយត្រួសៗអំពីក្របខណ្ឌជាសរុបទាំងអស់នៃច្បាប់ ដែលសម្រាប់គ្រប់គ្រងលើទំនាស់ផលប្រយោជន៍របស់មេធាវីនៅចំពោះមុខតុលាការ ICC នោះឡើយ។ មាត្រាផ្សេងៗទៀតនៃក្រមវិជ្ជាជីវៈរបស់តុលាការ ICC បានបង្ហាញឲ្យឃើញថា ទោះបីជានៅពេលដែលការជៀសវាងនូវទំនាស់ណាមួយត្រូវបានអនុវត្តដោយត្រឹមត្រូវដោយមាន "ការយល់ព្រមដ៏ពេញលេញ និងដែលត្រូវបានជូនដំណឹង" ពិតប្រាកដនោះក៏ដោយ ដែលនៅទីនេះមិនត្រូវបានយកមកធ្វើការបង្ហាញជូននោះទេ ការលះបង់បែបនេះគួរតែអាចអនុញ្ញាតឲ្យបានតែក្នុងកាលៈទេសៈ ដែលមានការកំណត់ព្រំដែនយ៉ាងច្បាស់ និងយ៉ាងតឹងតែងតែប៉ុណ្ណោះ។

៣៦- ឧទាហរណ៍ដូចជា គោលការណ៍និងកាតព្វកិច្ចផ្សេងៗដែលមេធាវីការពារក្តីអនុវត្តភារកិច្ចរបស់ខ្លួន "ដោយសេរី"ហើយដែលមាន "ការគោរពចំពោះការសម្ងាត់នៃវិជ្ជាជីវៈ"[103] ដែលមិនចុះសម្រុងជាមួយនឹងការធ្វើការការពារដែលមានទំនាស់។ មាត្រា១២បានចែងថា៖ "មេធាវីមិនត្រូវធ្វើការការពារឲ្យកូនក្តីណាម្នាក់នៅក្នុងករណីរឿងក្តីណាមួយ[...]បើសិនជាករណីរឿងនោះ គឺជាករណីរឿងតែមួយជាមួយគ្នា ឬដែលមានការជាប់ទាក់ទងគ្នាយ៉ាងច្រើនទៅនឹងករណីរឿងមួយផ្សេងទៀតដែលក្នុងនោះមេធាវី ឬអ្នករួមសមាគមជាមួយមេធាវីនេះការពារឲ្យ ឬកាលពីមុនធ្លាប់ធ្វើការការពារឲ្យកូនក្តីម្នាក់ផ្សេងទៀត ហើយដែលផលប្រយោជន៍របស់កូនក្តីនោះ មានវិសមិតភាពជាមួយនឹងផលប្រយោជន៍របស់អតីតកូនក្តី លុះត្រាតែកូនក្តីនោះហើយនឹងអតីតកូនក្តីមានការយល់ព្រមនឹងគ្នា បន្ទាប់ពីការពិគ្រោះពិភាក្សាគ្នាមក"។

---

[101] *ដូចគ្នានឹងខាងលើ* (ក្រមសីលធម៌តុលាការ ICTR ) ត្រង់មាត្រា (៩)(៥)(ខ)(ii)។

[102] ក្រមសីលធម៌តុលាការ ICC, ត្រង់មាត្រា ១៦(៣)។

[103] ក្រមសីលធម៌តុលាការ ICC, ត្រង់មាត្រា ៥ និង ៦។

៣៧- មាត្រា១២ បានចែងបន្ថែមទៀតថា មាត្រានេះគឺ "មិនធ្វើឲ្យប៉ះពាល់ដល់មាត្រា១៦ឡើយ"[104]។ គោលការណ៍ជាដំបូងបង្អស់របស់មាត្រា១៦នោះ គឺថា៖ "មេធាវីត្រូវអនុវត្តនូវរាល់ការយកចិត្តទុកដាក់ដើម្បីធានាថាគ្មានទំនាស់ផលប្រយោជន៍កើតឡើងឡើយ។ មេធាវីត្រូវចាត់ទុកផលប្រយោជន៍របស់កូនក្តី ធំជាងផលប្រយោជន៍ផ្ទាល់របស់ខ្លួនឬផលប្រយោជន៍របស់ជនណាម្នាក់ផ្សេងទៀតរបស់អង្គការឬរបស់រដ្ឋ ដោយមានការគោរពដ៏ត្រឹមត្រូវចំពោះបទប្បញ្ញត្តិនានានៃច្បាប់លក្ខន្តិកៈ វិធានស្តីពីនីតិវិធីនិងភស្តុតាង ព្រមទាំងក្រមសីធម៌នេះ"។ ក៏ប៉ុន្តែ ដូចដែលបានធ្វើការកត់សម្គាល់ពីខាងលើបន្ទាប់មកទៀត មាត្រា១៦បន្តអនុញ្ញាតដល់មេធាវីដើម្បីឲ្យ "ស្វែងរកការយល់ព្រមដ៏ពេញលេញ និងដោយមានការជូនព័ត៌មានជាលាយលក្ខណ៍អក្សរអំពីរាល់កូនក្តីទាំងអស់ដែលបានទទួលរងផលប៉ះពាល់ដ៏មានសក្តានុពល ដើម្បីឲ្យបន្តធ្វើតំណាងតទៅទៀត"។ ហេតុដូចនេះទោះបីជាក្រមសីលធម៌របស់តុលាការ ICC អនុញ្ញាតឲ្យមានការលះបង់ផលប្រយោជន៍បានក៏ដោយ វាជាការច្បាស់លាស់ណាស់ថា គោលការណ៍នឹងគោលដៅផ្សេងទៀតនៃការប្រុងប្រយ័ត្នរបស់តុលាការ ICC ដែលប្រឆាំងទល់នឹងការអនុញ្ញាតឲ្យមានការធ្វើជាតំណាងដែលមានទំនាស់ ទោះបីបើសិនជាការលះបង់ទំនាស់ដែលមានសុពលភាពនានា ត្រូវទទួលរួចហើយក្តី។

៣៨- ជាបន្ថែមពីលើនេះ សហព្រះរាជអាជ្ញាអន្តរជាតិ សូមលើកឡើងជូនសហចៅក្រមស៊ើបអង្កេតដោយយោងទៅលើការវិភាគទៅលើយុត្តិសាស្ត្រនៃតុលាការ ICTY នៅក្នុងសំណើបឋមនេះ។ នៅក្នុងចម្លើយតបរបស់ខ្លួន សហមេធាវីដែលបានចាត់តាំងរួចបានព្យាយាមដើម្បីញែកឲ្យដាច់ពីគ្នា នៅក្នុងករណីយុត្តិសាស្ត្រនេះជាតិ ជាសំខាន់ គឺដោយផ្អែកលើមូលដ្ឋាននៃអង្គហេតុដែលបានចោទប្រកាន់អំពីភាពខុសគ្នា ទាក់ទងទៅនឹងភាពជិតស្និទ្ធនៃទំនាក់ទំនងរវាងថ្នាក់លើ-កូនចៅថ្នាក់ក្រោម។ ការពោលអះអាងអំពីអង្គហេតុនៅក្នុងចម្លើយតបត្រូវបានលើកឡើងនៅក្នុង **ផ្នែកទីIV** ខាងក្រោម។ រហូតមកទល់នឹងពេលនេះ ដោយសារតែករណីរឿងក្តីតាំងនេះបានផ្តល់ឲ្យនូវឧទាហរណ៍ ដោយផ្ទាល់អំពីច្បាប់ជាធរមាន និងអំពីបទដ្ឋានអន្តរជាតិ ស្តីពីទំនាស់ផលប្រយោជន៍នោះ ភាពជាប់ទាក់ទងគ្នានៃការវែកញែកហេតុផលខាងអង្គច្បាប់របស់ពួកគេត្រូវបានបង្ហាញឲ្យឃើញនៅទីនេះ។

៣៩- សហមេធាវីដែលបានចាត់តាំងរួចបានលើកសំអាងទៅលើ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY ដែលផ្តល់ការយល់ព្រមទៅលើការការពារឲ្យភាគីចំនួនពីររបស់មេធាវី

[104] ក្រមសីលធម៌តុលាការ ICC, ត្រង់មាត្រា ១៥(២)។

ពីព្រោះការទំនាក់ទំនងរវាងភាគីទាំងពីរនេះ "នៅដាច់ឆ្ងាយពីគ្នាណាស់"[105] ហើយដែលបានអះអាងថាមានស្ថានភាពស្រដៀងគ្នានឹងនៅទីនេះ។ ក៏ប៉ុន្តែ ការយោងទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះនេះបង្ហាញឲ្យឃើញថា ការទំនាក់ទំនងគ្នាកាន់តែនៅឆ្ងាយពីគ្នាជាងករណីចំពោះមុខទៅទៀត។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា ដោយសារមានភ័ស្តុតាងបង្ហាញអំពីភាពនៅដាច់ឆ្ងាយពីគ្នាដែលឈ្មោះរបស់ភាគីទីពីរ "មិនឃើញមាននៅក្នុងអម្លុងពេល" ជំនុំជម្រះក្តីរបស់ភាគីទីមួយនោះទេ[106]។ នៅក្នុងករណីរឿងចំពោះមុខនេះ ឈ្មោះរបស់ មាស មុត មិនគ្រាន់តែ "ឃើញមាន"នៅក្នុងអម្លុងពេលជំនុំជម្រះលើសំណុំរឿងលេខ០០២ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវបានជ្រើសរើស ដើម្បីធ្វើការកោះហៅឲ្យចូលមកធ្វើជាសាក្សីទៀតផង។

៤០- នៅក្នុងពេលជជែកតវ៉ាគ្នាថាសេចក្តីសម្រេចលើករណីរបស់ *Mejakić និងគូរកន* អាចញែកដាច់ដោយឡែកពីគ្នាបាននោះ[107] សហមេធាវីការពារក្តីដែលបានចាត់តាំងរួចបានលើកឡើងថា ព្រោះដោយសារតែ "អៀង សារី មិនត្រូវបានចោទប្រកាន់ថាជាថ្នាក់លើរបស់លោក មាស មុត ផ្ទាល់"[108]និងដោយសារតែ "លោក មាស មុត បានស្នើសុំសិទ្ធិនៅស្ងៀមមិនឆ្លើយទាំងនៅក្នុងសំណុំរឿងលេខ០០២ និងទាំងនៅក្នុងសំណុំរឿងលេខ០០៣"[109]នេះហើយទើបបានជាសេចក្តីសម្រេចលើករណីរឿងរបស់ *Mejakić* មិនត្រូវបានយកមកអនុវត្ត។ ក៏ប៉ុន្តែ ការពិនិត្យឡើងវិញមួយអំពីសេចក្តីសម្រេចលើករណីរឿងរបស់ *Mejakić និងគូរកន* បានបង្ហាញឲ្យឃើញអំពីភាពទាក់ទងគ្នា។ ដូចដែលបានធ្វើការកត់សម្គាល់នៅកន្លែងផ្សេង ចម្លើយរបស់ មាស មុត ដែលថា គាត់នឹងមិនផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿងលេខ០០២ ០០៣ ឬ០០៤ ដែលជាផ្នែកនៃការគូសបញ្ជាក់អំពីការលះបង់សិទ្ធិរបស់គាត់ជាជាងទំនាស់របស់សហមេធាវីដែលបានចាត់តាំងរួច។ គោលការណ៍នេះ ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងសេចក្តីសម្រេចលើករណីរឿងរបស់ *Mejakić* ដែលនៅក្នុងនោះបានចង្អុលបង្ហាញថា កូនក្តីណាម្នាក់ដែលមានមេធាវីដែលមានទំនាស់មិនអាចផ្តល់ការប្រឹក្សាយោបល់បានគ្រប់គ្រាន់អំពីថា តើកូនក្តី

[105] ឯកសារលេខ **D56/4/1** សំណើសុំបន្ថែមចំនួនទំព័រកំណត់ និងសារណារបស់សហមេធាវីស្តីពីទំនាស់ផលប្រយោជន៍ជាសក្តានុពល នៅក្នុងការការពារឲ្យលោក មាស មុត ក្នុងសំណុំរឿង ០០៣, ត្រង់កថាខណ្ឌទី១៧ ៤ មីនា ២០១៣។ ("ឯកសារលេខ **D56/4/1**ទំនាស់ផលប្រយោជន៍ជាសក្តានុពល ករណី មាស មុត")។

[106] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង* Jadranko Prlic *និងគូរកន*, សំណុំរឿងលេខ IT-04-74-PT,សេចក្តីសម្រេចលើណើសុំចាត់តាំងមេធាវី, ចុះថ្ងៃទី៣០ កក្កដា ២០០៤,កថាខណ្ឌទី៤៣។

[107] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង* *Zeljko Mejakic* *និងគូរកន*, សំណុំរឿងលេខ IT-02—65-AR73.1, សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់អយ្យការ ដើម្បីដោះស្រាយទំនាស់ផលប្រយោជន៍ទាក់ទងនឹងមេធាវី Jovan Simic, ចុះថ្ងៃទី៦ តុលា ២០០៤។

[108] ឯកសារលេខ **D56/4/1** ទំនាស់ផលប្រយោជន៍ជាសក្តានុពល របស់លោក មាស មុត, កំណត់សម្គាល់លេខ១១៥ *ខាងដើម* ត្រង់កថាខណ្ឌទី១៣។

[109] *ដូចគ្នានឹងខាងលើ*។

គួរតែផ្តល់សក្ខីកម្ម ដែរឬអត់?[110]។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ក៏បានថ្លែងផងដែរ អំពីការព្រួយបារម្ភរបស់ខ្លួនជាក់លាក់អំពីស្ថានភាពដែលអាចបានទទួល បើសិនជាសហមេធាវីដែលបានចាត់តាំងរួចត្រូវបានទទួលយកដើម្បីការពារឲ្យ មាស មុត ដែលការធ្វើបែបនេះ ទំនងជានឹងមានផលប៉ះពាល់ដល់ផលប្រយោជន៍របស់ អៀង សារី ដែលត្រូវបានការពារ[111]។

៤១- ទោះបីជា នៅក្នុងកាលៈទេសៈពិសេសដោយឡែកមួយចំនួននៃករណីរឿងក្តីរបស់ *Mejakić និងគូរកន* មានការចោទប្រកាន់អំពីការទទួលខុសត្រូវក្នុងការបញ្ជាដោយផ្ទាល់រវាងកូនក្តីពីរនាក់ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានបង្ហាញឲ្យឃើញពីសេចក្តីកង្វល់របស់ខ្លួន ទាក់ទងអំពីថាតើតើភ័ស្តុតាង និងផលប្រយោជន៍របស់កូនក្តីទាំងពីរនាក់ មានទំនាស់គ្នាយ៉ាងទំលំទូលាយជាងនេះបែបដូចម្តេចខ្លះ? ដោយធ្វើការកត់សម្គាល់ថា កូនក្តីម្នាក់ក្នុងចំណោមកូនក្តីទាំងពីរនាក់ "អាចផ្តល់ភ័ស្តុតាងស្តីពីរចនាសម្ព័ន្ធ"នៃជំរុំប្រមូលផ្តុំដែលកូនក្តីទីពីរបានគ្រប់គ្រង "ក៏ដូចជាបទល្មើសដោយឡែកនានាដែលបានប្រព្រឹត្តនៅក្នុងជំរំនេះ" ហើយជាលទ្ធផល "អាចបណ្តាលឲ្យមានផលប៉ះពាល់យ៉ាងធំ" ដល់ផលប្រយោជន៍របស់សាក្សីទីពីរ[112]។ នៅក្នុងស្ថានភាពនេះ ការការពារឲ្យកូនក្តីទាំងពីរ "ទំនងជាមិនអាចប្រែត្រឡប់បានធ្វើឲ្យខូចខាតដល់កិច្ចការគ្រប់គ្រងយុត្តិធម៌របស់តុលាការ"[113]។ គឺជាការពិតដូចគ្នានៅទីនេះដែរ។

៤២- ក្នុងការព្យាយាមញែកចេញឲ្យដាច់ពីគ្នា នូវកិច្ចដំណើរការនីតិវិធីនៅក្នុងករណីរឿងក្តីរបស់ *Prlić និងគូកន* ដែលក្នុងរឿងនេះលោក Karnavas ធ្លាប់បានដឹងយ៉ាងច្បាស់ណាស់ ជាថ្មីម្តងទៀតសហមេធាវីការពារក្តីដែលបានចាត់តាំងរួចបានផ្តោតទៅលើទំនាក់ទំនងរវាងថ្នាក់លើ និងកូនចៅក្រោមបង្គាប់[114]។ ក៏ប៉ុន្តែឈុតឆាកពិសេសដោយឡែកទាក់ទងនឹងអង្គហេតុរវាងករណីរឿងក្តីទាំងពីរនេះ ជៀសមិនផុតទេវាត្រូវតែខុសគ្នា គឺមិនបំរើដោយផ្ទាល់ដើម្បីកាត់បន្ថយនូវការសម្រេចតាមច្បាប់ដែលជាធរមាន និងដែលជាប់ពាក់ព័ន្ធនោះទេ។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍មានភាពច្បាស់លាស់ណាស់ថា "ទំនាស់ផលប្រយោជន៍ណាមួយរវាងមេធាវីនិងកូនក្តីដែលកើតឡើង នៅក្នុងស្ថានភាពណាមួយដោយសារមូលហេតុនៃកាលៈទេសៈមួយចំនួន ធ្វើការការពាររបស់មេធាវីនេះ បណ្តាលឲ្យខូចខាត

---

[110] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Zeljko Mejakic និងគូរកន,* កំណត់សម្គាល់លេខ១១០ *ខាងដើម* ត្រង់កថាខណ្ឌទី១៣។

[111] *ដូចគ្នានឹងខាងលើ* , ត្រង់កថាខណ្ឌទី១៥។

[112] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Zeljko Mejakic និងគូរកន,* កំណត់សម្គាល់លេខ១១០ *ខាងដើម* ត្រង់កថាខណ្ឌទី១៤។

[113] *ដូចគ្នានឹងខាងលើ* , ត្រង់កថាខណ្ឌទី១៥។

[114] ឯកសារលេខ **D56/4/1** ទំនាស់ផលប្រយោជន៍ជាសក្តានុពល ករណីលោក មាស មុត, កំណត់សម្គាល់លេខ១១៥ *ខាងដើម* ត្រង់កថាខណ្ឌទី១៤។

ឬអាចនឹងធ្វើឲ្យខូចខាតដល់ផលប្រយោជន៍របស់កូនក្តី និងផលប្រយោជន៍នៃយុត្តិធម៌ដែលធំជាងនេះ"[115]។ ហើយជាងនេះទៅទៀត អង្គជំនុំជម្រះសាលាឧទ្ធរណ៍មិនបានកម្រិតការរកឃើញរបស់ខ្លួនត្រឹមតែទំនាស់ទៅនឹងការទំនាក់ទំនងរវាងថ្នាក់លើ និងកូនចៅក្រោមបង្គាប់ប៉ុណ្ណោះទេ។ អង្គជំនុំជម្រះបាន សម្រេចយ៉ាងទូលំទូលាយជាងនេះថា អង្គជំនុំជម្រះសាលាដំបូងបានធ្វើដោយត្រឹមត្រូវក្នុងការរកឃើញថា ទំនាស់ដែលអាចហាមឃាត់កើតឡើង ក្នុងករណីបើមេធាវី "អាចនឹងមិនមានលទ្ធភាពការពារដល់ផលប្រយោជន៍ដ៏ប្រសើរបំផុតរបស់កូនក្តី ដោយការយកចិត្តទុកដាក់ម៉ត់ចត់ ឬនៅក្នុងពេលភ្លាមៗតាមការរំពឹងទុកបាន និងទៅតាមដែលលក្ខខណ្ឌបានតម្រូវចំពោះមេធាវី៖ ដែលស្នើសុំឲ្យធ្វើការសម្របសម្រួលគ្នាវិញអំពីផលប្រយោជន៍របស់កូនក្តី ជាជាងការខំបន្តធ្វើតទៅទៀតដោយពុំមានការរឹតត្បិតណាមួយដែលផ្ទុយទៅនឹងកាតព្វកិច្ចខាងវិជ្ជាជីវៈរបស់មេធាវី"[116]។

៤៣- ចំណែកឯនៅក្នុង*ករណីរឿងក្តីរបស់* Gotovina វិញ ជាថ្មីម្តងទៀត សហមេធាវីការពារក្តីដែលបានចាត់តាំងរួច បានទាមទារថា ការដែលគ្មានការទំនាក់ទំនងគ្នារវាងថ្នាក់លើ និងកូនចៅក្រោមបង្គាប់ស្រដៀងគ្នានេះ គឺជាកត្តាដើម្បីសម្រេចបញ្ចប់ និងថាសហមេធាវីការពារក្តីដែលបានចាត់តាំងរួច "នឹងមិនត្រូវបានធ្វើការរិតត្បឹតនៅក្នុងយុត្តិសាស្ត្រសម្រាប់ការពារក្តីរបស់ខ្លួន ទាក់ទងទៅនឹងកូនក្តីណាមួយក្នុងចំណោមកូនក្តីទាំងពីរភាគីនោះឡើយ"[117]។ ក៏ប៉ុន្តែ នៅក្នុងសេចក្តីសម្រេចលើករណីរបស់ *Gotovina* នេះផ្ទាល់តែម្តង សង្កត់ធ្ងន់ទៅលើស្ថានភាពដ៏ទូលំទូលាយដែលទំនាស់អាចនឹងកើតឡើងបាន ដោយធ្វើការកត់សម្គាល់ថា ទំនាស់ផលប្រយោជន៍បែបនេះកាន់តែជាក់ស្តែងថែមទៀត ក្នុងករណីបើសិនជាមេធាវីធ្វើតំណាងឲ្យជនជាប់ចោទចំនួនពីរនាក់ដែលយ៉ាងហោចណាស់ក៏មានផ្នែកខ្លះត្រូវបានចោទប្រកាន់អំពីអំពើឧក្រិដ្ឋដូចគ្នា ដែលបានប្រព្រឹត្តនៅក្នុងអម្លុងពេលជាមួយគ្នា និងនៅទីកន្លែងជាមួយគ្នាដែរ នេះគឺច្បាស់ណាស់ថា មិនមែនជាសភាពការណ៍តែមួយប៉ុណ្ណោះទេដែលទំនាស់ផលប្រយោជន៍អាចកើតឡើង......អ្វីដែលត្រូវបានហាមឃាត់នោះគឺការការពារនៅក្នុងពេលទន្ទឹមគ្នា ដែលនឹង ឬដែលអាចធ្វើការរំពឹងទុកបានដោយសមហេតុសមផលថា មានផលប៉ះ

---

[115] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Jadranko Prlic និងគូរកន,* កំណត់សម្គាល់លេខ១០៩ *ខាងដើម* ត្រង់កថាខណ្ឌទី២២។ [សង្កត់ន័យបន្ថែមដោយអក្សរទ្រេត].

[116] *ដូចគ្នានឹងខាងលើ* , ត្រង់កថាខណ្ឌទី៣០។

[117]ឯកសារលេខ **D56/4/1** ទំនាស់ផលប្រយោជន៍ជាសក្តានុពល ករណីលោក មាស មុត, កំណត់សម្គាល់លេខ១១៥ *ខាងដើម* ត្រង់កថាខណ្ឌទី១៩។

ពាល់ផ្ទុយគ្នា នៅក្នុងការការពារឲ្យកូនក្តីទាំងពីរនេះ”[118]។ នេះគឺរួមបញ្ចូលទាំងករណីបើភារកិច្ចដែលត្រូវស្មោះត្រង់របស់មេធាវី បណ្តាលឱ្យកូនក្តីទាំងពីរ “ត្រូវបានដកចេញពីក្នុងយុទ្ធសាស្ត្រសម្រាប់ការការពារក្តីណាមួយដែលនឹងធ្វើឲ្យឃើញថា “កូនក្តីម្នាក់ទៀត” មានការជាប់ពាក់ព័ន្ធ “ដោយមិនគិតពីថាតើ[កូនក្តីម្នាក់ទៀតនោះ]”បច្ចុប្បន្ននេះ កំពុងតែត្រូវបានចោទប្រកាន់អំពីបទឧក្រិដ្ឋកម្មទាំងនេះ ដែរ ឬក៏អត់នោះឡើយ”[119]។

៤៤- ជាចុងក្រោយ សហព្រះរាជអាជ្ញាអន្តរជាតិកត់សម្គាល់ឃើញថា សហមេធាវីចាត់តាំងពឹងផ្អែកលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងរឿងក្តី *Martic* លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចរបស់ក្រឡាបញ្ជីស្តីពីការចាត់តាំងមេធាវី។ សាលដីកានោះមិនមែនជាការសម្រេចចុងក្រោយឡើយទាក់ទងនឹងថាតើ នៅក្រោមកាលៈទេសៈដូច្នេះ ទំនាស់នៅមានជាអត្ថិភាពដែរ ឬអត់ ប៉ុន្តែ ដើម្បីជំនួសឱ្យការបញ្ជូនត្រឡប់ទៅក្រឡាបញ្ជីដើម្បីឱ្យសម្រេចជាថ្មីឡើងវិញ ដោយសារតែសេចក្តីសម្រេចដែលពួកគាត់កំពុងតែពិនិត្យឡើងវិញនោះ មានកង្វះខាតអង្គហេតុ និងសារធាតុរួមទាំង “មិនបានផ្តល់ព័ត៌មានណាមួយអំពីប្រភេទនៃទំនាស់ផលប្រយោជន៍ ដែលតាមមតិរបស់ក្រឡាបញ្ជីថាមាន។ សេចក្តីសម្រេចនោះមិនបានយោងសំដៅអនុកថាខណ្ឌជាក់ស្តែងនៃមាត្រា៩ នៃក្រមសីលធម៌ដែលសេចក្តីសម្រេចលើកទីពីររបស់ក្រឡាបានពឹងផ្អែក [...] ថាមិនបានផ្តល់ព័ត៌មានអំពីអង្គហេតុជាដើមចមនៃរឿងក្តីនោះ ថាខ្លួនគ្រាន់តែពិចារណាថា “ការចាត់តាំង លោក Kastratovic ជាតំណាងឲ្យជនជាប់ចោទ អាចនាំទៅរកផលប៉ះពាល់ផ្ទុយគ្នាមួយចំពោះសិទ្ធិរបស់ជនជាប់ចោទ និងជនសង្ស័យនៅក្រោមកាលៈទេសៈនាពេលនេះ ថាប៉ុន្តែសេចក្តីសម្រេចនេះមិនបានពន្យល់អំពីប្រភេទ និងវិសាលភាពនៃ “កាលៈទេសៈបច្ចុប្បន្ន” និង “ផលប៉ះពាល់ផ្ទុយគ្នា” ទៅលើសិទ្ធិរបស់ជនជាប់ចោទ”[120] ទេ។

៤៥- ***តុលាការអន្តរជាតិទានាទទួលស្គាល់អំណាចរបស់តុលាការខ្លួនឯង នៅក្នុងការការពារជំនឿទុកចិត្តរបស់សាធារណជន និងការគ្រប់គ្រងយុត្តិធម៌នៅក្នុងការចាត់តាំងមេធាវីការពារក្តី។*** សារាចរណែនាំរបស់តុលាការ ICTY ស្តីពីការចាត់តាំងមេធាវីការពារក្តី ពិចារណាថាតើ ការតែងតាំងនោះ

---

[118] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Ante Gotovina និងគូរកន*, សំណុំរឿងលេខ IT-06-90-AR73.2, សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍លើបញ្ហាបន្ទាន់បន្ទិររបស់ Ivan Čermak's ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីទំនាស់ផលប្រយោជន៍របស់មេធាវី Čedo Prodanović និង Jadranka Sloković, ចុះថ្ងៃទី២៩ មិថុនា ២០០៧, កថាខណ្ឌទី២៤ និង២៥។

[119] *ដូចគ្នានឹងខាងលើ* , ត្រង់កថាខណ្ឌទី២៧។

[120] *រដ្ឋអាជ្ញា ទល់នឹង Milan Martic*, សំណុំរឿងលេខៈ IT-95-11-PT, សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចរបស់ក្រឡាបញ្ជី, ២ សីហា ២០០២, ទំព័រ៥។

"ទំនងជាបន្ថយជំនឿទុកចិត្តរបស់សាធារណជននៅក្នុងតុលាការអន្តរជាតិ ឬនៅក្នុងការគ្រប់គ្រងយុត្តិធម៌ដែរ ឬទេ"[121] ដែលនេះជាបុរេវិនិច្ឆ័យមួយក្នុងចំណោមបុរេវិនិច្ឆ័យនានាសម្រាប់ការចាត់តាំងមេធាវី។

៤៦- ***តុលាការអន្តរជាតិនានាទទួលយកប្រភេទនៃទំនាស់ដែលមិនអាចផ្សះផ្សាបាន បើសិនជាមានការព្រមព្រៀងនៅក្នុងការការពារ និងធ្វើឱ្យមានបុរេនិច្ឆ័យចំពោះការគ្រប់គ្រងយុត្តិធម៌។*** នៅចំពោះមុខតុលាការ ICTY មេធាវីត្រូវបានរាំងមិនឱ្យការពារឱ្យកូនក្តីច្រើននាក់ ដោយមានទំនាស់ផលប្រយោជន៍ សូម្បីតែកូនក្តីទាំងនោះបានផ្តល់នូវ "ការយល់ព្រមពេញលេញ និងបានដឹងយ៉ាងជ្រួតជ្រាប" ក៏ដោយ ប្រសិនបើ "ការយល់ព្រមដូច្នេះទំនងជានឹងមានបុរេនិច្ឆ័យ ដែលមិនអាចវិលត្រឡប់វិញបានចំពោះការគ្រប់គ្រងយុត្តិធម៌[122]។ វិធាននេះច្បាស់ណាស់ថា អនុវត្តបានចំពោះទាំងកូនក្តីបច្ចុប្បន្ន និងអតីតកូនក្តី[123] ដោយអង្គជំនុំជម្រះសាលាឧទ្ធរណ៍បានរកឃើញយ៉ាងច្បាស់ដូច្នេះនៅក្នុងរឿងក្តី *Mejakić និងគូកន*.,[124] ខណៈដែលរឿងក្តី *Prlić និងគូកន*., អង្គជំនុំជម្រះដែលបានទទួលស្គាល់ថា ទំនាស់ផលប្រយោជន៍មួយដែលកើតឡើង វាមិនត្រឹមតែជាបុរេវិនិច្ឆ័យដ៏មានសក្តានុពលចំពោះផលប្រយោជន៍របស់កូនក្តីម្នាក់ប៉ុណ្ណោះទេ ប៉ុន្តែជាហានិភ័យនៃបុរេវិនិច្ឆ័យចំពោះ "ផលប្រយោជន៍នៃយុត្តិធម៌ធំជាងនេះ"[125]ទៅទៀត។ ន័យត្រង់នៃមាត្រា ១៤(ង)(២)(ii) នៃក្រមតុលាការ ICTY ឃ្លាដែលថា "ការយល់ព្រមពេញលេញ និងបានដឹងយ៉ាងជ្រួតជ្រាប" បានព្យាបាលទៅលើទំនាស់ផលប្រយោជន៍ "<u>ឱ្យតែ</u>ការយល់ព្រមដូច្នេះ ទំនងជាមិនមែនបុរេនិច្ឆ័យដែលមិនអាចវិលត្រឡប់វិញបានចំពោះការគ្រប់គ្រងយុត្តិធម៌"។ ការជាប់ជំពាក់វាក់វិននៃរបបគំហើញមួយអំពីបុរេវិនិច្ឆ័យដែលមិនអាចវិលត្រឡប់វិញបាន - <u>ជាការវាយតម្លៃមួយ</u>របស់តុលាការទៅលើការសាកល្បងសត្យានុម័ត - នឹងមានន័យថា គ្មានការយល់ព្រមណាមួយពីកូនក្តីអាចនឹងធ្វើទៅបានឡើយនៅក្នុងកាលៈទេសៈដូច្នេះ។ និយាយឱ្យសាមញ្ញ ទំនាស់ផលប្រយោជន៍ដូច្នេះមិនអាចផ្សះផ្សាបានឡើយ។

---

[121] សារាចរណែនាំរបស់តុលាការ ICTY ស្តីពីការចាត់តាំងមេធាវីការពារក្តី, សារាចរ លេខ 1/94, ដែលបានកែប្រែថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៤, IT/73/វិសោធនកម្មលើកទី១៩, មាត្រា១៤(ក)(vii)។

[122] ក្រមសីលធម៌វិជ្ជាជីវៈតុលាការ ICTY, កំណត់សម្គាល់*ខាងដើម* លេខ៦៣, ត្រង់មាត្រា១៤(ង)។

[123] *ឯកសារដដែលដូចខាងលើ,* ត្រង់១៤(ង)(១) ("ស្មាក្តីត្រូវជម្រាបជូនកូនក្តីបច្ចុប្បន្ន និងអតីតកូនក្តីនិមួយៗដែលរងការប៉ះពាល់ជាសក្តានុពលឱ្យបានទាន់ពេលវេលា និងពេញលេញ...")។

[124] *រដ្ឋអាជ្ញា ទល់នឹង Zeljko Mejakic និងគូកន,* កំណត់សម្គាល់*ខាងដើម* លេខ១១០។

[125] *រដ្ឋអាជ្ញា ទល់នឹង Jadranko Prlic និងគូកន,* កំណត់សម្គាល់*ខាងដើម* លេខ១០៩, ត្រង់កថាខណ្ឌទី២២។

៤៧- យន្តការដែលទើបត្រូវបានបង្កើតថ្មីសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ (MICT) ដែលការបង្កើតនេះ បានពង្រីកទៅដល់មុខងារជាក់លាក់មួយចំនួននៅពេលអនាគត ទាំងសម្រាប់តុលាការ ICTY និងតុលាការ ICTR ហើយក្របខណ្ឌច្បាប់របស់វាត្រូវបានគេជម្រាបឲ្យដឹងតាមរយៈបទពិសោធន៍នៃកិច្ចប្រតិបត្តិការរបស់បណ្ដាតុលាការដែលបានបង្កើតពីមុនៗ ក៏ទទួលយកប្រភេទនៃទំនាស់ផលប្រយោជន៍ដែលកើតចេញពីការការពារឲ្យទាំងកូនក្ដីបច្ចុប្បន្ន និងទាំងអតីតកូនក្ដីផងដែរ។ ក្រមសីលធម៌សម្រាប់មេធាវីការពារក្ដីដែលបង្ហាញខ្លួននៅចំពោះមុខយន្តការនេះ ដែលបានចូលជាធរមាននាពេលថ្មីៗនេះក្នុងខែវិច្ឆិកា ឆ្នាំ២០១២ អនុម័តនូវបទដ្ឋានច្បាប់មួយដូចគ្នាបេះបិទទៅនឹងមាត្រា១៤(ង)(២)(ii) នៃក្រមសីលធម៌របស់តុលាការ ICTY[126]។

៤៨- ***តុលាការអន្តរជាតិនានាទទួលស្គាល់ថា ការលះបង់សិទ្ធិជាទូទៅ ឬជាចំហរមិនអាចព្យាបាលទំនាស់ផលប្រយោជន៍ដ៏មានសក្ដានុពលបានឡើយ។*** ដូចអង្គជំនុំជម្រះសាលាឧទ្ធរណ៍ក្នុងរឿងក្ដី *Prlić* សង្កេតឃើញថា ការលះបង់សិទ្ធិនៅក្នុងការយល់ព្រមចំពោះទំនាស់ផលប្រយោជន៍ នឹងទៅជាគ្មានប្រសិទ្ធភាព ប្រសិនបើអាជ្ញាធរតុលាការដែលទទួលបន្ទុកខាងត្រួតពិនិត្យមិនជឿថាបុគ្គលដែលផ្ដល់ការលះបង់សិទ្ធិនោះ "បានដឹងពីភាពជំពាក់ជំពិន និងព្រំដែនកំណត់ទាំងអស់ដែលអាចមាន ដែលការការពារជាប់ឥតដាច់[របស់ស្នាក្ដី] ចំពោះ[កូនក្ដីម្នាក់] អាចមានទៅលើយុត្តិសាស្ត្រការពារក្ដីឲ្យ[កូនក្ដីទីពីរ]"[127]។ ការណ៍នេះរួមមាន ភាពជំពាក់ជំពិនចំពោះសិទ្ធិ ដូចជាបុព្វសិទ្ធិរវាងមេធាវី និងកូនក្ដី ដែលនៅមាននៅក្រោយមរណភាព[128]។ ស្រដៀងគ្នានេះ មតិអំពីក្រមសីលធម៌របស់អ្នកច្បាប់ដែលបានប្រគល់ឲ្យដោយគណៈមេធាវីទីក្រុងវ៉ាស៊ីនតុង ឌីស៊ី (សហរដ្ឋអាមេរិក) បានកំណត់ថា "កាលណាកូនក្ដីលើកយកកាលៈទេសៈជាក់លាក់ផ្សេងៗមកពិចារណាកាន់តែតិច ហើយបើសិនជាកូនក្ដីនោះមិនមែនជាមនុស្សសាំញ៉ាំ ភាពទំនងក៏កាន់តែតិចដែលថា ការលះបង់សិទ្ធិជាមុននៅមាន

---

[126] ក្រមសីលធម៌សម្រាប់មេធាវីការពារក្ដីដែលបង្ហាញខ្លួននៅចំពោះមុខយន្តការនេះ, MICT/6 (១៤ វិច្ឆិកា ២០១២)។

[127] *រដ្ឋអាជ្ញា ទល់នឹង Prlić និងគូកន,* សំណុំរឿងលេខ: IT-04-74-AR73.1, សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ Bruno Stojic ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្ដីពីសំណើសុំចាត់តាំងមេធាវី (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY), ២៤ វិច្ឆិកា ២០០៤, កថាខណ្ឌទី២៧។

[128] សូមមើល *Swidler & Berlin និងគូកន ទល់នឹងសហរដ្ឋ,* 124 F.3d 230, ២៥ មិថុនា ១៩៩៨ (កត់សម្គាល់ថា បុព្វសិទ្ធិនៅចិតស្លេរទៅបានអាស្រ័យដោយ "កូនក្ដីអាចមានកង្វល់អំពីកេរ្ដិ៍ឈ្មោះ, ការទទួលខុសត្រូវផ្នែកស៊ីវិល ឬគ្រោះថ្នាក់ជាយថាហេតុចំពោះគ្រួសារ ឬមិត្តភក្ដិ")។

សុពលភាពដដែល”[129]។ មានយុត្តាធិការខ្លះនៃដែនដីសហរដ្ឋអាមេរិក ក៏តម្រូវឱ្យមេធាវីដែលស្វែងរកការលះបង់សិទ្ធិពីកូនក្តី សូមឱ្យផ្តល់យោបល់ទៅកូនក្តីនោះឱ្យទៅរកមេធាវីខាងក្រៅ[130]។

## IV. **អង្គហេតុពាក់ព័ន្ធ**

៤៩- ឧក្រិដ្ឋកម្មទាំងឡាយដែលស្ថិតក្រោមកិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ ដែលជាប់ពាក់ព័ន្ធដោយផ្ទាល់ជាមួយ មាស មុត រួមមានការចាប់ខ្លួន និងការបញ្ជូនពួកកម្មាភិបាលពីតំបន់បោសសម្អាតនៃកងពលធំ១៦៤ ទៅកាន់មន្ទីរស-២១[131] ព្រមទាំងការចាប់ខ្លួនដោយកងទ័ពជើងទឹករបស់កម្ពុជាប្រជាធិបតេយ្យចំពោះជនជាតិវៀតណាម ថៃ និងជនបរទេសដទៃទៀតដែលបានបញ្ជូនទៅមន្ទីរស-២១[132]។ សមាជិកកងទ័ពបដិវត្តកម្ពុជា ត្រូវបានបញ្ជូនពីគ្រប់បណ្តាកងពលធំស្របច្បាប់ទាំងអស់ នៃកងទ័ពបដិវត្តកម្ពុជា រួមទាំងកងពល ១៦៤[133] ផង។ ក្រុមអ្នកទោសដែលមានចំនួនច្រើនជាគេនៅមន្ទីរស-២១ គឺជាក្រុមកម្មាភិបាលនៃកងទ័ពបដិវត្តកម្ពុជាដែលត្រូវបានបោសសម្អាត រួមទាំងសមាជិកនៃកងពលធំ ១៦៤[134]។ កសព បានកំណត់អត្តសញ្ញាណកម្មាភិបាលចំនួន ៣៩៦ នាក់ នៃកងពលធំ ១៦៤ ដែលបានជាប់គុកនៅមន្ទីរស-២១[135]។ មាស មុត ក៏ស្ថិតនៅក្រោមកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣ ដែរចំពោះការចូលរួមនៃកងពលធំ ១៦៤ ក្នុងការវាយប្រហារផ្នែកយោធាទៅក្នុងប្រទេសវៀតណាមនៅចុងឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨[136] និងត្រូវបានចោទថា មានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះការចូលរួមក្នុងសហកម្មឧក្រិដ្ឋកម្មរួម ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មនានានៅទីតាំងការ

---

[129] គណៈមេធាវី DC, មតិ ៣០៩: ការលះបង់សិទ្ធិជាមុនចំពោះទំនាស់ផលប្រយោជន៍ អាចរកបានតាមរយៈ http://www.dcbar.org/for_lawyers/ethics/legal_ethics/opinions/opinion309.cfm.

[130] សូមមើល *ឧទាហរណ៍* វិធានស្តីពីក្រមសីលធម៌វិជ្ជាជីវៈនៃរដ្ឋអូរីហ្គិន ដែលបានកែសម្រួលថ្ងៃទី១ មករា ២០១៣, វិធាន១.៨(ក)(២) ទំនាស់ផលប្រយោជន៍: កូនក្តីបច្ចុប្បន្ន: វិធានជាក់លាក់ (“មេធាវីមិនត្រូវធ្វើការប្តោះប្តូរជំនួញណាមួយជាមួយកូនក្តី ឬទទួលយកជាកម្មសិទ្ធិដោយចេតនា ការកាន់កាប់ ប្រាតិភោគ ឬផលប្រយោជន៍ជាប្រាក់កាសដទៃទៀតដែលផ្ទុយនឹងកូនក្តីណាម្នាក់ ដរាបណាៈ..កូនក្តីត្រូវបានជូនយោបជាលាយល័ក្ខណ៍អក្សរអំពីភាពពេញចិត្តនៃការស្វែងរកនោះ និងត្រូវបានឱកាសឱ្យស្វែងរកមេធាវីផ្នែកច្បាប់ដែលឯករាជ្យស្តីពីការផ្លាស់ប្តូរនោះ”)។

[131] **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីរ ទាក់ទងនឹងកងទ័ពបដិវត្តន៍កម្ពុជានៃកម្ពុជាប្រជាធិបតេយ្យ, ២០ វិច្ឆិកា ២០០៨ ត្រង់កថាខណ្ឌទី៤៣, ៥២។

[132] **D1** *ឯកសារដដែលដូចខាងលើ*, ត្រង់កថាខណ្ឌទី៦០, ៦១។

[133] **D1** *ឯកសារដដែលដូចខាងលើ*, ត្រង់កថាខណ្ឌទី៤៣។

[134] **D427** ដីកាដំណោះស្រាយ, ត្រង់កថាខណ្ឌទី៤២៤។

[135] **D1.3.11.3** បញ្ជីឈ្មោះអ្នកដែលត្រូវបានគេចាប់ខ្លួនពីកងពលធំ ១៦៤, ២០ វិច្ឆិកា ២០០៨។

[136] **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីរ ទាក់ទងនឹងកងទ័ពបដិវត្តន៍កម្ពុជានៃកម្ពុជាប្រជាធិបតេយ្យ, ២០ វិច្ឆិកា ២០០៨ ត្រង់កថាខណ្ឌទី៦២។

ដ្ឋានព្រលានយន្តហោះខេត្តកំពង់ឆ្នាំង[137]។ មាស មុត ត្រូវបានចោទប្រកាន់ថាជាសមាជិកមួយរូបនៃគណៈកម្មាធិការមជ្ឈិមផង និងជាប្រធានកងពលធំយោធាមជ្ឈិមផង[138]។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនៃសំណុំរឿង០០៣ ចោទប្រកាន់ថា អគ្គសេនាធិការរាយការណ៍ជូនគណៈកម្មាធិការយោធា ដែលជាអនុគណៈកម្មាធិការនៃគណៈកម្មាធិការអចិន្ត្រៃយ៍ ឬគណៈកម្មាធិការមជ្ឈិម[139]។

៥០- អៀង សារី ត្រូវបានចោទប្រកាន់ពីឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តនៅ ស-២១[140] នៅការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង[141] ហើយនិងពីឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តដោយពួកយោធានៅលើទឹកដីវៀតណាម ក្នុងចន្លោះពាក់កណ្ដាលឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨[142]។ អៀង សារី ធ្លាប់បានសារភាពថា គណៈកម្មាធិការយោធាបានរាយការណ៍ទៅគណៈកម្មាធិការអចិន្ត្រៃយ៍ ក្រោយពេលបានទទួលរបាយការណ៍នានាពីមូលដ្ឋាន[143]។

៥១- អៀង សារី និង មាស មុត ទាំងពីរនាក់នេះជាសមាជិកគណៈកម្មាធិការមជ្ឈិមបក្ស។ សមាជិកភាពរបស់ មាស មុត នៅក្នុងគណៈកម្មាធិការមជ្ឈិម ត្រូវបានផ្ដល់សក្ខីកម្មដោយ ខៀវ សំផន ជាសមាជិកដូចគ្នានៅក្នុងគណៈកម្មាធិការមជ្ឈិម[144]។ គណៈកម្មាធិការមជ្ឈិម ត្រូវបានកំណត់និយមន័យដោយលក្ខន្តិកៈ បកក ថាជា "អង្គការប្រតិបត្តិការខ្ពស់ជាងគេបំផុតទូទាំងប្រទេស" និងទទួលខុសត្រូវចំពោះការអនុវត្តមាគ៌ារបស់បក្ស, ណែនាំអង្គការភូមិភាគ និងតំបន់, និងគ្រប់គ្រងសមាជិកក្នុងបក្សទាំងមូល[145]។

៥២- ទូរលេខមួយ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ ផ្ញើចេញពី មាស មុត ជូនទៅ គណៈកម្មាធិការ៨៧០ ត្រូវបានចម្លងជូន ប៉ុល ពត, នួន ជា, អៀង សារី, វន វេត និង សុន សេន។ នៅក្នុងទូរលេខនោះ មាស

---

[137] **D1** *ឯកសារដដែលដូចខាងលើ,* ត្រង់កថាខណ្ឌទី៤៧-៥១, ៩៦-៩៧។

[138] **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីរ ទាក់ទងនឹងកងទ័ពបដិវត្តន៍កម្ពុជានៃកម្ពុជាប្រជាធិបតេយ្យ, ២០ វិច្ឆិកា ២០០៨ ត្រង់កថាខណ្ឌទី៣។

[139] **D1** *ឯកសារដដែលដូចខាងលើ,* ត្រង់កថាខណ្ឌទី១៣។

[140] **CF002-D427** ដីកាដំណោះស្រាយ, ២៨ កញ្ញា ២០១២ ត្រង់កថាខណ្ឌ ៤២៤, ៤៣៣។

[141] **CF002-D427** ដីកាដំណោះស្រាយ, ២៨ កញ្ញា ២០១២ ត្រង់កថាខណ្ឌ ៣៨៣-៣៨៨។

[142] *ដដែលដូចមុន,* ត្រង់កថាខណ្ឌ ៨៣៦-៨៤០។

[143] **D1** *ដដែលដូចមុន,* ត្រង់កថាខណ្ឌ ១២២។ **E3/94** បទសម្ភាសន៍របស់លោក អៀង សារី ដោយលោកស្រី Elizabeth Becker, ២២ កក្កដា ១៩៨១, លេខERN 00342500-00342504។ **D4.1.1032** នៅក្នុង **CF003**។

[144] **D1.3.33.15** កំណត់ហេតុស្ដួរចម្លើយ ខៀវ សំផន, ទំព័រទី ១១។

[145] **CF002-E3/28** លក្ខន្តិកៈបក្សកុម្មុយនីសកម្ពុជា, ៣០ មេសា ២០០៩, មាត្រា ៧(១), ២៣។

មុត បានអះអាងបញ្ជាក់ពីការទទួលបានមតិណែនាំរបស់បក្ស ចំពោះជនជាតិវៀតណាម ហើយបានប្តេជ្ញា "ការពារបក្ស" និង "បោសសម្អាត គ្មានស្ទាក់ស្ទើរ សមាសភាពបង្កប់របស់ខ្មាំង ជាយួន និងខ្មាំងដទៃទៀត"[146]។ របាយការណ៍មួយពី មាស មុត ចុះថ្ងៃទី១ ខែមេសា ឆ្នាំ១៩៧៨ ដែលបានចម្លងជូន ប៉ុល ពត, នួន ជា និង អៀង សារី បានរាយការណ៍អំពីការចាប់ខ្លួន និងការសម្លាប់ពួកវៀតណាមចំនួន ១២០នាក់[147]។

៩៣- ដោយបន្ថែមលើនេះ សហចៅក្រមស៊ើបអង្កេតបានកត់សម្គាល់ថា អ្នកនេសាទថៃត្រូវបានពួកមន្ត្រីផ្លូវការកងពលធំលេខ១៦៤ នៃកម្ពុជាប្រជាធិបតេយ្យ ចាប់ខ្លួន ក្រោមបញ្ជារបស់ មាស មុត ហើយបន្ទាប់មក ត្រូវបានសម្លាប់ចោល ឬ បាត់ខ្លួន ឬ ឋិតនៅក្រោមពលកម្មដោយបង្ខំ[148]។ ជាបន្តបន្ទាប់មកទៀត នៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ១៩៧៨ ដោយមានសំណើពីរដ្ឋមន្ត្រីការបរទេសថៃ អៀង សារី បានសន្យានឹងរដ្ឋាភិបាលថៃថា ពួកអ្នកទោសថៃនឹងត្រូវបានដោះលែងបន្ទាប់ពីការពិគ្រោះយោបល់ជាមួយនឹងពួកមន្ត្រីកម្ពុជា។ ដោយប្រមាណ នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ១៩៧៨ ពួកមន្ត្រីខ្មែរក្រហមបានជូនដំណឹងទៅរដ្ឋមន្ត្រីការបរទេសថៃថា ពួកខ្លួនបានត្រៀមស្រេចហើយនឹងដោះលែងអ្នកនេសាទថៃចំនួន ៥(ប្រាំ)នាក់ នៅចន្លោះថ្ងៃទី ២៧ និង ២៩ ខែមីនា ឆ្នាំ១៩៧៨។ នៅថ្ងៃទី១ ខែមេសា មាស មុត ត្រូវបានលើកឡើងចោទប្រកាន់ថា បានរាយការណ៍តាមទូរស័ព្ទថា មានការ ពន្យារពេលនៅក្នុងការដោះលែង "ពួកសៀម" ដែលសារនេះត្រូវបានគេធ្វើប្រតិចារឹក ហើយបានចម្លងជូន ក្នុងចំណោមអ្នកទាំងនោះមាន អៀង សារី (ក្រោមឈ្មោះក្លែងថា "អ៊ំវ៉ាន់")។ ក្រោយមក នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៧៨ មានកាសែតមួយបានរាយការណ៍ថា មួយខែមុននេះ មានអ្នកនេសាទថៃចំនួន១០(ដប់)នាក់ ត្រូវបានគេលើកឡើងចោទប្រកាន់ថាត្រូវបានសម្លាប់ដោយពួកខ្មែរក្រហម ហើយបានរាយការណ៍ផងដែរអំពីការសន្យាដែល អៀង សារី បានធ្វើជាមួយនឹងរដ្ឋាភិបាលថៃ ដែលថាខ្មែរក្រហមនឹងឈប់សម្លាប់ពួកអ្នកស្រុកថៃ ហើយថាវាសនារបស់ពួកអ្នកនេសាទថៃចំនួន៣៣នាក់

---

[146] **D1.3.34.60** ទូរលេខរបស់យោធាកម្ពុជាប្រជាធិបតេយ្យ ផ្ញើដោយ មាស មុត ក្រោមចំណងជើងថា "ទូរលេខ០០ - ៣៥៤ខ្ទង់ - គោរពជូនគណៈ ម.៨៧០" ។

[147] **IS18.59** សារទូរស័ព្ទសម្ងាត់ នៅថ្ងៃទី ១/៤/៧៨៖ របាយការណ៍អំពីចំនួនសរុបខ្មាំងយួនដែលបានចាប់ខ្លួន និងបាញ់សម្លាប់, ២៨ មេសា ២០០៨, *សូមអាន* D4.1.635។

[148] **D56/3** សេចក្តីសម្រេច និង ដីកាចាត់កាលវិភាគពាក់ព័ន្ធនឹងសំណើសុំឲ្យចាត់តាំងសហមេធាវីការពារក្តីដែលបានចាត់តាំង, ១១ កុម្ភៈ ២០១៣, កថាខណ្ឌ ២២។

ដែលបានឃាត់ខ្លួននៅក្នុងជំរំពលកម្មក្នុងប្រទេសកម្ពុជា និងត្រូវបានដោះស្រាយទៅតាមករណីនីមួយៗ[149]។

៩៤- នៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៣ ក្រោយពេលមរណភាពរបស់ អៀង សារី និងក្រោយពេលសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងថា កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងគាត់ត្រូវបានបញ្ចប់[150] កាសែតមួយនៅក្នុងប្រទេសកម្ពុជាបានរាយការណ៍ថា សហមេធាវីការពារក្ដីដែលបានចាត់តាំងបានចូលរួមនៅក្នុងពិធីបូជាសព អៀង សារី[151]។ អត្ថបទកាសែតនោះបានកត់សម្គាល់ថា សហមេធាវីការពារក្ដីដែលបានចាត់តាំង បានយកស៊ុមរូបថតដែលមានរូបពួកគេជាមួយនឹង អៀង សារី នៅក្នុងអង្គជំនុំជម្រះ ធ្វើជាអំណោយជូនទៅកូនប្រុស អៀង សារី ដែលបានធ្វើបដិសណ្ឋារកិច្ច "យ៉ាងកក់ក្ដៅ" ដល់ពួកគេ។ លោក Karnavas ត្រូវបានគេដកស្រង់សម្ដីថាបាននិយាយថា៖ "រូបថតនេះ ជាស៊ុមនៃទំនាក់ទំនងរបស់ខ្ញុំជាមួយនឹងលោក អៀង សារី។ បន្ទាប់ពីប្រាំឆ្នាំ និងប្រាំខែនៃការងារធំនៅក្នុងរឿងក្ដីនេះ ដែលជាការងារមួយដ៏ពិបាកបំផុតដែលខ្ញុំមិនដែលបានជួបនោះ គឺវាជាការមួយដ៏ពិបាកបំផុត បើមិនបានជាប់ជំពាក់ចិត្តទៅនឹងកូនក្ដី"[152]។

៩៥- នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៣ ក្រោយពេលមរណភាពរបស់ អៀង សារី និងក្រោយពេលសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងថា កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងគាត់ត្រូវបានបញ្ចប់[153] អ៊ីមែលមួយត្រូវបានផ្ញើចេញពីអាសយដ្ឋានអ៊ីមែលរបស់លោក Karnavas ជូនទៅបុគ្គលិកផ្សេងៗរបស់ អ.វ.ត.ក, ពួកអ្នកតាមដានឃ្លាំមើលការជំនុំជម្រះក្ដី និងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលដទៃទៀត, បណ្ដាញសារព័ត៌មាន ហើយនិងអ្នកដទៃផ្សេងទៀត ដោយបានភ្ជាប់ "សេចក្ដីប្រកាសព័ត៌មានរបស់មេធាវីការពារក្ដី អៀង សារី ស្ដីពីការប្រកាសដាក់ឲ្យប្រើប្រាស់នូវគេហទំព័រថ្មីរបស់ខ្លួន"[154]។ សេចក្ដីប្រកាសព័ត៌មាននោះបានប្រកាសថា "ថ្ងៃនេះ ថ្ងៃទី២៨ ខែមីណា ឆ្នាំ២០១៣ ក្រុមមេធាវីការពារក្ដី អៀង សារី បានដាក់ឲ្យប្រើប្រាស់នូវគេហទំព័រថ្មីរបស់ខ្លួន"។ គេបានកត់

---

[149] **D56/3** សេចក្ដីសម្រេច និង ដីកាចាត់កាលវិភាគពាក់ព័ន្ធនឹងសំណើសុំឲ្យចាត់តាំងសហមេធាវីការពារក្ដីដែលបានចាត់តាំង, ១១ កុម្ភៈ ២០១៣, កថាខណ្ឌ ២២។

[150] **E270/1** សេចក្ដីសម្រេចលើការបញ្ចប់កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទ អៀង សារី , ១៤ មីនា ២០១៣។

[151] កាសែត ឌឹ ឃែមបូឌា ដេលី, *សពលោក អៀង សារី ត្រូវបានបូជានៅក្នុងពិធីឈាបនកិច្ចយ៉ាងធំដុំ*, ២២ មីនា ២០១៣។

[152] កាសែត ឌឹ ឃែមបូឌា ដេលី, *សពលោក អៀង សារី ត្រូវបានបូជានៅក្នុងពិធីឈាបនកិច្ចយ៉ាងធំដុំ*, ២២ មីនា ២០១៣។

[153] **E270/1** សេចក្ដីសម្រេចលើការបញ្ចប់កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទ អៀង សារី , ១៤ មីនា ២០១៣។

[154] អ៊ីមែល ពីលោក Michael Karnavas, ចុះហត្ថលេខាដោយ Tanya Pettay, "សេចក្ដីប្រកាសព័ត៌មានរបស់ក្រុមមេធាវីការពារក្ដី អៀង សារី - ការប្រកាសដាក់ឲ្យប្រើប្រាស់នូវគេហទំព័រថ្មី", ២៨ មីនា ២០១៣។

សម្គាល់ថា "គេហទំព័រនេះ គឺការងារដែលកំពុងស្ថិតក្នុងដំណើរនៅឡើយ" ហើយក៏បានបញ្ជាក់អះអាងផងដែរថា "ពេញមួយរយៈកាលនៃការការពារក្តីលោក អៀង សារី ក្រុមមេធាវីការពារក្តី អៀង សារី បានខិតខំប្រឹងប្រែងយ៉ាងមោះមុតក្នុងការការពារ និងលើកតម្កើងសិទ្ធិមនុស្ស និងសិទ្ធិទទួលបានការការពារក្តីដោយយុត្តិធម៌របស់លោក អៀង សារី, ការពារសេចក្តីថ្លៃថ្នូរជាមនុស្សរបស់គាត់, និងជម្រុញឲ្យមានសាធារណភាព និងតម្លាភាពនៅក្នុងគ្រប់ទិដ្ឋភាពនៃកិច្ចដំណើរការនីតិវិធីទាំងអស់។ គេហទំព័រនេះ គឺជាការបន្តអោយសម្រេចបាននូវការខិតខំប្រឹងប្រែងនេះ"។

៥៦- ត្រង់ផ្នែក "អំពីយើង" នៃគេហទំព័រ មានផ្ទុកទៅដោយជីវប្រវត្តិរបស់សហមេធាវីការពារក្តីដែលបានចាត់តាំងទាំងពីររូប។ គេបានថ្លែងថា គេហទំព័រនេះ "ត្រូវបានបង្កើតឡើង និងត្រូវបានប្រតិបត្តិការដោយក្រុមមេធាវីការពារក្តីក្នុងការការពារឲ្យលោក អៀង សារី នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" ពីព្រោះថា នៅក្នុងពាក្យពេចន៍របស់សហមេធាវីការពារក្តី ដែលបានចាត់តាំង៖

> *...ការអនុវត្តបច្ចុប្បន្ននេះពីសំណាក់អង្គជំនុំជម្រះនានា និងសហចៅក្រមស៊ើបអង្កេតនៅ អ.វ.ត.ក លើការទប់ស្កាត់មិនឲ្យមានការដាក់ឯកសាររបស់មេធាវីការពារក្តី ដែលអាចជាការអាម៉ាស់ ឬ ដែលនាំឲ្យមានជាសំណួរអំពីធម្មានុភាព និងភាពពិចារណាដ៏ហ្មត់ចត់លើសកម្មភាព និងសេចក្តីសម្រេចរបស់ចៅក្រម ដែលបិតនៅក្រោមរូបភាពផ្លែល្វា ដែលថាវាជាវិធានការសំខាន់ដើម្បីការពារនូវភាពសម្ងាត់ដោយសន្មត និងសុចរិតភាពនៃការស៊ើបអង្កេត ឬដំណើរការនៃការធ្វើសេចក្តីសម្រេចតាមផ្លូវតុលាការនោះ ដែលទាំងអស់នេះគេមិនត្រូវបន្តធ្វើតទៅទៀតទេ ដោយគ្មានការលើកលែងអ្វីឡើយ។ សេចក្តីសន្និដ្ឋានដែលជាការងាររបស់ក្រុមមេធាវីការពារក្តីតែម្នាក់ឯង ហើយដែលមិនមានការទាក់ទងទៅនឹងអង្គសេចក្តីនៃការស៊ើបសួរដែលកំពុងដំណើរការ ក៏ប៉ុន្តែមានតែការទាក់ទងទៅនឹងបញ្ហាច្បាប់ប៉ុណ្ណោះ ត្រូវតែបានធ្វើការជជែកពិភាក្សានៅក្រោមក្រសែភ្នែកដ៏ប្រុងប្រយ័ត្នរបស់សាធារណជន។ ការអនុញ្ញាតឲ្យបញ្ហាមិនសម្ងាត់នានា ត្រូវបានជជែកពិភាក្សាជាសម្ងាត់ គឺមិនត្រឹមតែដកហូតនូវសិទ្ធិរបស់លោក អៀង សារី ក្នុងការទទួលបាននូវការជំនុំជម្រះក្តីដ៏ត្រឹមត្រូវ និងជាសាធារណៈ នោះទេ ក៏ប៉ុន្តែថែមទាំងដកហូតនូវការពន្យល់បង្ហាញថា*

*តើការជំនុំជម្រះក្តីដ៏ស្មុគស្មាញលើឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរបំផុតរបស់ប្រទេសកម្ពុជា អាចត្រូវដំណើរការដោយចំហរ និងប្រកបទៅដោយតម្លាភាព បានតាមរបៀបណាទៀតផង*[155] ។

## V. **អំណះអំណាង**

### 1. ទំនាស់ផលប្រយោជន៍មានអត្ថិភាព

៥៧- **កិច្ចដំណើរការនីតិវិធីកន្លងមកប្រឆាំងនឹង អៀង សារី និងកិច្ចដំណើរការនីតិវិធីកំពុងអនុវត្ត ពាក់ព័ន្ធនឹង មាស មុត មានទំនាក់ទំនងគ្នាយ៉ាងច្រើន។** កិច្ចដំណើរការនីតិវិធីប្រឆាំងនឹង អៀង សារី ក្នុងសំណុំរឿង០០២ និងអង្គហេតុដែលត្រូវបានចោទប្រកាន់ ពាក់ព័ន្ធនឹង មាស មុត ដែលត្រូវស៊ើបអង្កេតក្នុងសំណុំរឿង០០៣ មានទំនាក់ទំនងគ្នាយ៉ាងច្រើន មានជាអាទិ៍ ទីតាំងឧក្រិដ្ឋកម្ម និងឧក្រិដ្ឋកម្មសំខាន់ៗ និងទម្រង់នៃការទទួលខុសត្រូវ ដែលត្រូវចោទ ឬចោទប្រកាន់។ ជនទាំងពីរនេះត្រូវបានចោទថាមានការពាក់ព័ន្ធនឹងសហកម្មឧក្រិដ្ឋកម្មរួមដូចគ្នា។ ភស្តុតាងបង្ហាញថា បុគ្គលទាំងពីរ គឺជាសមាជិកក្នុងចនាសម្ព័ន្ធបក្សជាន់ខ្ពស់ដូចគ្នានៃបក្សកុម្មុយនីស្តកម្ពុជា។

៥៨- មាស មុត ដែលជាលេខាកងពល ១៦៤ (កងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ) ត្រូវបានចោទថាបានដឹងឮ និងបានចូលរួមផ្ទាល់ក្នុងឧក្រិដ្ឋកម្មនានា ពាក់ព័ន្ធនឹងការបញ្ជូនកម្មាភិបាលក្នុងកងពល ១៦៤នៃកងទ័ពបដិវត្តកម្ពុជាដែលត្រូវបានបោសសម្អាត និងអ្នកធ្វើដំណើរតាមទូកជនជាតិថៃ វៀតណាម និងមកពីបស្ចិមប្រទេសទៅកាន់ ស-២១[156]។ អៀង សារី ត្រូវបានចោទប្រកាន់អំពីឧក្រិដ្ឋកម្មដូចគ្នាទាក់ទងនឹងស-២១ ក្នុងសំណុំរឿង ០០២[157]។ មាស មុត ក៏ត្រូវបានស៊ើបអង្កេតនៅក្នុងសំណុំរឿង០០៣ ដែលបានចូលរួមជាមួយនឹងកងពល ១៦៤ ក្នុងការវាយប្រហារដោយកងទ័ពចូលទៅក្នុងប្រទេសវៀតណាម នៅចុងឆ្នាំ ១៩៧៧ និង ១៩៧៨[158] និងត្រូវបានចោទប្រកាន់ថាមានការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋជាទម្រង់សហកម្មឧក្រិដ្ឋកម្មរួម ដោយបានប្រព្រឹត្តឧក្រិដ្ឋកម្មនានានៅក្នុងទីតាំងសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង[159]។ អៀង សារី ត្រូវបានជាប់ចោទចំពោះ

---

[155] សូមអាន http://www.iengsarydefence.org/about-us.html, ចូលមើលចុងក្រោយ ថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៣។

[156] ឯកសារ D1 *ដូចខាងលើ* កថាខណ្ឌ ៨៩ ដល់ ៩៣។

[157] ដីកាដំណោះស្រាយ ឯកសារ **CF002-D427** ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១២ កថាខណ្ឌ ៤២៤ កថាខណ្ឌ ៤៣៣។

[158] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីរ ទាក់ទងនឹងកងទ័ពបដិវត្តន៍កម្ពុជាប្រជាធិបតេយ្យ ឯកសារ **D1** ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ កថាខណ្ឌ ៦២។

[159] ឯកសារ D1 *ដូចខាងលើ* កថាខណ្ឌ ៤៧ ដល់ ៥១ កថាខណ្ឌ ៩០ ដល់ ៩៧។

អំពើឃោរឃៅដែលបានប្រព្រឹត្តក្នុងទីតាំងឧក្រិដ្ឋកម្មដូចគ្នានេះ[160] និងបានចូលរួមក្នុង "ឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តដោយកងទ័ពបដិវត្តន៍កម្ពុជានៅលើទឹកដីវៀតណាម" ក្នុងអំឡុងពេលពីពាក់កណ្ដាលឆ្នាំ ១៩៧៧ ដល់ឆ្នាំ ១៩៧៨[161]។ អត្ថិភាពនៃឧក្រិដ្ឋកម្មរួមគ្នា ឬគ្រួតស៊ីគ្នានេះ ត្រូវបានលើកមកបង្ហាញយ៉ាងច្បាស់នៅកថាខណ្ឌ ៥ នៃដីកាបញ្ជូនរឿងឲ្យស៊ើបសួរក្នុងសំណុំរឿង០០៣[162]។

៥៩- មាស មុត ត្រូវបានចោទប្រកាន់ថាបានចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមដូចគ្នានឹងការចោទប្រកាន់ប្រឆាំងនឹង អៀង សារី ដែរ ដែលក្នុងនោះ សមាជិកភាពរបស់ពួកគាត់ត្រូវរៀបរាប់នៅក្នុងដីកាដំណោះស្រាយនៃសំណុំរឿង ០០២ ដោយរួមបញ្ចូលទាំង "សមាជិកនៃគណៈកម្មាធិការមជ្ឈិម" និង "មេបញ្ជាការកងពលមជ្ឈិមបក្ស"[163]។ មាស មុត ត្រូវបានចោទថាធ្លាប់ជាសមាជិកគណៈកម្មាធិការមជ្ឈិមផង និងជាមេបញ្ជាការកងពលមជ្ឈិមបក្សផង[164]។

៦០- ក្នុងនាមជាលេខាកងពល ១៦៤ នោះ មាស មុត ជាអ្នករាយការណ៍ជូនប្រធានសេនាធិការ (និងសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍) សុន សេន ដែលជាអ្នករាយការណ៍បន្តទៀតទៅសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ដទៃទៀត។ នៅគ្រប់កាលៈទេសៈទាំងអស់ពាក់ព័ន្ធនឹងសំណុំរឿង ០០៣, អៀង សារី គឺជាសមាជិកម្នាក់ក្នុងចំណោមសមាជិកពេញសិទ្ធិទាំងប្រាំរូបរបស់គណៈកម្មាធិការអចិន្ត្រៃយ៍។ ជាពិសេស ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនៃសំណុំរឿង ០០៣ ចោទប្រកាន់ថាសេនាធិការ ជាអ្នករាយការណ៍ជូនគណៈកងទ័ពដែលជាអនុគណៈកម្មាធិការមួយនៃគណៈកម្មាធិការអចិន្ត្រៃយ៍ ឬគណៈកម្មាធិការមជ្ឈិម[165]។ អៀង សារី បានទទួលស្គាល់ថា គណៈកម្មាធិការកងទ័ពជាអ្នករាយការណ៍ទៅគណៈកម្មាធិការអចិន្ត្រៃយ៍ បន្ទាន់ពីគណៈកម្មាធិការនេះបានទទួលរបាយការណ៍ពីមូលដ្ឋាន[166]។ របាយការណ៍នានាដែលបានធ្វើឡើងនៅពេលនោះ ហើយបានដកស្រង់នៅក្នុង **ផ្នែកទី ៤** ខាងលើ ក៏បញ្ជាក់ថា មាស មុត បានចម្លងជូន អៀង សារី នូវសារទូរលេខ

---

[160] ដីកាដំណោះស្រាយ ឯកសារ **CF002-D427** ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១២ កថាខណ្ឌ ៣៨៣ ដល់ ៣៩៨។

[161] *ដូចខាងលើ* កថាខណ្ឌ ៨៣៦ ដល់ ៨៤០។

[162] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីរ ទាក់ទងនឹងកងទ័ពបដិវត្តន៍កម្ពុជាប្រជាធិបតេយ្យ ឯកសារ **D1** ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ កថាខណ្ឌ ៥។

[163] **CF002-D427** Closing Order, 28 September 2012 at paras. 159.

[164] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីរ ទាក់ទងនឹងកងទ័ពបដិវត្តន៍កម្ពុជាប្រជាធិបតេយ្យ ឯកសារ **D1** ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ កថាខណ្ឌ ៣។

[165] ឯកសារ **D1** *ដូចខាងលើ* កថាខណ្ឌ ១៣។

[166] ឯកសារ **D1** *ដូចខាងលើ* កថាខណ្ឌ ១២២; បទសម្ភាសន៍ជាមួយនឹង អៀង សារី ដោយ អេលីហ្សាប៊ែត ប៊ែកឃឺ (Elizabeth Becker) ឯកសារ **E3/94** ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ១៩៨១, លេខឯកសារ ERN00342500-00342504;, ឯកសារ **D4.1.1032** នៅក្នុង **CF003**។

ទាក់ទងនឹងការចោទប្រកាន់ជាច្រើនដង[167]។ អាស្រ័យហេតុនេះហើយទើបសហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា កិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹង អៀង សារី និង មាស មុត មានទំនាក់ទំនងយ៉ាងច្រើន ហើយតាមពិតមានការពាក់ព័ន្ធគ្នាទាំងស្រុងតែម្តង។

៦១- ***ផលប្រយោជន៍ផ្លូវច្បាប់របស់ អៀង សារី និង មាស មុត មានភាពខុសគ្នាជាសត្យានុម័ត នៅក្នុងកិច្ចដំណើរការនីតិវិធីពាក់ព័ន្ធសំខាន់ៗដែលជាហេតុនាំឱ្យមានទំនាស់ផលប្រយោជន៍ជាច្រើន។***

សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា ផលប្រយោជន៍ផ្លូវច្បាប់ជាក់ស្តែងរបស់ អៀង សារី និង ផលប្រយោជន៍ផ្លូវច្បាប់របស់ មាស មុត នៅពេលបច្ចុប្បន្នមានភាពខុសគ្នាជាសត្យានុម័ត។ ក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២ អំឡុងកាលនៃការសួរដេញដោលរបស់ខ្លួនជាមួយ កាំង ហ្កេកអ៊ាវ ហៅ ឌុច សហមេធាវីដែលត្រូវបានចាត់តាំង បានអនុវត្តយុទ្ធសាស្ត្រយ៉ាងស៊ីសង្វាក់គ្នាដើម្បីការពារក្តីថា អៀង សារី គ្មានការទទួលខុសត្រូវក្នុងការសម្រេចក្នុងការបញ្ជូនកម្មាភិបាលដែលត្រូវបោសសម្អាត ឬបុគ្គលផ្សេងៗទៀតដែលត្រូវបានចាត់ទុកថាជា "ខ្មាំង" ទៅកាន់ ស-២១ ទេ ឬគ្មានការទទួលខុសត្រូវលើសកម្មភាពយោធានៃរបបកម្ពុជាប្រជាធិបតេយ្យឡើយ[168]។ ទោះជាយ៉ាងនេះក្តី មាស មុត បានធ្វើសេចក្តីប្រកាសដូចខាងក្រោម នៅក្នុងបទសម្ភាសន៍ជាមួយនឹងប្រព័ន្ធព័ត៌មាន ក្នុងខណៈពេល អៀង សារី នៅគ្រប់គ្រងទឹកដីនៅឡើយរបស់ខ្មែរក្រហមនៅភាគខាងជើងនៃប្រទេសកម្ពុជា ហើយយ៉ាងហោចណាស់សេចក្តីប្រកាសនោះត្រូវបានធ្វើឡើង ៤ ឆ្នាំ មុនពេល អៀង សារី បានចុះចូលជាមួយរដ្ឋាភិបាល បន្ទាប់ពីបានទទួលព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស ៖

> *[ប្រសិនបើអ្នកចង់ដឹងរឿងរ៉ាវគ្រប់យ៉ាងនៅក្នុងសម័យនោះ សូមទៅសួរ អៀង សារី ទៅ។ កុំសួរខ្ញុំ ឬមន្ត្រីមានឋានៈទាបៗផ្សេងៗទៀត។ អៀង សារី គឺជាអ្នកដឹកនាំ។* [...] *សម្រាប់ខ្ញុំ ខ្ញុំគ្មានបញ្ហាជាមួយនឹងតុលាការឡើយ។ ខ្ញុំនឹងនិយាយរឿងរ៉ាវសព្វយ៉ាង ៖ អ្វីៗដែលខ្ញុំបានដឹង និងបានធ្វើ។ មន្ត្រីមានឋានៈទាបត្រូវតែគោរពបញ្ជា*[169] ។

[167] សារទូរលេខយោធារបស់កម្ពុជាប្រជាធិបតេយ្យពី មាស មុត មានចំណងជើងថា "សារទូរលេខ ០០-៣៥៤ ខ្ទង់ សូមគោរពជូន គណៈកម្មាធិការមន្ទីរ ៨៧០" ឯកសារ **D1.3.34.60**"; សារសម្ងាត់តាមទូរស័ព្ទ ថ្ងៃទី១ ខែ មេសា ឆ្នាំ ១៩៧៨ ឯកសារ**IS18.59** ៖ របាយការណ៍អំពីចំនួនខ្មាំងឃ្លួនសរុបដែលបានចាប់ខ្លួន និងបាញ់សម្លាប់ ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០០៨។ សូមមើលផងដែរ ឯកសារ **D4.1.635**។

[168] សូមមើល ប្រតិចារឹក ឯកសារ **E1/61.1** ថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១២ ទំព័រ ៨០ ដល់ ៨១ ទំព័រ ៨៨ ដល់ ៨៩, ទំព័រ ៩៩ ដល់ ១០៧ និង ទំព័រ ១១០ (ភាសាអង់គ្លេស)។

[169] បទសម្ភាសន៍ជាមួយមាស មុត ដោយ Christine Chameau ឯកសារ **D1.3.33.16** ខែកក្កដា ឆ្នាំ១៩៩១ ទំព័រ ៩៦ បន្ទាត់៨ដល់ ៩ លេខសម្គាល់ជាភាសាអង់គ្លេស 00089661 (ទំព័រ ១)។

៦២- ដូចនេះ សេចក្ដីប្រកាសជាមុនរបស់ មាស មុត នេះ បង្ហាញពីតួនាទីដែលមានទំនាក់ទំនងផ្ទាល់ជាមួយនឹងការការពារពាក់ព័ន្ធចំពោះការបញ្ជាពីថ្នាក់លើ ឬយុត្តិកម្មនៃការបញ្ជាថ្នាក់លើ ដើម្បីកាត់បន្ថយការផ្ដន្ទាទោសដែលអាចកើតមាន និងការចាត់ទុក អៀង សារី ជាអ្នកដឹកនាំផ្ទាល់របស់ខ្លួនដែលបានដឹង "រឿងរ៉ាវគ្រប់ប្រភេទ" និងការចាត់ទុកខ្លួនឯងថាជា "មន្ត្រីជាន់ទាប" ម្នាក់។ នៅក្នុងការប្រៀបធៀបក្នុងពេលសួរដេញដោល ឌុច លោក Karnavas ធ្វើការការពារកូនក្ដីយ៉ាងស៊ីសង្វាក់គ្នាថា អៀង សារី មិនបានដឹងអ្វីទាំងអស់ "ទាក់ទងនឹងការចាប់ខ្លួននរណាម្នាក់"[170] ដោយធ្វើការសួរសំណួរថា "តើអ្នកអាចបញ្ជាក់ចំណុចណាមួយឲ្យបានច្បាស់លាស់ ដែលបង្ហាញថាលោក អៀង សារី ពិតជាបានទទួលព័ត៌មានថាមានមនុស្សត្រូវបានគេបញ្ជូនទៅ ស-២១[171]។ ផលប្រយោជន៍ផ្នែកច្បាប់របស់ មាស មុត ក្នុងការពង្រឹងការការពារក្ដីសំខាន់ៗរបស់ខ្លួន គឺមានភាពខុសគ្នាជាសត្យានុម័តជាមួយនឹងផលប្រយោជន៍ដែលត្រូវបានលើកឡើងសម្រាប់ អៀង សារី នៅក្នុងកិច្ចដំណើរការនីតិវិធីដែលមានទំនាក់ទំនងគ្នាយ៉ាងច្រើននេះ។ អង្គហេតុតែប៉ុណ្ណេះនេះអាចបញ្ជាក់ថាសហមេធាវីដែលត្រូវបានចាត់តាំង មានទំនាស់ផលប្រយោជន៍នៅក្នុងសំណុំរឿងបច្ចុប្បន្ន ហើយបង្កឲ្យកើតមានទំនាស់ផលប្រយោជន៍ជាច្រើនដែលមិនត្រឹមតែអាចព្យាករណ៍ទុកជាមុនបានទេ តែជាការកើតឡើងយ៉ាងពិតប្រាកដ ក្នុងពេលអនុវត្តកិច្ចស៊ើបសួរ។

៦៣- តាមរយៈតារាងអង្គហេតុដែលមានទំនាក់ទំនងគ្នានេះ គេអាចព្យាករណ៍ទុកជាមុនយ៉ាងសមហេតុសមផលថែមទៀតថា ព័ត៌មានសម្ងាត់ (មានជាអាទិ៍ព័ត៌មានដែលបានលើកឡើងនៅក្នុង **ផ្នែកទី ៣**, ព័ត៌មានផ្សេងៗទៀតដែលទាក់ទងនឹងនឹងការការពារឲ្យ អៀង សារី បើទោះបីហួសពីវិសាលភាពនៃសម្ភារៈដែលត្រូវបានការពារដោយអភ័យឯកសិទ្ធិវិជ្ជាជីវៈច្បាប់ក៏ដោយ) អាចមានការពាក់ព័ន្ធ និងជាការដោះបន្ទុកដែលអាចកើតមានក្នុងពេលការពារឲ្យ មាស មុត ឲ្យបានត្រឹមត្រូវនោះ។ ឧទាហរណ៍ក្នុងខណៈពេលអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបនៅក្នុងតុលាការ ដែលជាសិទ្ធិស្របច្បាប់របស់ខ្លួននោះ អៀង សារី ទំនងជាអាចបានផ្ដល់ព័ត៌មានពីប្រភពដើមទាក់ទងនឹងបទពិសោធរបស់គាត់អំពីបណ្ដាញរាយការណ៍របស់បក្សកុម្មុយនីស្តកម្ពុជាទៅសហមេធាវីដែលត្រូវបានចាត់តាំង ដែលធ្វើឲ្យពួកគេចោទសួរ ឌុច យ៉ាងល្អិតល្អន់ពីភាពខុសគ្នារវាង "ការងារជាគោលការណ៍ និងការងារអនុវត្តជាក់ស្ដែង"[172]។ មេធាវីដែលមានព័ត៌មានដូចនេះពីកូនក្ដីមុនរបស់ខ្លួនអាចជាការបំពានដល់ភាព

---

[170] ប្រតិចារឹក ឯកសារ **E1/61.1** ថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១២ ទំព័រ ៩៦ បន្ទាត់ ៨ ដល់ ៩។

[171] *ដូចខាងលើ* ឯកសារ **E1/61.1** ទំព័រ ៩៦ បន្ទាត់ ១១ ដល់ ១៣។

[172] *ដូចខាងលើ* ឯកសារ **E1/61.1** ទំព័រ ៩៧ បន្ទាត់ ១៤ ដល់ ១៧។

សម្ងាត់ដោយពឹងផ្អែកដោយផ្ទាល់ ឬដោយប្រយោលលើព័ត៌មានទាំងនោះដើម្បីការពារកូនក្តីបច្ចុប្បន្ន ដែលមានផលប្រយោជន៍ខុសគ្នាជាសត្យានុម័ត។ ក្នុងករណីខ្លះ ប្រសិនបើមេធាវីការពារក្តីអាចបិទបាំងដោយចេតនាដោយមិនប្រើប្រាស់ព័ត៌មានទាំងនេះក៏ដោយ ក៏មេធាវីការពារក្តីរូបនោះអាចបំពានដល់តួនាទីទំនុកចិត្ត ពាក់ព័ន្ធនឹងការផ្សព្វផ្សាយព័ត៌មាន សុចរិតភាព ការបើកចំហ និងភាពស្មោះត្រង់ដល់កូនក្តីដែលខ្លួនកំពុងការពារដោយមិនប្រើប្រាស់ព័ត៌មានទាំងនោះជាផ្នែកមួយ ក្នុងការការពារក្តីរបស់ខ្លួន។

៦៤- ដោយផ្អែកលើមូលហេតុទាំងនេះហើយទើបសហព្រះរាជអាជ្ញាអន្តរជាតិបញ្ជាក់ថា វាយ៉ាងហោចណាស់អាចព្យាករណ៍ទុកជាមុនយ៉ាងសមហេតុសមផលថា ព័ត៌មានសម្ងាត់ទាក់ទងនឹងការការពារឲ្យ អៀង សារី អាចត្រូវប្រើប្រាស់ ដើម្បីបំផ្លាញផលប្រយោជន៍របស់ អៀង សារី ឬដើម្បីផ្តល់ប្រយោជន៍ដល់ការការពារក្តីរបស់ មាស មុត នៅក្នុងកាលៈទេសៈដែលផលប្រយោជន៍របស់កូនក្តីនីមួយៗមានខុសគ្នាជាសត្យានុម័ត។ បញ្ហានេះអាចបង្កឲ្យមានទំនាស់ផលប្រយោជន៍មួយផ្សេងទៀតក្នុងពេលខ្លួនធ្វើជាមេធាវីការពារឲ្យ មាស មុត។

៦៥- ***សហមេធាវីដែលត្រូវបានចាត់តាំងបន្តការពារផលប្រយោជន៍របស់ អៀង សារី បន្ទាប់ពីបញ្ចប់អាណត្តិរបស់ខ្លួន ដែលការណ៍នេះនាំឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ការអនុវត្តភារកិច្ចរបស់ខ្លួនជាមួយ មាស មុត។*** សកម្មភាពនានារបស់សហមេធាវីដែលត្រូវបានចាត់តាំង ទាំងលក្ខណៈបុគ្គល ទាំងលក្ខណៈរួម បង្ហាញឲ្យឃើញថា ពួកគេមិនត្រឹមតែបន្តភាពស្មោះត្រង់របស់ខ្លួនជាមួយនឹង អៀង សារី ប៉ុណ្ណោះទេ តែថែមទាំងលើកកម្ពស់ដោយផ្ទាល់ក្នុងការបន្តការពារផលប្រយោជន៍ផ្លូវច្បាប់របស់គាត់ ក្នុងនោះរួមមានការការពារកេរ្តិ៍ឈ្មោះ និងភាពថ្លៃថ្នូរ និងសុខុមាលភាពរបស់គ្រួសារកូនក្តីរូបនេះ។ ដូចមានបង្ហាញនៅក្នុងផ្នែកទី ៤ ខាងលើ លោក Karnavas បានចេញសេចក្តីថ្លែងការណ៍ដល់ប្រព័ន្ធព័ត៌មានអំពីភាពចាំបាច់ក្នុងការថែរក្សាភាពថ្លៃថ្នូររបស់ អៀង សារី ហើយរៀបរាប់ថាតើគាត់មាន "ទំនាក់ទំនងផ្លូវចិត្ត" យ៉ាងណា ចំពោះអតីតកូនក្តីរបស់ខ្លួន[173]។

៦៦- បន្ទាប់ពី អៀង សារី បានទទួលមរណភាព និងការបញ្ចប់អាណត្តិរបស់ខ្លួននោះ, សហមេធាវីដែលត្រូវបានតែងតាំង បានធ្វើការផ្សព្វផ្សាយគេហទំព័រគាំទ្រ អៀង សារី ដោយមានបញ្ជាក់ "យុត្តិកម្ម និងមូលហេតុ" ថា "ទម្លាប់អនុវត្តបច្ចុប្បន្នរបស់អង្គជំនុំជម្រះ និងសហចៅក្រមស៊ើបអង្កេតនៅ

[173] កំណត់សម្គាល់ ១៣៩ *ខាងលើ*។

អ.វ.ត.ក ទម្លាប់អនុវត្តក្នុងការរារាំងដល់ការដាក់ឯកសារពីសំណាក់ក្រុមមេធាវីការពារក្ដីដែលអាចជាទង្វើគួរឲ្យខ្មាស់អៀន ឬអាចជាទង្វើទាក់ទងនឹងភាពស្របច្បាប់ និងសកម្មភាព និងសេចក្ដីសម្រេចយ៉ាងប្រុងប្រយ័ត្នរបស់ចៅក្រម ... ដកហូតពីលោក អៀង សារី នូវសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌”[174]។ សហមេធាវីដែលត្រូវបានចាត់តាំងនៅតែបន្តមានទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងគេហទំព័រនេះ និងខ្លឹមសារនៅក្នុងគេហទំព័រនេះ ដែលការណ៍នេះអាចបញ្ជាក់តាមរយៈការផ្សព្វផ្សាយសេចក្ដីជូនដំណឹង អំពីការដាក់ឲ្យដំណើរការនៃគេហទំព័រនេះរបស់លោក Karnavas[175] និងការដាក់ផ្សព្វផ្សាយសំខាន់ៗនូវរូបថត ព័ត៌មានអំពីជីវប្រវត្តិ និងសេចក្ដីបញ្ជាក់ពីចេតនា និងបំណង ព្រមទាំងការគាំទ្រផ្ទាល់ដល់គេហទំព័រនេះ[176]។

៦៧- គេហទំព័រនេះបង្ហាញយ៉ាងច្បាស់នូវផ្នែកមួយនៃយុទ្ធសាស្ត្រផ្នែកច្បាប់ ដែលមានការសម្របសម្រួលក្នុងការការពារផលប្រយោជន៍ផ្លូវច្បាប់ឲ្យ អៀង សារី ទាំងនៅក្នុង និងនៅក្រៅសាលសវនាការ ដើម្បីតវ៉ាប្រឆាំងនឹងធម្មានុរូបនៃសេចក្ដីសម្រេចនានារបស់ចៅក្រម ក្នុងបរិបទនយោបាយទូលំទូលាយទាក់ទងនឹងព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោសសម្រាប់ អៀង សារី។ ចំណុចនេះអាចត្រូវបញ្ជាក់បន្ថែមតាមរយៈសេចក្ដីប្រកាសរបស់ អៀង សារី ផ្ទាល់ នៅពេលចាប់ផ្ដើមកិច្ចដំណើរការនីតិវិធី ក្នុងសំណុំរឿង ០០២ ដែលថា “ដោយសារអង្គជំនុំជម្រះសាលាដំបូងមិនបានចាត់ការដោយត្រឹមត្រូវ ខ្ញុំយល់ឃើញថា ខ្ញុំបាទមិនគួរចូលរួមក្នុងការជំនុំជម្រះនេះទេ ដោយគួររង់ចាំរហូតដល់អង្គជំនុំជម្រះតុលាការកំពូល បានចេញសេចក្ដីសម្រេចលើព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោសនេះសិន”[177]។

៦៨- ការគាំទ្រ “យ៉ាងខ្លាំង”[178] របស់សហមេធាវីដែលត្រូវបានចាត់តាំងដល់ អៀង សារី ទាំងនៅមុន និងបន្ទាប់ពី អៀង សារី ទទួលមរណភាព បានធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងដល់តួនាទីទំនុកចិត្តរបស់សហមេធាវីដែលត្រូវបានចាត់តាំងចំពោះ មាស មុត ដែលត្រូវបានបំពេញឲ្យបានល្អបំផុត។ ដូចមានបង្ហាញនៅក្នុងផ្នែកទី ៣ ខាងលើ មាស មុត មានសិទ្ធិទទួលបានការប្រឹក្សាដោយសេរីអំពីដំបូន្មានផ្លូវ

---

[174] សូមមើល www.iengsarydefence.org/about-us.html ។

[175] សារអេឡិចត្រូនិករបស់ Michael Karnavas ផ្ញើជូនភាគីទាំងអស់ “សេចក្ដីប្រកាសព័ត៌មានពីក្រុមការពារក្ដី អៀង សារី ៖ ការប្រកាសដាក់ឲ្យដំណើរការគេហទំព័រថ្មី”, ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៣។

[176] កំណត់សម្គាល់ ១៧៧ *ខាងលើ*, www.iengsarydefence.org/about-us.html

[177] ប្រតិចារឹក ឯកសារ **E1/15.1** ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ៤ បន្ទាត់ ២២ ដល់ ២៤ (ភាសាអង់គ្លេស)។

[178] សេចក្ដីប្រកាសព័ត៌មានរបស់ក្រុមមេធាវីការពារក្ដី អៀង សារី “សេចក្ដីប្រកាសដាក់ឲ្យដំណើរការគេហទំព័រថ្មី” ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៣ ទំព័រ ១។

ច្បាប់ដោយផ្អែកលើការវិនិច្ឆ័យបែបវិជ្ជាជីវៈឯករាជ្យ។ ឧទាហរណ៍ ប្រសិនបើ មាស មុត ក្នុងពេលណាមួយនោះ ចង់ពិចារណា ឬប្រើប្រាស់យុទ្ធសាស្ត្រការពារខ្លួន ដោយសហការជាមួយនឹងផ្នែកស៊ើបអង្កេត ដែលយ៉ាងតិចបំផុតដោយការគោរពតាមលក្ខខណ្ឌផ្លូវច្បាប់នៃភាពសម្ងាត់ក្នុងកិច្ចស៊ើបសួរនោះ វាបង្ហាញយ៉ាងច្បាស់ថា សហមេធាវីដែលត្រូវបានចាត់តាំង អាចមានការប្រយ័ត្នប្រយែងក្នុងការផ្ដល់ការប្រឹក្សាដល់គាត់។ នៅក្នុងកាលៈទេសៈនេះ សហមេធាវីដែលត្រូវបានចាត់តាំងមិនអាចឯករាជ្យពីការការពារឲ្យផលប្រយោជន៍ស្របច្បាប់របស់ អៀង សារី ដែលពួកគេមានតួនាទីបន្តភាពស្មោះត្រង់របស់ខ្លួន និងជាមួយមនុស្សដែលខ្លួនអះអាងថាមានសេចក្ដីស្រឡាញ់ជាលក្ខណៈបុគ្គល។ ការផ្ដល់យោបល់ដល់ មាស មុត ឲ្យគោរពឲ្យបានពេញលេញនូវភាពសម្ងាត់នៃកិច្ចស៊ើបសួរ អាចធ្វើឲ្យប៉ះពាល់ មិនត្រឹមតែដល់ភារកិច្ចដែលខ្លួនត្រូវបន្តផ្ដល់ភាពស្មោះត្រង់ចំពោះ អៀង សារី ប៉ុណ្ណោះទេ តែថែមទាំងនាំអន្តរាយដល់ការយល់ឃើញពីភាពត្រឹមត្រូវនៃការអះអាងដែលបានធ្វើឡើងនៅក្នុងគេហទំព័ររបស់ខ្លួនផ្ទាល់ ដែលខ្លួនបានបង្កើតឡើងសម្រាប់ការការពារក្ដីរបស់ខ្លួន ហើយជាលទ្ធផលក៏ធ្វើឲ្យប៉ះពាល់ដល់ប្រយោជន៍ផ្ទាល់ខ្លួនពាក់ព័ន្ធនឹងកិត្តិយសវិជ្ជាជីវៈទៀតផង។

៦៩- ដោយសារមូលហេតុទាំងនេះហើយ ទើបសហព្រះរាជអាជ្ញាអន្តរជាតិអះអាងថាមានទំនាស់ផលប្រយោជន៍ដូចមានចែងក្នុងវិធាន ៣.១ នៃក្រមសមាគមមេធាវីអន្តរជាតិ (IBA Code) និងបានដកស្រង់មកបញ្ជាក់នូវខាងលើ[179] ពីព្រោះមាន "ហានិភ័យយ៉ាងច្បាស់ថា ការតំណាងឲ្យកូនក្ដីម្នាក់ ឬច្រើននាក់ នឹងត្រូវប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសារការទទួលខុសត្រូវរបស់មេធាវីការពារក្ដីក្នុងចំពោះអតីតកូនក្ដីរបស់ខ្លួន ឬផលប្រយោជន៍ផ្ទាល់ខ្លួនរបស់មេធាវីរូបនោះ"[180]។

## ២. ទំនាស់ប្រយោជន៍ទាំងនេះមិនអាចត្រូវបានលះបង់ចោលឡើយ

៧០- ***នៅក្នុងកាលៈទេសៈ ដែលលើកលែងចំពោះការយល់ព្រមទៅនឹងការការពារនោះ នឹងប៉ះពាល់ជាអចិន្ត្រៃយ៍ដល់កិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ***។ ក្រៅពីព្យសនកម្ម ដែលទំនាស់នោះបង្កើតឲ្យមានចំពោះការការពារឲ្យ មាស មុត និង អៀង សារី ស្ថាប័នរបស់ អ.វ.ត.ក និងកិច្ចដំណើរការនីតិវិធីចំពោះ មុខ អ.វ.ត.ក នឹងទទួលរងព្យសនកម្មផងដែរតាមរយៈការចាត់តាំងសហមេធាវីដែល ត្រូវបានចាត់តាំង នៅក្រោមកាលៈទេសៈនេះ។ ជាក់ស្ដែង ការយល់ឃើញថាជាទំនាស់ពិតប្រាកដ ដែលនឹងកើតចេញពីការការពារឲ្យ មាស មុត របស់សហមេធាវីដែលត្រូវបានចាត់តាំងនោះ នឹងប៉ះពាល់ដល់កិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះនៅ អ.វ.ត.ក ដោយសារតែ វានឹងមានឥទ្ធិពលអាក្រក់ទៅលើ

[179] មើលកំណត់សម្គាល់ ៩៦។

[180] *ដូចខាងលើ*។

ការយល់ឃើញអំពីសុចរិតភាពពិតប្រាកដនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២ និង០០៣ និង អាចនៅក្នុងសំណុំរឿង០០៤ ទៀត។

៧១- អ.វ.ត.ក មានសិទ្ធិស្របច្បាប់ក្នុងការមិនសម្របសម្រួលដែលមិនចាំបាច់នូវបេសកម្មរបស់តុលាការ និងក្នុងការធ្វើឲ្យកិច្ចដំណើរការនីតិវិធីចំពោះមុខតុលាការមិនត្រឹមតែមានយុត្តិធម៌ពិតប្រាកដប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើឲ្យមានការយល់ឃើញថាមានយុត្តិធម៌ទៀតផង តាមដែលអាចធ្វើទៅបាន។ ប្រការនេះរួមទាំងការធានាថា ជនសង្ស័យ និងជនជាប់ចោទមានមេធាវីដែលនឹងមានសមត្ថភាពពេញលេញដើម្បីការពារកូនក្តីរបស់ពួកគាត់ តាមគ្រប់មធ្យោបាយសមស្រប និងគ្រប់កាលៈទេសៈទាំងអស់ ដែលអាចកើតឡើង ដូច្នេះ ការអះអាងបញ្ជាក់អំពីបទចោទ ការផ្តន្ទាទោស និងការដាក់ទោស ដែលអាចកើតមាន ត្រូវបានគេមើលឃើញថាត្រឹមត្រូវតាមច្បាប់ ដោយសារតែភាពលំបាកស្មុគស្មាញច្រើនផ្នែកនីតិវិធីនៃវិវាទដែលមាននៅចំពោះមុខ។ តុលាការ និងសហព្រះរាជអាជ្ញា មានសិទ្ធិក្នុងការធានាថា បុគ្គលទាំងឡាយដែលត្រូវបានស៊ើបអង្កេត និងដែលអាចត្រូវបានយកមកជំនុំជម្រះ នៅចំពោះមុខតុលាការ មានឱកាសទាំងអស់ ដើម្បីការពារខ្លួនឲ្យបានពេញលេញ។

៧២- ដោយពិចារណាអំពីច្បាប់ជាធរមាននៅក្នុងផ្នែក **III** និងដូចដែលបានលើកទឡ្ហីករណ៍នៅក្នុងផ្នែក **IV** (ក) ខាងលើ សហមេធាវីដែលត្រូវបានចាត់តាំង នឹងមិនអាចផ្តល់នូវការការពារក្តីឲ្យបានហ្មត់ចត់ល្អិតល្អន់បានឡើយ ដោយហេតុផលនៃទំនាស់របស់ពួកគេ។ ការកម្រិតនោះ នឹងពិតជាធ្វើឲ្យការការពារឲ្យ មាស មុត ឬធ្វើឲ្យមានការយល់ឃើញថាការការពារនោះមិនបានពេញលេញ ដែលអាចជាដុំពកខ្មៅគ្របដណ្តប់ទៅលើដីកាដំណោះស្រាយដ៏សំខាន់ ដែលបញ្ជូនជនជាប់ចោទទៅជំនុំជម្រះលើបទចោទណាមួយ ព្រមទាំងការផ្តន្ទាទោសណាមួយបន្ទាប់ទៀត។

៧៣- បន្ថែមទៅនឹងផលប៉ះពាល់ពិតប្រាកដ និងការយល់ឃើញអំពីផលប៉ះពាល់ទៅលើកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះក្នុងសំណុំរឿង០០៣ ការចាត់តាំងសហមេធាវីដែលត្រូវបានចាត់តាំងជាមេធាវីការពារក្តីឲ្យ មាស មុត នឹងមានឥទ្ធិពលអាក្រក់ទៅលើសុចរិតភាពពិតប្រាកដ និងការយល់ឃើញថាជាសុចរិតភាពនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២។ ដូចដែលបានកត់សម្គាល់កាលពីលើកមុនដោយសហព្រះរាជអាជ្ញាអន្តរជាតិ[181] មាស មុត ត្រូវបានកំណត់កាលបរិច្ឆេទឲ្យចូល

[181] ឯកសារ **D56/1** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំឲ្យបដិសេធការចាត់តាំងសហមេធាវីដែលត្រូវបានចាត់តាំង ដោយផ្អែកលើមូលដ្ឋាននៃជម្លោះផលប្រយោជន៍ដែលមិនអាចសម្រុះសម្រួលបាន ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១២ កថាខណ្ឌ ៥២។

បង្ហាញខ្លួនជាសាក្សីក្នុងសំណុំរឿង០០២។ ការចាត់តាំងសហមេធាវីដែលត្រូវបានចាត់តាំងជាមេធាវីស្របច្បាប់របស់គាត់នោះ នឹងអនុញ្ញាតឲ្យអតីតមេធាវីការពារក្តីរបស់សហជនជាប់ចោទ ក្នុងសំណុំរឿង០០២ អាចជួបប្រាស្រ័យដោយផ្ទាល់ជាមួយសាក្សី និងមានឥទ្ធិពលទៅលើសាក្សីក្នុងសំណុំរឿង ០០២។

៧៤- សហមេធាវីដែលត្រូវបានតែងតាំង នឹងបន្តមានផលប្រយោជន៍នៅក្នុងលទ្ធផលនៃសំណុំរឿង ០០២ ដោយសារតែពួកគាត់នៅតែមានកាតព្វកិច្ចរក្សាភាពសម្ងាត់ និងភាពស្មោះត្រង់ ព្រមទាំងក្តីស្រលាញ់ផ្ទាល់ខ្លួនទៅលើអតីតកូនក្តីរបស់ពួកគាត់[182] ដែលជាសមាជិកគណៈអចិន្ត្រៃយ៍ និងត្រូវបានចោទប្រកាន់ថាបាន ជាប់ពាក់ព័ន្ធក្នុងសហកម្មឧក្រិដ្ឋកម្មរួម (JCE) ជាមួយសហជនជាប់ចោទ ដែលនៅរស់ពីរនាក់ទៀតក្នុងសំណុំរឿង០០២។ សហមេធាវីដែលត្រូវបានតែងតាំង នឹងមានផលប្រយោជន៍ផ្ទាល់ខ្លួនផងដែរក្នុងការមើលឃើញថាទឡ្ហីករណ៍ ដែលពួកគាត់បានលើកឡើងក្នុង សំណុំរឿង០០២ ត្រូវបានធ្វើយុត្តិកម្ម ហើយមតិយោបល់ដែលបញ្ចេញជាសាធារណៈនោះ មានសុពលភាព[183]។ ដោយសារហេតុផលទាំងនេះ ការជួបប្រាស្រ័យ និងការមានឥទ្ធិពលទៅលើសាក្សី ក្នុងសំណុំរឿង ០០២ នឹងអាចប៉ះពាល់ដល់កិច្ចដំណើរការនីតិវិធីនៅក្នុងអង្គហេតុ និងមានផលប៉ះពាល់ជាអវិជ្ជមានផងដែរ ទៅលើការយល់ឃើញអំពីសុចរិតភាពនៃកិច្ចដំណើរការនីតិវិធី ក្នុងសំណុំរឿង ០០២។

៧៥- សហមេធាវីដែលត្រូវបានចាត់តាំង បានលើកទឡ្ហីករណ៍ថា ដោយសារតែ មាស មុត បានចង្អុលបង្ហាញថា គាត់ពុំមានបំណងផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២ ឬអាចក្នុងសំណុំរឿង ០០៣ ឬ ០០៤

---

[182] សូមមើលកាសែត The Cambodia Daily មានចំណងជើងថា អៀង សារី ត្រូវបានបូជានៅក្នុងពិធីបុណ្យសពដ៏ធំដុំមួយ (*Ieng Sary Cremated in Elaborate Funeral Ceremony*) ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០១៣ ("ផងដែរ ក្នុងចំណោមភ្ញៀវទាំងនោះមានដូចជាសមាជិកក្រុមមេធាវីការពារក្តី អៀង សារី មកពី អ.វ.ត.ក ទីក្រុងភ្នំពេញ។ មេធាវីការពារក្តីជាតិ លោក អាង ឧត្តម និងសហសេវិកមេធាវីអន្តរជាតិ លោក Michael Kamavas បានទទួលការស្វាគមន៍ដ៏កក់ក្តៅពីសំណាក់ លោក អៀង វុធ ដែលជាកូនប្រុសរបស់លោក អៀង សារី។ ក្នុងឱកាសនោះមេធាវីទាំងពីររូប បានទទួលកាដូជារូបថតដាក់ក្នុងស៊ុម ដែលមានរូបថតរបស់មេធាវី និងកូនក្តីថតជាមួយគ្នានៅក្នុងតុលាការ។ លោក Karnavas បាននិយាយថា "រូបថតនេះបញ្ជាក់អំពីទំនាក់ទំនងរបស់ខ្ញុំជាមួយ អៀង សារី"។ គាត់បានបន្ថែមទៀតថា "កិច្ចការមួយក្នុងចំណោមកិច្ចការជាច្រើនដែលយើងខិតខំបំពេញនោះ គឺដើម្បីធានានូវដំណើរការទាំងមូលថា មានការប្រព្រឹត្តចំពោះគាត់ក្នុងលក្ខណៈមួយដែលមានសេចក្តីថ្លៃថ្នូរជាមនុស្ស"។ "បន្ទាប់ពីការខិតខំបំពេញកិច្ចការលើរឿងក្តីនេះអស់រយៈពេលប្រាំឆ្នាំប្រាំខែមក វាជាការពិបាកមែនទែនក្នុងការមិន ជាប់ចិត្តស្រលាញ់លើកូនក្តីនោះ ដែលប្រការនេះ ជាការលំបាកមួយក្នុងចំណោមការលំបាកបំផុតរបស់ខ្ញុំដែលខ្ញុំមិនដែលជួប ប្រទះ")។

[183] សូមមើល Toronto Star ដែលមានចំណងជើងថា *ហេតុអ្វីបានជាការជំនុំជម្រះឧក្រិដ្ឋកម្មសង្គ្រាមរបស់ខ្មែរក្រហមនៃប្រទេសកម្ពុជាគ្មានទីបញ្ចប់ និងគ្មានប្រយោជន៍* (*Why Cambodia's Khmer Rouge war crimes trial is endless – and useless*) ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៣ ("ជាទូទៅ អង្គចៅក្រមពុំមានសមត្ថភាព គ្មានចៅក្រមណាម្នាក់មានបទពិសោធន៍ ចំណេះដឹង និងជំនាញសម្រាប់រឿងក្តីប្រភេទនេះឡើយ")។

ទេនោះ ទំនាស់នោះពុំកើតមានឡើយ ដោយផ្អែកលើមូលដ្ឋាននេះ។ តាមពិត ប្រការនេះគ្រាន់តែបញ្ជាក់អំពី ក្តីបារម្ភរបស់សហព្រះរាជអាជ្ញាអន្តរជាតិប៉ុណ្ណោះ និងផ្តល់នូវភ័ស្តុតាងបង្ហាញថា សហមេធាវីដែលត្រូវបានចាត់តាំងកំពុងតែធ្វើឲ្យប៉ះពាល់ដល់កិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ រួចទៅហើយ។

៧៦- ជាផ្នែកនៃឯកសារតែមួយដែល មាស មុត ធ្វើការលះបង់សិទ្ធិនោះ គាត់ក៏បានបញ្ជាក់ផងដែរថា គាត់ "ពុំមានបំណងឆ្លើយសំណួរណាមួយក្នុងនាមជាសាក្សីក្នុងសំណុំរឿង០០២ ក្នុងនាមជាជនជាប់សង្ស័យក្នុងសំណុំរឿង០០៣ ឬក្នុងនាមជាសាក្សីក្នុងសំណុំរឿង០០៤ ឡើយ"[184]។ បន្ថែមទៅលើអង្គហេតុដែលថាសេចក្តីបញ្ជាក់នេះត្រូវបានធ្វើឡើងជាផ្នែកមួយនៃការលះបង់សិទ្ធិនោះ ទឡ្ហីករណ៍របស់សហមេធាវីដែលត្រូវបានចាត់តាំងបញ្ជាក់ច្បាស់ថា សេចក្តីបញ្ជាក់នេះត្រូវបានដាក់បញ្ចូលដើម្បីកាត់បន្ថយនូវលទ្ធភាពនៃជម្លោះ[185]។ ដូច្នេះ ក្នុងការស្វះស្វែងឲ្យមានការចាត់តាំងជាមេធាវីការពារក្តីនោះ សហមេធាវីដែលត្រូវបានចាត់តាំងបានធ្វើឲ្យប៉ះពាល់ដល់កិច្ចដំណើរការ នីតិវិធីក្នុងសំណុំរឿង ០០២ សំណុំរឿង ០០៣ និងសំណុំរឿង ០០៤ រួចទៅហើយ សូម្បីតែនៅមុនពេលមានការបញ្ជាក់អះអាងអំពីការតែងតាំងពួកគាត់នោះ។ វាមិនអាចដឹងឡើយថាតើ មាស មុត នឹងប្រកាន់គោលជំហរតែមួយ ឬយ៉ាងណា ពាក់ព័ន្ធនឹងការផ្តល់សក្ខីកម្ម ប្រសិនបើវាមិនមែនជាតម្រូវការរបស់សហមេធាវីដែលត្រូវបានចាត់តាំង ក្នុងការព្យាយាមបំបាត់ចោលនូវទស្សនៈ យល់ឃើញយ៉ាងច្បាស់អំពីទំនាស់ផលប្រយោជន៍របស់ពួកគាត់នោះ ប៉ុន្តែវាក៏មិនអាចមិនអើពើដែរ ចំពោះអង្គហេតុដែលថា ផលប្រយោជន៍របស់សហមេធាវីដែលត្រូវបានចាត់តាំង មានអានុភាពគាំទ្រ មាស មុត ក្នុងការមិនផ្តល់សក្ខីកម្ម។ ជាថ្មីម្តងទៀត ប្រសិនបើ មាស មុត គោរពតាមការប្រកាសរបស់គាត់ ពាក់ព័ន្ធនឹងការសុខចិត្តផ្តល់សក្ខីកម្មនោះ ទស្សនៈដែលថាគាត់យកជម្រើសបែបនេះដោយមានមេធាវីការពារក្តីមិនមែនដោយសារវាស្ថិតក្នុងផលប្រយោជន៍របស់គាត់ ប៉ុន្តែដោយសារតែវាបម្រើឲ្យផលប្រយោជន៍មេធាវីការពារក្តីរបស់គាត់នោះ នឹងមានច្រើនលើសលប់ និង "កាត់បន្ថយនូវទំនុកចិត្តរបស់សាធារណជន" ទៅលើ អ.វ.ត.ក និងកិច្ចការរដ្ឋបាលរបស់ អង្គជំនុំជម្រះ។

---

[184] ឯកសារ **D56/4/1.2** ត្រង់ទំព័រ ២។

[185] ឯកសារ **D56/4/1** ត្រង់ទំព័រ ១ ("លោក មាស មុត ក៏បានផ្តល់នូវការជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីបំណងរបស់គាត់ ក្នុងការប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយតបក្នុងសំណុំរឿង ០០២ (ប្រសិនបើគាត់ត្រូវបានកោះហៅឲ្យផ្តល់ភ័ស្តុតាង) និងសំណុំរឿង ០០៣ (ប្រសិនបើការិយាល័យសហចៅក្រមស៊ើបអង្កេតស្នើសុំស្តាប់ចម្លើយរបស់គាត់...) ដូចខាងលើ កថាខណ្ឌ ៣៤។ ដូចខាង លើ កថាខណ្ឌ ៤០។

៧៧- ដូច្នេះ បន្ថែមទៅលើភាពមិនអាចលះបង់ចោលនូវទំនាស់ផលប្រយោជន៍នៅពេលនេះរវាង អៀង សារី និង មាស មុត សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ គួរតែបដិសេធកុំបញ្ជាក់អះអាងនូវការចាត់តាំងនេះ ជាផ្នែកមួយនៃអំណាចឆន្ទានុសិទ្ធិក្នុងការការពារ ផលប្រយោជន៍របស់ អ.វ.ត.ក ដែលជាស្ថាប័នមួយ។ វាគួរតែបែបនេះ ក្នុងករណីដែលពុំមានកង្វះ ខាតនូវមេធាវីដែលមានសមត្ថភាពដែលអាចឲ្យ DSS តែងតាំងបាន ដែលពុំមានអានុភាពទៅលើ កិច្ចដំណើរការនីតិវិធីណាមួយនៅចំពោះមុខតុលាការ ហើយក៏មិននាំឲ្យមានមន្ទិលទៅលើកិច្ចដំណើរ ការនីតិវិធីនោះឡើយ។

## ៣. លិខិតលះបង់សិទ្ធិមិនមានសុពលភាព

៧៨- ***ជម្រើសម្យ៉ាងទៀត ការយល់ព្រមដែលទទួលបានពីកូនក្តីទាំងពីរ គឺពុំមានសុពលភាព ហើយលិខិត លះបង់សិទ្ធិរបស់ អៀង សារី មិនអាចកែប្រែបានទៀតឡើយ។*** ប្រសិនបើសហចៅក្រមស៊ើបអង្កេត មិនយល់ស្របជាមួយនឹងសហព្រះរាជអាជ្ញាអន្តរជាតិថាទំនាស់នោះ មិនអាចលះបង់ចោលបាន និង/ឬថា ព្យសនកម្មដល់ អ.វ.ត.ក ដែលជាស្ថាប័នមួយ រារាំងមិនឲ្យមានការចាត់តាំងសហមេធាវី ដែលត្រូវបានចាត់តាំងនោះ សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា ទោះបីជាយ៉ាងណាក៏ដោយ សហមេធាវីដែលត្រូវបានចាត់តាំង មិនគួរត្រូវបានតែងតាំងឡើយ ពីព្រោះសហមេធាវីដែលត្រូវបាន ចាត់តាំងមិនបានបង្ហាញនូវលិខិតលះបង់សិទ្ធិគ្រប់គ្រាន់ពី មាស មុត និង អៀង សារី ដែលមាន លក្ខណៈគ្រប់គ្រាន់ ដើម្បីធានាដល់ចៅក្រមថា បុគ្គលទាំងនោះបានទទួលព័ត៌មានលម្អិត និងផល វិបាកអំពីការលះបង់សិទ្ធិរបស់ពួកគាត់ និងមានលក្ខណៈគ្រប់គ្រាន់ផងដែរ ក្នុងការទប់ទល់នឹងបញ្ហា ប្រឈមណាមួយក្រោយៗទៀត។

៧៩- លិខិតលះបង់សិទ្ធិដែលបានផ្តល់ឲ្យនោះ មានលក្ខណៈទូទៅ និងទូលំទូលាយមែនទែន ទាក់ទិននឹង បញ្ហាប្រឈមនានាដែលមិនអាចបំពេញនូវបទដ្ឋានជាធរមានឡើយ ដោយគ្រាន់តែបញ្ជាក់ថា បុគ្គល ទាំងនោះ "សុខចិត្តលះបង់ចោលនូវជម្លោះផលប្រយោជន៍ណាមួយដែលអាចកើតឡើង ដោយស្ម័គ្រ ចិត្ត ដោយដឹងខ្លួន និងដោយឥតកែប្រែ"[186] ដូច្នេះវាមិនបានបង្ហាញនូវការយល់ព្រម ដែលទទួលបាន ព័ត៌មានគ្រប់គ្រាន់ និងពេញលេញឡើយ។ ភាពទូទៅនេះ បង្កឲ្យមាននូវក្តីបារម្ភ ពីព្រោះពុំមានការ

---

[186] ឯកសារ **D56/4/1.2** ទំព័រ ២, ៦។ លិខិតលះបង់សិទ្ធិរបស់ អៀង សារី ប្រើពាក្យពេចន៍ខុសគ្នាបន្តិចបន្តួចនៅក្នុងផ្នែកដែល ពាក់ព័ន្ធ "សុខចិត្តលះបង់ចោលនូវជម្លោះផលប្រយោជន៍ជាសក្តានុពលណាមួយដែលអាចកើតឡើង ដោយស្ម័គ្រចិត្ត ដោយដឹងខ្លួន និងដោយឥត កែប្រែ"។

ចង្អុលបង្ហាញថា បុគ្គលទាំងនោះទទួលបាននូវព័ត៌មានពេញលេញអំពីស្ថានភាពជាក់លាក់ដែលទំនាស់ផលប្រយោជន៍នោះ អាចកើតមាន ឬថាតើជម្លោះនោះអាចប៉ះពាល់យ៉ាងដូចម្ដេចដល់ការការពារឲ្យពួកគាត់ដោយសហមេធាវីដែលត្រូវបានចាត់តាំងនោះ។ ប្រការនេះ បង្កើតឲ្យមាននូវបញ្ហាជាពិសេស នៅក្នុងករណីដែលមានភាពស្មុគស្មាញបែបនេះ និងនៅពេលណាមួយក្នុងកិច្ចដំណើរការនីតិវិធីដែលអង្គហេតុជាច្រើន ទាំងអង្គហេតុដាក់បន្ទុក និងអង្គហេតុដោះបន្ទុក មិនទាន់ត្រូវបានបញ្ចេញឲ្យដឹងនៅឡើយទេ ដូច្នេះហើយលក្ខណៈពេញលេញនៃទំនាស់ផលប្រយោជន៍នេះអាចពិបាកក្នុងការបញ្ជាក់ការពិត។

៨០- លិខិតលះបង់សិទ្ធិនេះ មិនត្រឹមតែមានចំណុចខ្វះខាតក្នុងការពុំបានផ្ដល់នូវការចង្អុលបង្ហាញឲ្យបានគ្រប់គ្រាន់ថា មាស មុត និង អៀង សារី ទទួលបានព័ត៌មានអំពីគ្រប់ទិដ្ឋភាពទាំងអស់នៃជម្លោះផលប្រយោជន៍ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងខកខានពុំបានចង្អុលបង្ហាញថា បុគ្គលទាំងនោះទទួលបានការជូនដំណឹង និងយល់ព្រមទៅនឹងរបៀបនៃការដោះស្រាយជម្លោះផលប្រយោជន៍នានានោះ ឬអាចនិយាយ ម៉្យាងទៀតថា ផលប្រយោជន៍របស់បុគ្គលមួយណានឹងត្រូវទុកជាមោឃៈ ក្នុងការដោះស្រាយទំនាស់នោះ។ ជាឧទាហរណ៍មួយ លិខិតលះបង់សិទ្ធិរបស់ អៀង សារី ពុំបានចង្អុលបង្ហាញអំពីការយល់ព្រមរបស់គាត់ ក្នុងការលះបង់សិទ្ធិរបស់គាត់ក្នុងការរក្សាការណ៍សម្ងាត់ អំពីព័ត៌មានឯកសិទ្ធិស្របច្បាប់ ដែលសិទ្ធិនេះនៅតែបន្តមាន ទោះបីជាគាត់ស្លាប់ក៏ដោយ។

៨១- ជាងនេះទៀត កង្វះភាពជាក់លាក់នៅក្នុងលិខិតលះបង់សិទ្ធិរបស់ អៀង សារី ដែលបានចុះហត្ថលេខានៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១២ ជាបញ្ហាពិសេស ដោយសារនាពេលចុះហត្ថលេខា អៀង សារី គួរបានដឹងថា គាត់នៅតែមានអំណាចក្នុងការលើកចេញនូវការលះបង់សិទ្ធិរបស់ខ្លួន និង/ឬ បញ្ចប់ការកាពាររបស់សហមេធាវីដែលត្រូវបានចាត់តាំងចំពោះរូបគាត់ ដោយសារមានបញ្ហាទំនាស់ផលប្រយោជន៍ជាច្រើនកើតឡើង និងស្នើសុំឲ្យមានដំណោះស្រាយ។ នាពេលនេះ ដោយសារ អៀង សារី ទទួលមរណភាពទៅហើយ គាត់ក៏លែងគ្រប់គ្រងលើសិទ្ធិ និងផលប្រយោជន៍របស់ខ្លួនបានទៀតដែរ។

៨២- បន្ថែមលើការមិនបានបញ្ចូលនូវខ្លឹមសារជាក់លាក់ពេញលេញនោះ លិខិតលះបង់សិទ្ធិទាំងនោះក៏មិនបានបង្ហាញពីការការពារតាមនីតិវិធីឲ្យបានពេញលេញទេ នៅពេលលិខិតលះបង់សិទ្ធិទាំងនេះមានសុពលភាព។ ជាពិសេស លិខិតលះបង់សិទ្ធិមិនបានចង្អុលបង្ហាញថា មេធាវីខាងក្រៅបានផ្ដល់យោបល់ដល់បុគ្គលទាំងពីររូបនេះក្នុងការចុះហត្ថលេខាលើលិខិតលះបង់សិទ្ធិទាំងនេះឡើយ ហើយ

សហមេធាវីដែលត្រូវបានចាត់តាំង ឬអង្គភាពគាំពារការការពារក្តី ក៏មិនបានជូនដំណឹងថាពួកគេគួរតែធ្វើបែបនេះដែរ។

៨៣- ការចាត់តាំងមេធាវីដោយគ្មានលិខិតលះបង់សិទ្ធិត្រឹមត្រូវនោះ មិនត្រឹមតែត្រូវហាមឃាត់ដោយក្រមសីលធម៌វិជ្ជាជីវៈប៉ុណ្ណោះទេ ប៉ុន្តែពាក់ព័ន្ធនឹង មាស មុត ការចាត់តាំងនេះ ក៏នឹងមិនបានការពារនឹងការទាមទារសុំជំនួយដែលមិនមានប្រសិទ្ធភាពពីមេធាវីក្នុងកិច្ចដំណើរការនីតិវិធីនាពេលបន្ទាប់ទៀតឡើយ ដោយសារជនជាប់ចោទអាចទាមទារថា គាត់មិនយល់ច្បាស់ពីទំនាស់ផលប្រយោជន៍ដែលអាចកើតមាននោះទេ។ សម្រាប់ហេតុផលទាំងនេះ និងដោយសារមានកំហុសឆ្គងធ្ងន់ធ្ងរនៅក្នុងលិខិតលះបង់សិទ្ធិដែល អៀង សារី បានចុះហត្ថលេខា មិនបានកែប្រែបាន ដោយសារតែគាត់បានទទួលមរណភាពទៅហើយនោះ ការការពារដែលមានទំនាស់ផលប្រយោជន៍ មិនគួរត្រូវអនុញ្ញាតឲ្យបន្តដំណើរការទៀតទេ។

## VI. **សំណូមពរ**

៨៤- សម្រាប់សម្អាងហេតុទាំងនេះ សហព្រះរាជអាជ្ញាអន្តរជាតិសូមស្នើដោយគោរពដល់សហចៅក្រមស៊ើបអង្កេត មេត្តា**ទទួលយក** និង**តម្កល់**សំណើរបស់គាត់ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១២ និងសារណាបន្ថែមភ្លាមៗ, **បដិសេធ**ចំពោះការចាត់តាំងសហមេធាវីដែលត្រូវបានចាត់តាំង ដោយសម្អាងទៅលើទំនាស់ផលប្រយោជន៍ដែលមិនអាចសម្របសម្រួលបាន ឬជាជម្រើសម្យ៉ាងទៀត បដិសេធលិខិតលះបង់សិទ្ធិដែលមិនមានប្រសិទ្ធភាព និង**ណែនាំ**ឲ្យអង្គភាពគាំពារការការពារក្តី ជូនដំណឹងដល់ជនសង្ស័យពីបញ្ហានេះ និងជួយគាត់ក្នុងការអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការមានមេធាវីឲ្យបានសមស្រប។

សូមលោកសហចៅក្រមស៊ើបអង្កេតមេត្តាទទួលយកសារណាបន្ថែមនេះដោយគោរព។

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៣ | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញាអន្តរជាតិ | ភ្នំពេញ | [signature] |